00286053

**Decalssified to Public**
**06 September 2012**

E1/2.1

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩**

**កិច្ចប្រជុំរៀបចំសវនាការ (អសាធារណៈ)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោក យ៉ា សាខន

**ការិយាល័យសហព្រះរាជអាជ្ញា** ខាតវ៉ាយថ៍

លោកស្រី ជា**លោង** ហ្សង់ ម៉ាកឡាវែន៍

លោក ធូ មណី

លោក យូរ ឧត្តរា

**មេធាវីសាលាដំបូង៖**

លោក លឹម សួយហុង

លោក ពេជ្រ **ឈេម្បា** ម៉ាតូ គ្រីស្តារ

លោកស្រី សែ កុលវុឌ្ឍី (ក្រឡាបញ្ជី)

កញ្ញា ណាតាចាក់ វិចស៊ែល (ក្រឡាបញ្ជី)

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូប៊ឺត ពើទីត

លោក យ៉េត ចរិយា

លោក វាលៀម ស្មិត

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

លោក ជឺហ្គិន អាស្នាន

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនត្រូវចោទ កាំង ហ្គេកអ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី

លោក ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក សាន់ រ៉ាដា

# កិច្ចដំណើរការប្រជុំ

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបសួរ អស់លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះ ។ ឥឡូវនេះ យើងចាប់ផ្តើមបន្តដំណើរការកិច្ចប្រជុំរបស់យើងតាមរបៀបវារៈដែលគ្រោងទុក សម្រាប់កិច្ចប្រជុំនៅថ្ងៃនេះ។

នៅថ្ងៃនេះរបៀបវារៈអង្គប្រជុំ មានការគ្រប់គ្រងសវនាការ ជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ ហើយយើងមានរបៀបវារៈ ចែកជារបៀបវារៈតូចៗជាច្រើន ។ នៅក្នុងនោះគឺ ចាប់ដំបូងគឺ អំពីបទបញ្ជាសវនាការ ។ អនុលោមតាមរបៀបវារៈនេះ អង្គប្រជុំក្នុងពេលនេះ ខ្ញុំសូមប្រកាសអំពីបទបញ្ជាដែលត្រូវអនុវត្តក្នុងអំឡុងពេលដឹកនាំសវនាការ ។ ហើយបទបញ្ជានេះនឹងមានឯកសារចម្លងមួយច្បាប់នៃបទបញ្ជា នឹងមានបទនៅផ្លូវចូលបន្ទប់តុលាការ និងក្នុងសាលសវនាការធំ ។

ឯខ្លឹមសារនៃបទបញ្ជាក្នុង សាលសវនាការសម្រាប់អំឡុងពេលសវនាការមានដូចតទៅនេះ៖ បទបញ្ជាផ្ទៃក្នុងសាលសវនាការសម្រាប់ថ្ងៃសវនាការ៖

ដើម្បីរក្សានូវសណ្តាប់ធ្នាប់របៀបរៀបរយសន្តិសុខ និងដំណើរការបានល្អក្នុងពេលសវនាការ ប្រធានអង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងសាលវសនាការ ក្នុងអំឡុងពេលសវនាការដូច ខាងក្រោម៖

១) អ្នកដែលមានបំណងចូលរួមក្នុងសាលសវនាការទាំងអស់ត្រូវមានវត្តមានក្នុងសាលាតុលាការក្នុងអង្គជនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឲ្យបានមុនម៉ោង៨និង៣០នាទីព្រឹក និងមុន ម៉ោង ១ និង ៣០នាទីរសៀល ។

២) អ្នកចូលរួមក្នុងសាលសវនាការត្រូវមានអាកប្បកិរិយាថ្លៃថ្នូរសមរម្យជានិច្ច។

៣) ហាមយកម៉ាស៊ីនថតរូប ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសំឡេង និងឧបករណ៍បំពងសំឡេងគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង។

៤) ហាមជក់បារី ឬក៏យកចំណីអាហារ ភេសជ្ជៈគ្រប់ប្រភេទ ចូលក្នុងសាលសវនាការ ។

៥) ហាមយកអាវុធគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែភ្នាក់ងារសន្តិសុខដែលមានសមត្ថកិច្ច ។

00286056



៦) ហាមប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទក្នុងសាលសវនាការ ហាមថតរូបភាព ឬថតសំឡេងតាមគ្រប់មធ្យោបាយ ។

៧) ហាមប្តូរទីកន្លែងអង្គុយ ឬដើររហេតរហូតក្នុងសាលសវនាការ ។

៨) ហាមទះដៃ ឬស្រែកជយឃោស ឬស្រែកឡូឡា ឬការធ្វើឱ្យមានសំឡេងខ្លាំង នាំឱ្យរំខានដល់ដំណើរការសវនាការ ។

៩) ហាមដើរចេញចូល ដោយអនាធិបតេយ្យនៅពេលសវនាការ ។ ការចេញចូល ត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខរក្សាសណ្តាប់ធ្នាប់ក្នុងសាលសវនាការ ។

១០) ហាមកុមារដែលមានអាយុតិចជាង១៦ឆ្នាំ ចូលក្នុងសាលសវនាការ ។ ក្នុងករណីដែលកុមារមានអាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ អាចចូលក្នុងសាលសវនាការបាន ប្រសិនបើគាត់មកជាមួយឪពុក ឬម្តាយ ឬអាណាព្យាបាល លើកលែងតែកុមារណាដែលត្រូវចូលរួម ក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី ។

១១) ក្នុងករណីមានបុគ្គលប្រព្រឹត្តបទល្មើសនឹងបទបញ្ជាផ្ទៃក្នុងនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងនឹងចាត់វិធានការ ដើម្បីរារាំង ឬទប់ស្កាត់ភ្លាមៗ តាមករណីសមស្របផ្អែកតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។ នេះជាបទបញ្ជា ដើម្បីគ្រប់គ្រងសាលសវនាការឱ្យមានសណ្តាប់ធ្នាប់ នៅក្នុងអំឡុងពេលធ្វើសវនាការ ។

របៀបវារៈជាបន្តទៅទៀតនេះ គឺការបង្ហាញអំពីប្រតិចារឹក និងថតសោតទស្សន៍ ដែលរបៀបវារៈនេះ បានស្នើបន្ថែមដោយសហព្រះរាជអាជ្ញា ។ ពាក់ព័ន្ធនឹងរបៀបវារៈត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូង សូមអញ្ជើញមន្ត្រីជាន់ខ្ពស់ខាងផ្នែកគ្រប់គ្រងតុលាការ ឡើងធ្វើបទបង្ហាញដោយសង្ខេបនូវបច្ចុប្បន្នភាពនៃការធ្វើចំដែលធ្វើឡើងដោយ *ស៊ីអ៊ីមអេស* ទាក់ទងទៅនឹងធ្វើប្រតិចារឹក និងការថតសោតទស្សន៍នៃដំណើរការនីតិវិធី ព្រមទាំងការលុបនូវផ្នែកនៃព័ត៌មានដែលជាការសម្ងាត់ ។ ហើយរយៈពេលសូមកម្រិតក្នុងកម្រិតរង្វង់២០នាទី ។ សូមអញ្ជើញ ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំឈ្មោះ ថារីក អាប់ឌុលឡាក់ ខ្ញុំជាមន្ត្រីជាន់ខ្ពស់នៅក្នុងផ្នែកគ្រប់គ្រងតុលាការ ហើយខ្ញុំបាននៅជាមួយ ឯកឧត្តម តូនី ក្រាញ់ នឹងធ្វើការថ្លែងសុន្ទរកថាខ្លីមួយ អំពីសោតទស្សន៍ ហើយនិងប្រតិចារឹក ។ ហើយបន្ទាប់មក ខ្ញុំបាទ នឹងទុកឱកាសដើម្បីឱ្យសួរនូវសំណួរណាមួយ

ដែលពាក់ព័ន្ធ ។

លោកចៅក្រម! នៅក្នុងការរៀបចំសវនាការនៅក្នុងតុលាការយើងនេះ ហើយក៏ដូចគ្នានៅក្នុងតុលាការប្រហាក់ប្រហែលគ្នានេះដែរ គឺថាខ្ញុំនឹងព្យាយាមធ្វើសុន្ទរកថាដ៏ខ្លីមួយ ដើម្បីទុកឱកាសដើម្បីបានឆ្លើយនូវសំណួរ ។ ជាសំខាន់នោះគឺថា តុលាការទាំងពីរ សាលទាំងពីរនៅក្នុងបន្ទប់នេះឯង នឹងមានការថតសំឡេងសោតទស្សន៍លក្ខណៈ*ឌីជីថល* គឺថាមានផ្នែកវីដេអូ និងមានកាមេរ៉ា៥នៅក្នុងបន្ទប់សាលសវនាការ ដែលអស់លោក លោកស្រី អាចឃើញ ។ ហើយនិងការថតសំឡេងផងដែរ សម្រាប់ការបកប្រែផ្ទាល់មាត់ នៅខាងផ្នែកសំឡេង ។

ទាក់ទងទៅខាងផ្នែកវីដេអូនោះ កាមេរ៉ាហ្នឹង គឺមានការថតចេញពីបន្ទប់នៅខាងក្រោយខ្ញុំនេះ ហើយការថតសំឡេងហ្នឹង គឺថាកើតឡើងដំណើរគ្នានៅពេលសវនាការកំពុងដំណើរការ ហើយការថតនេះ គឺអ្វីដែលយើងបានឃើញនៅលើអេក្រង់របស់យើង ។

អ៊ីចឹងខាងផ្នែកគ្រប់គ្រងតុលាការហ្នឹងធ្វើការកត់ត្រាតែមួយផ្នែកប៉ុណ្ណោះ មានន័យថា គឺរូបភាពដែលអស់លោក លោកស្រី បានឃើញនៅលើកញ្ចក់ហ្នឹងឯង គឺជារូបភាពដែលកំពុងតែថត ។ កាមេរ៉ាហ្នឹងគឺថតចេញពីបន្ទប់សោតទស្សន៍ គឺគេអាចថតបាននូវគ្រប់ផ្នែកណាមួយនៅក្នុងសាលសវនាការ ហើយនៅក្នុងពេលខាងមុខទៀតដែរ យើងនឹងធ្វើការណែនាំអំពីទាក់ទងទៅនឹងប្រព័ន្ធសោតទស្សន៍នេះឯង និងសម្រាប់ការប្រើប្រាស់និងការអនុវត្ត ដែលជាវិធាននៅពេលណាមួយ ដូចថាសាលសវនាការត្រូវបានថតចម្លងនោះ ។

អ៊ីចឹងសេចក្ដីណែនាំទាំងអស់នេះ នឹងនិយាយអំពីស្ថានភាពប្រហាក់ប្រហែលគ្នាដែរ នៅក្នុងសាលសវនាការដទៃៗទៀត ហើយនេះគឺជាកំណត់ត្រានៃដំណើរការនីតិវិធី ហើយកាមេរ៉ាហ្នឹងឯងនឹងកត់ត្រាទុកនៅពេលដែលយើងកំពុងតែនិយាយ ។

និយាយអំពីបញ្ហាផ្នែកប្រព័ន្ធវីដេអូ ដែលជាប្រព័ន្ធឌីជីថលហ្នឹង មានន័យថា គឺជាការបង្ហាញនូវភស្តុតាង ដែលជាប្រព័ន្ធនេះ គឺថាវាមានប្រភេទពីរ-បីផ្សេងៗគ្នា ផ្នែកមួយហ្នឹងឯង គឺជាការបង្ហាញគឺជាកុំព្យូទ័រសម្រាប់ការបង្ហាញ ដែលមាននៅក្នុងបន្ទប់សវនាការ ដែលកុំព្យូទ័រនេះ អាចអនុញ្ញាតឱ្យភាគីណាមួយ ធ្វើការបង្ហាញដល់សាលសវនាការ និងអ្នកចូលរួមទាំងអស់នូវភស្តុតាងជា ឌីជីថល ណាមួយ ឧទាហរណ៍៖ គឺឯកសារក្នុងទម្រង់*វីត* ឬក៏ក្នុងលក្ខណៈជា *ផៅវ័រ ភ័ញ* ឬក៏ការថតសំឡេង ឬក៏ការថតវីដេអូ មានន័យថាយើងអាចចាក់ផ្សាយនូវឧបករណ៍ថតទាំងនេះជាទម្រង់*ឌីជីថល* ។

នេះគឺអាស្រ័យទៅលើការណែនាំរបស់ខាងអង្គជំនុំជម្រះដែរជាទូទៅ ។ អ៊ីចឹងភាគីមួយអាចបង្ហាញនៅពីកន្លែង ដែលខ្លួនគាត់អង្គុយនៅក្នុងសាលសវនាការបាន ។ អ៊ីចឹងភស្តុតាងជាលក្ខណៈឌីជីថលនេះ គឺថាអាចមើលឃើញនៅលើអេក្រង់ ហើយនៅក្នុងផ្នែកសាធារណជន-- សាធារណជនក៏អាចមើលឃើញផងដែរ ។ អ៊ីចឹងនេះ គឺជាផ្នែកមួយនៃការបង្ហាញអំពីភស្តុតាង ។

ផ្នែកមួយទៀតនោះ គឺជាឧបករណ៍ ដែលមានឈ្មោះថា គឺជាកាមេរ៉ាសម្រាប់ថតភស្តុតាង ឬក៏ឯកសារ គឺថាមានមួយនៅក្នុងកន្លែងដែលសម្រាប់សាក្សី ។ ឧបករណ៍នេះ គឺសម្រាប់បង្ហាញអំពីវត្ថុអ្វីដែលមានជារូបរាង ។ គឺថាហើយនឹងមានបង្ហាញផងដែរនៅលើអេក្រង់នៅមុខលោក លោកស្រី ។

អ៊ីចឹងការបង្ហាញនូវឧបករណ៍បែបហ្នឹងឯង នៅលើអេក្រង់ហ្នឹង គឺមានន័យថាបានថតសំឡេងទុកនៅក្នុងប្រព័ន្ធសោតទស្សន៍នៃដំណើរការនីតិវិធីនេះ ។ អ៊ីចឹងបន្ទប់សវនាការហ្នឹងឯង គឺមានការបកប្រែប្រដេញ ហើយអ៊ីចឹងនីតិវិធីអស់ទាំងនេះ គឺអាចកើតឡើងនៅក្នុងសាលសវនាការទាំងពីរនៅពេលដំណាលគ្នា ក្នុងភាសាជាផ្លូវការទាំងបីរបស់តុលាការ ។ ដូចដែលអស់លោក លោកស្រីបានឃើញអ៊ីចឹងគឺថាយើងមានបន្ទប់អ្នកបកប្រែនៅខាងលើនេះ ។ អ៊ីចឹងគឺអាចមើលឃើញដំណើរការនៃនីតិវិធីបាននៅលើអេក្រង់របស់ពួកគាត់ ហើយនិងភស្តុតាងដែលបានបង្ហាញដល់ចៅក្រមជាដើម ។

ផ្នែកមួយទៀតនៃប្រព័ន្ធសោតទស្សន៍នោះ គឺថាការធ្វើទាក់ទងគ្នាតាមរយៈវីដេអូ ជួនកាលអាចមានតម្រូវការ នូវតម្រូវការនៃប្រព័ន្ធបែបនេះ ។ អ៊ីចឹងតុលាការហ្នឹងគឺអាចមានការធ្វើការទាក់ទងគ្នាតាមរយៈវីដេអូបាន អាចទាក់ទងពីប្រទេសខ្មែរទៅបរទេស ។ ការប្រើប្រព័ន្ធហ្នឹង គឺមានវាលក្ខណៈបច្ចេកទេសខ្លះ ហើយមានតម្រូវការផ្នែកបច្ចេកទេស ហើយខ្ញុំសូមស្នើដល់ភាគីទាំងអស់ គឺថាឲ្យធ្វើការជូនដំណឹងជាមុន ប្រសិនបើត្រូវការនូវសេវាកម្មបែបនេះ ។

អ៊ីចឹងនៅក្នុងប្រទេសកម្ពុជាយើងហ្នឹងឯង គឺថាត្រូវការប្រើប្រព័ន្ធដែលអាចលើកចុះឡើងបាន ។ មានន័យថាសម្រាប់ផ្នែកដែលនៅឯទីឆ្ងាយ និងសម្រាប់ផ្នែកដែលនៅក្នុងតំបន់នេះ ។ ហើយសម្រាប់ផ្នែកនៅក្នុងសាលសវនាការផងដែរ ។ ហើយសម្រាប់ការធ្វើការទាក់ទងគ្នាតាមវីដេអូ នៅអន្តរជាតិ នៅបរទេសនោះ ឧទហរណ៍ គឺយើងអាចប្រើស្ថាប័ន *យូអិន* ណាមួយដែលមានភាពប្រហាក់ប្រហែលគ្នានៅក្នុងប្រព័ន្ធទាក់ទងគ្នាតាមវីដេអូបាននេះ ឬក៏ស្ថាប័ននានានៅក្នុងប្រទេសនានាផងដែរ ដែលតម្រូវការនេះចាំបាច់នោះ គឺថាត្រូវការការអនុញ្ញាតពីភាគីអស់ទាំងនោះ ។

ទាក់ទងទៅនឹងប្រតិចារឹក វិធានផ្ទៃក្នុងបានផ្តល់ផងដែរ នៅក្នុងវិធាន ៩៧.២ ហ្នឹងឯង គឺមាន

ន័យថា ប្រតិចារឹកទាំងស្រុងនឹងត្រូវធ្វើនូវអំពីសាលសវនាការ ហើយយើងបានរៀបចំនៅប្រព័ន្ធមួយ ហើយនិងនីតិវិធី ហើយនិងធនធាន ដើម្បីរៀបចំធ្វើប្រតិចារឹក ។ ហើយដែលមិនចាំបាច់និយាយពីបញ្ហាបច្ចេកទេសឱ្យបានលម្អិតនោះ ជាសំខាន់គឺថាយើងសង្ឃឹមថា នឹងផ្តល់នូវសេចក្តីព្រាងនៃប្រតិចារឹកដែលបានថតនឹងធ្វើឡើង នូវអ្វីដែលបាននិយាយនៅក្នុងសាលសវនាការ នៅក្នុងអំឡុងពេលនៃនីតិវិធី ក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីសវនាការបានបញ្ចប់នោះ ។

អ៊ីចឹងពេលហ្នឹង គឺថាអាចមានការផ្លាស់ប្តូរមិនអាចប្រាកដអ៊ីចឹងទេ អាចខ្លីជាងហ្នឹង ឬក៏អាចវែងជាងហ្នឹង ។ អ៊ីចឹងសម្រាប់ការស្នើប្រញាប់ណាមួយហ្នឹង គឺថាប្រហែលជាយើងប្រហែលជា អាចធ្វើនៅដំណាក់ដំណាលគ្នានៃពេលសវនាការ ។ ប៉ុន្តែជាទូទៅគឺរយៈពេល២៤ម៉ោងក្រោយទើប យើងអាចធ្វើនូវប្រតិចារឹកបាន ។

អ៊ីចឹងហើយប្រតិចារឹកហ្នឹង គឺធ្វើជាភាសាផ្លូវការទាំង៣របស់តុលាការយើង គឺយើងនឹងផ្តល់ដំបូងជាសេចក្តីព្រាងដល់ខាងអង្គជំនុំជម្រះ ហើយបន្ទាប់មកទៀតដល់ភាគី ហើយយើងនឹងទុកឱកាសដើម្បីធ្វើការកែប្រែទៅលើសេចក្តីព្រាងនោះ ។ អ៊ីចឹងបន្ទាប់មកទៀតហ្នឹងឯង គឺនិយាយអំពីការផលិតនូវកំណត់ហេតុ គឺថាជាទូទៅលោកចៅក្រមបានដឹងអំពីការផលិតនូវកំណត់ហេតុនៃសវនាការហើយ ។ នេះគឺដើម្បីជាប្រយោជន៍ដល់អ្នកចូលរួមទាំងអស់ ពីព្រោះយើងមិនមែនធ្វើការធ្វើនីតិវិធីផ្ទាល់នោះទេ ។ មានន័យថាយើងមិនធ្វើការអាចផ្សព្វផ្សាយផ្ទាល់នោះទេ ។

អ៊ីចឹងការលុបផ្នែកណាមួយ គឺនឹងកើតមានឡើងនៅពេលក្រោយ បន្ទាប់ពីនីតិវិធីបានបញ្ចប់ ហើយដូច្នេះតម្រូវការពីខាងផ្នែកចៅក្រមហ្នឹង ដើម្បីថាតើត្រូវលុបចេញនូវផ្នែកណាមួយមុននឹង--ជាផ្នែកនៃសាធារណៈនៃការថតចម្លងនេះ ។ អ៊ីចឹងវាអាចមានដូចជាផ្នែកណាមួយដែលជាឯកសារសម្ងាត់ដែលមិនគួរឱ្យសាធារណជនដឹង ឬក៏នៅពេលសវនាការអសាធារណៈណាមួយនោះ ។

អ៊ីចឹងដីកានេះឯង គឺថានឹងយើងធ្វើការគ្នាជាមួយនឹងអង្គចៅក្រម ហើយសម្រាប់ឱ្យខាងបច្ចេកទេសធ្វើការសម្រួល ឬក៏លុបចោលនូវផ្នែកណាមួយដែលត្រូវលុបនោះ ។ ហើយយើងនឹងយកអនុវត្តផងដែរ ទៅលើការថតប្រព័ន្ធសោតទស្សន៍ទាំងអស់ ហើយនិងទៅលើប្រតិចារឹកផងដែរ ។ ហើយនៅពេលយើងធ្វើការលុបហើយនោះ ទើបយើងអាចផ្សព្វផ្សាយដល់សាធារណៈបាន ។

អ៊ីចឹងគឺថាយើងរៀបចំនូវប្រព័ន្ធនេះដើម្បីធ្វើការធានាថា ការលុបហ្នឹងឯង គឺអាចកើតឡើងក្នុងរយៈពេលខ្លីមួយ ជាទូទៅគឺនៅក្នុងថ្ងៃតែមួយជាមួយគ្នា នៅពេលដែលមានដីកាបញ្ជាឱ្យធ្វើការលុបបែប

នោះ ។ ហើយជាការពិតណាស់ គឺថាយើងរក្សានូវកំណត់ហេតុដើមទុកសម្រាប់ការរក្សាផ្ទៃក្នុងរបស់យើង សម្រាប់តុលាការ និងភាគីពាក់ព័ន្ធគ្នានៅក្នុងសាលសវនាការ ។

ខ្ញុំនឹងនិយាយបន្តិចផងដែរទាក់ទងទៅនឹងចំណុចមួយ នៅពេលដែលយើងនិយាយអំពីការគ្រប់គ្រងតុលាការនោះ ខាងផ្នែកគ្រប់គ្រងតុលាការ គឺនឹងមានមន្ត្រីគ្រប់គ្រងតុលាការនៅក្នុងអំឡុងពេលនីតិវិធី ហើយគឺថាតែងតែមានមន្ត្រីគ្រប់គ្រងតុលាការដែលមានវត្តមានដើម្បីរៀបចំសម្របសម្រួល គឺថាមាន ដូចជាគាត់ជាដើម នឹងអាចទទួលនូវសំណើរ ឬក៏បញ្ហាអ្វីមួយទាក់ទងទៅនឹងប្រតិចារឹក ឬក៏ទាក់ទងទៅនឹងសោតទស្សន៍ ហើយជាសំខាន់ គឺថាពួកគេធ្វើការសម្របសម្រួលជាមួយខាងផ្នែកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្រាប់វិធានការការពារសាក្សីជាដើម ។

ខ្ញុំជឿថាអ្នកចូលរួមទាំងអស់គ្នា គឺថាបានដឹងយល់ដឹងច្បាស់ណាស់អំពី វិធានការការពារនោះឯង ហើយខ្ញុំអាចនឹងពន្យល់រយៈពេលខ្លីមួយ ប្រសិនបើយល់ថាជាការចាំបាច់នោះ ។ ប៉ុន្តែខ្ញុំ មិនចង់ធ្វើសេចក្តីអធិប្បាយបន្ថែមទេ ទាក់ទងទៅលើចំណុចនេះ ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោក ថារីក ដែលបានធ្វើបទង្ហាញនេះ ។ ជាបន្តទៀត សូមផ្តល់វេទិកានេះជូនទៅភាគីដែលពាក់ព័ន្ធ ។ ជាដំបូងនេះ គឺសូមអញ្ជើញមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានសំណួរ ឬមានការកត់សម្គាល់អ្វីទេ ពាក់ព័ន្ធទៅនឹងរបៀបវារៈនេះ? ទៅនឹងបទបង្ហាញរបស់លោក ថារីក ដែលបានធ្វើបទបង្ហាញអម្បាញ់មិញនេះ ។

សូមអញ្ជើញ !

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

លោកចៅក្រម ខ្ញុំមានសំណួរមួយដែលត្រូវសួរ តើលោកចៅក្រមផ្តល់ភាគី--ដល់ភាគីទាំងអស់នូវប្រតិចារឹក ដោយមានធ្វើជាសំណើ ឬក៏ដោយផ្តល់ដោយលក្ខណៈស្វ័យប្រវត្តិ? ពីព្រោះនៅខាងអង្គបុរេជំនុំជម្រះហ្នឹងឯង គាត់ផ្តល់ប្រតិចារឹកនៅពេលដែលមាននូវសំណើតែប៉ុណ្ណោះ ។ ហើយសំណួរមួយទៀត ដែលខ្ញុំដាក់ជូនទៅលោក ថារីក ថាតើនឹងមានគម្រោងក្នុងការផ្តល់នូវប្រតិចារឹកនៅក្នុងអំឡុងពេលនៃនីតិវិធី? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបឋមនេះ សូមអញ្ជើញលោក ថារីក ឆ្លើយតបទៅនឹងសំណួរមេធាវីមុន ហើយចំណែកឯង

ពាក់ព័ន្ធនឹងសំណួរមកខាងអង្គជំនុំជម្រះ អង្គជំនុំជម្រះនឹងពិភាក្សារវាងចៅក្រមនៅក្នុងអង្គជំនុំជម្រះ ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ លោកប្រធាន យើងបានស្នើផ្ដល់ប្រតិចារឹកដល់ភាគីពាក់ព័ន្ធទាំងអស់ ។ ហើយជាការពិតណាស់ គឺថាយើងនឹងរៀបចំប្រព័ន្ធគ្រប់គ្រងឯកសារផងដែរ នៅក្នុង អ៊ីស៊ីស៊ីស៊ី របស់យើង ជាទូទៅគឺថានឹងដាក់បញ្ចូលទៅក្នុងហ្វូលឌ័ណាមួយ ដែលភាគីពាក់ព័ន្ធនឹងអាចទទួលយកបាន ។ ហើយផ្នែក--ទាក់ទងទៅនឹងការលុបចោលផ្នែកណាមួយនៃឯកសារហ្នឹង គឺថាយើងនឹងពិភាក្សាគ្នា អាស្រ័យទៅលើអ្វីដែលខាងអង្គជំនុំជម្រះគាត់សម្រេច ។ នេះជាប្រព័ន្ធដែលយើងបានរៀបចំរួចមកហើយ ហើយមានន័យថាហាក់ដូចជាការផ្ដល់ក្នុងលក្ខណៈជាស្វ័យប្រវត្តិដែរដល់ប្រតិចារឹក ដល់ភាគីនានាដែលមិនចាំបាច់ធ្វើសំណួមពរ ប្រសិនបើប្រព័ន្ធនេះដំណើរការបានល្អនោះ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោក ថារីក ហើយសូមអញ្ជើញលោក ហ្សង់ ម៉ាក ដែលលោកមាន បំណងចង់បំភ្លឺនូវសំណួរដែលពាក់ព័ន្ធជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ប្រហែលជាខ្ញុំនឹងមិននិយាយអ្វីបញ្ជាក់ថែមឲ្យបានច្បាស់ទៅលើអ្វី ដែលអ្នកស្រី ស្វូតហ្សីនស្គីបានលើកឡើងនោះទេ ខ្ញុំគ្រាន់តែចង់ធ្វើការរំឭកលើកឡើងថា ទាក់ទងទៅនឹងអ្វីដែលយើងពិភាក្សាគ្នាហ្នឹង គឺថាយើងមានឯកសារហ្នឹងជាបីប្រភេទគឺ៖

ទី១) គឺសវនាការប្រចាំថ្ងៃ កំណត់ហេតុសវនាការប្រចាំថ្ងៃ គឺថាកំណត់ហេតុជាលាយលក្ខណ៍អក្សរ ហើយនិងជាប្រតិចារឹក ហើយនិងការកត់ត្រាជាលក្ខណៈសោតទស្សន៍ ។ ហើយសំណើសម្រាប់ផ្នែកណាមួយ សម្រាប់ការផ្លាស់ប្ដូរផ្នែកណាមួយទៅលើប្រព័ន្ធ ទៅលើប្រតិចារឹកហ្នឹង គឺថាត្រូវដាក់មកជូនផ្នែកអង្គជំនុំជម្រះក្នុងរយៈពេល៣ថ្ងៃ បន្ទាប់ពីបានដាក់បញ្ចូលនៅកំណត់ត្រានៃសាលសវនាការនោះ។ អ៊ីចឹងនេះ គឺជានីតិវិធីដែលយើងមាននៅក្នុងវិធានផ្ទៃក្នុង ។ ខ្ញុំគ្រាន់តែចង់រំឭកតែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោក ហ្សង់ ម៉ាក ដែលបានបំភ្លឺលើចំណុចនេះ ។ ជាបន្តបន្ទាប់--បន្ទាប់ទៀត តើមានមេធាវីអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានចង់មានសំណួរ ឬក៏មានកត់សម្គាល់អ្វីពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់លោកប្រធានគ្រប់គ្រងតុលាការជាន់ខ្ពស់នេះទេ ? បើមិនមានទេ ខ្ញុំជូនវេទិកានេះទៅ

សហព្រះរាជអាជ្ញា តើលោកសហព្រះរាជអាជ្ញា តើមានសំណួរអ្វីចង់សួរ ឬចង់កត់សម្គាល់ពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់ខាងមន្ត្រីជាន់ខ្ពស់ ស៊ីអ៊ីមអេស នេះទេ?

សូមអញ្ជើញ លោក ពេទីត ។

**លោក រ៉ូប៊ីត ពេទីត៖**

សូមគោរពលោកប្រធាន! អ៊ីចឹងខ្ញុំមានសំណួរមួយចំនួន ទីមួយ ខ្ញុំនឹងលើកឡើងនូវសំណូមពរដល់ខាងអង្គជំនុំជម្រះដើម្បីធ្វើការបញ្ជាក់ឲ្យបានច្បាស់ថា ប្រសិនបើខ្ញុំបានយល់ដឹងច្បាស់លាស់ហ្នឹង គឺថាកំណត់ហេតុសាលសវនាការហ្នឹង ដែលខាងក្រឡាបញ្ជីជាអ្នកគ្រប់គ្រងហ្នឹង ហ្នឹងគឺជាភស្តុតាងនៃអត្ថបទនៃអ្វីរបស់សាលសវនាការ ។ អ៊ីចឹងការកែប្រែទៅលើកំណត់ត្រានេះ អាចធ្វើបានដោយ មានហេតុផលណាមួយ ដោយជាក់លាក់ជាពិសេសនេះ គឺទាក់ទងទៅនឹងប្រតិចារឹក ឬក៏ប្រព័ន្ធសោតទស្សន៍ ហើយនិងនីតិវិធី នៅក្នុងវិធាន៩៧ហ្នឹងត្រូវអនុវត្តតាម ។ អ៊ីចឹង តើនេះជាការយល់ដឹងត្រឹមត្រូវរបស់ខ្ញុំទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោក ហ្សង់ ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ខ្ញុំសូមបញ្ជាក់បន្តិចត្រង់ចំណុចនេះ អ៊ីចឹងកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ក្រឡាបញ្ជីនៅក្នុងអំឡុងពេលសវនាការ ។ អ៊ីចឹងនោះគឺមិនមែនជាប្រតិចារឹកពេញលេញនោះទេ ។ អ៊ីចឹងសេចក្តីថ្លែងការណ៍ពេញលេញ ឬក៏របាយការណ៍ពេញលេញពិតប្រាកដនោះ គឺនឹងមាននៅក្នុងប្រតិចារឹកតែប៉ុណ្ណោះ ហើយវាមានប្រភេទផ្សេងៗគ្នាផងដែរ ។ នៅក្នុងវិធាន៩៧ បាននិយាយថារបាយការណ៍សវនាការប្រចាំថ្ងៃ ដែលបានព្រាងឡើងដោយក្រឡាបញ្ជីនោះ គឺជាកំណត់ត្រាត្រឹមត្រូវ ប៉ុន្តែបើសិនជាមានចំណុចណាមួយត្រូវការកែប្រែ នឹងអាចធ្វើបានទៅលើកំណត់ហេតុនោះ ឬក៏ប្រតិចារឹក ឬក៏កំណត់ហេតុជាសោតទស្សន៍ ។ អ៊ីចឹងអត្ថបទនឹងវាមានន័យគ្រប់គ្រាន់ហើយ ។

**លោក រ៉ូប៊ីត ពេទីត៖**

*(គ្មានការបកប្រែ៩:២២:៤២-៩:២២:៥៩ )*

ខ្ញុំចង់និយាយថា ខ្ញុំអាចយល់ដឹងច្បាស់លាស់ពីអ្វីដែលលោកបាននិយាយ អ៊ីចឹងប្រតិចារឹកដែលលោកបានរៀបចំហ្នឹងឯង គឺនឹងមានសម្រាប់ភាគីពាក់ព័ន្ធទាំងអស់នៅពេលដែលប្រតិចារឹកហ្នឹងបានរួច

ឯកសារដើម

រាល់ពិតប្រាកដហើយនោះឬ? ហើយនិងបានបញ្ចូលទៅក្នុងប្រព័ន្ធ?

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ជាដំបូងបង្អស់ អ៊ីចឹងទាក់ទងនឹងខាងផ្នែកបច្ចេកទេសហ្នឹង គឺអាចធ្វើទៅបាន ក៏ប៉ុន្តែយើងត្រូវពិភាក្សាបន្ថែមទៀត ហើយបន្ទាប់មកទៀតយើងនឹងផ្តល់នូវចម្លើយដល់លោក ។

**លោក រ៉ូបឺត ពេទីត៖**

ខ្ញុំមានសំណួរពីរបីទៀត ដែលខ្ញុំចង់សួរទៅខាងផ្នែកគ្រប់គ្រងតុលាការ យើងបានឮកាលពីម្សិលមិញថាភស្តុតាងទាំងអស់ ដែលយើងមាន ដែលនឹងត្រូវយកមកបង្ហាញនៅក្នុងសវនាការដោយភាគីពាក់ព័ន្ធណាមួយនោះ ប្រសិនបើអង្គជំនុំជម្រះឯកភាពនោះ មានន័យថានឹងបញ្ចូលទៅក្នុងសំណុំរឿងនោះមែនទេ? មានន័យថាជាសំណុំរឿងថ្មីមួយ លេខ៣ឬ? អ៊ីចឹងមានន័យថា បើសិនជាអ៊ីចឹងមែនខ្ញុំមានន័យថា យើងនឹងមានលេខថ្មីមួយ ដូចជាថា០០៣ជាដើម ។

ប្រសិនបើអង្គជំនុំជម្រះហ្នឹងឯងចង់ធ្វើបន្តនីតិវិធី ទាក់ទងទៅនឹងភស្តុតាងទាំងនោះ តាមរយៈប្រព័ន្ធ មានន័យថា នៅពេលដែលគេបានស្កេន ឯកសារអស់ហ្នឹងហើយ ជាជាងការយកឯកសារផ្ទាល់មកនោះ អ៊ីចឹងតើមានលទ្ធភាពអ្វីមួយដែលយើងធ្វើការធានាថាយើងទាំងអស់គ្នា គឺថាអាចមើលទៅលើអេក្រង់ដូចគ្នា ហើយអាចធ្វើការពិភាក្សា ឬក៏តវ៉ា ហើយសម្រេចដោយខាងអង្គជំនុំជម្រះ ថាតើភស្តុតាងហ្នឹងមានការទទួលស្គាល់ត្រឹមត្រូវពិតប្រាកដនៅក្នុងកំណត់ហេតុឬក៏យ៉ាងម៉េច? ឧទាហរណ៍៖ បើភាគីណាមួយបានយកឯកសារមួយនៅលើអេក្រង់របស់យើង ជាចម្លើយសារភាព យើងបានពិភាក្សាគ្នាទៅលើចម្លើយសារភាពនោះ ពេលហ្នឹងអង្គជំនុំជម្រះបានឯកភាពថា-- បើអ៊ីចឹងទំព័រទី១ ទី២ ទី៣ហ្នឹង គឺវាមានពាក់ព័ន្ធ អ៊ីចឹងយើងអាចចាត់ទុកថានេះមានលេខថ្មី គឺ *E00១* ឧទាហរណ៍ ចុះថាតើមាននីតិវិធីណាមួយដែលឯកសារពាក់ព័ន្ធនេះ នឹងត្រូវការកត់ត្រាទុកក្នុងកំណត់ហេតុដោយខាងផ្នែកគ្រប់គ្រងតុលាការនេះជាផ្នែកមួយនៃសំណួររបស់ខ្ញុំ ។

ថាតើខាង លោក ថារីក អាចធ្វើដូច្នេះបានទេ? បើខ្ញុំយល់ថា អាចធ្វើអ៊ីចឹងបាន គឺវាប្រយោជន៍ណាស់ដល់ភាគីពាក់ព័ន្ធទាំងឡាយក្នុងការគ្រប់គ្រងទៅលើចំណុចនេះ ហើយទាក់ទងទៅហ្នឹងវិធានការការពារទៅលើប្រព័ន្ធសោតទស្សន៍ កំណត់ត្រាសោតទស្សន៍ផងដែរ ។ មានន័យថាអ្វីដែលខាងសាធារណជនបានឃើញបានឮនុំង ថាតើខាងអង្គជំនុំជម្រះហ្នឹងឯង គាត់នឹងដាក់វិធានការការពារណាមួយនៅក្នុងអំឡុងពេលសវនាការនោះ មានន័យថា អាចជាប្រយោជន៍ណាស់ដល់ភាគីពាក់ព័ន្ធទាំងឡាយ?

ចំណុចទី៣ ទាក់ទងទៅនឹងចំណុចបច្ចេកទេសបំផុតនោះ ខ្ញុំនៅគិតថាប្រតិចារឹកដែលបានផ្តល់នុំង យ៉ាងហោចណាស់សេចក្តីព្រាងនៃប្រតិចារឹកនោះ នឹងអាចជាអត្ថប្រយោជន៍បំផុត ប្រសិនបើសិនអាចធ្វើបាននៅក្នុងទម្រង់ជា វីត ដែលមានន័យថាយើងអាចធ្វើការរុករកបាននៅក្នុងប្រព័ន្ធប្រតិចារឹកនោះ បើសិនជាប្រព័ន្ធជា*ភីឌីអេហ្វ*នោះ វាពិបាកបន្តិច ។ អ៊ីចឹងមានន័យថា ប្រតិចារឹកចុងក្រោយអាចជាទម្រង់ *ភីឌីអេហ្វ* ប៉ុន្តែសម្រាប់សេចក្តីព្រាងនោះ គឺគួរតែធ្វើក្នុងទម្រង់ជា វីត សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ចារី ឆ្លើយតបនឹងសំណួរ ឬបកស្រាយនូវបញ្ហាពាក់ព័ន្ធនឹងសំណួរនេះបាន។

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំប្រហែលជាអាចឆ្លើយតបទៅនឹងសំណួរទាក់ទងទៅនឹងបច្ចេកទេសមុន បន្ទាប់មកទៀតយើងអាចនិយាយពីវិធានការការពារសាក្សី និងហើយលទ្ធភាពរបស់យើង ។ អ៊ីចឹងទាក់ទងទៅនឹងសំណួរចុងក្រោយបង្អស់នោះ គឺថាមានន័យថា ប្រតិចារឹកនឹងផ្តល់ជាទម្រង់*វីតហ្វ័រម៉េត* ខ្ញុំមិនបានពន្យល់ពីមុនមក ។ អ៊ីចឹងដូចខ្ញុំនិយាយអ៊ីចឹងម្តងទៀត គឺមានន័យថាទម្រង់ វីតហ្វ័រម៉េត ហើយភាគីទាំងអស់អាចចម្លងចេញបាន ។ ហើយនៅពេលដែលប្រតិចារឹកចុងក្រោយចេញនុំងឯង គឺនឹងមានជាទម្រង់មួយដែលមិនអាចធ្វើការកែប្រែបាន ។ អ៊ីចឹងសេចក្តីព្រាងហ្នឹង គឺអាចកែសម្រួលបាន ឬក៏អាចចម្លងបាន ។

អ៊ីចឹងទាក់ទងទៅនឹងឯកសារដែលបង្ហាញទៅក្នុងសវនាការនោះ គឺខ្ញុំអាចនឹងប្រើជាលក្ខណៈពាក្យបច្ចេកទេស ប្រហែលជាខ្ញុំមិនអាចពន្យល់បានជាលម្អិតនោះទេ ។ គឺថាយើងបានរៀបចំនូវប្រព័ន្ធមួយជាមួយនឹងក្រឡាបញ្ជីនៅក្នុងអង្គជំនុំជម្រះសវនាការ គឺទាក់ទងទៅនឹងឯកសារដែលយកមកបង្ហាញនៅក្នុងតុលាការនោះ ទាក់ទងទៅនឹងវិធានការក្នុងការអនុវត្ត ក្នុងការដាក់ពាក្យ ឬក៏ដាក់សំណុំឯកសារហ្នឹង គឺថាត្រូវអនុវត្តតាម ហើយនិងទាក់ទងទៅនឹងចំណុចបច្ចេកទេសខ្លះទាក់ទងទៅនឹងឯកសារទាំងនោះផងដែរ ដែលខាងផ្នែកចៅក្រមស៊ើបអង្កេតគាត់ដាក់ជូននោះ ឬដាក់បញ្ជូនមកនៅក្នុងអង្គជំនុំជម្រះ ។

អ៊ីចឹងទាក់ទងនឹងផ្នែកបច្ចេកទេសនេះ គឺថាមានជម្រើសពីរបីផ្សេងៗ ដែលយើងអាចធ្វើការជ្រើសរើស ទាក់ទងទៅនឹងឯកសារដែលជារូបរាង ដែលអាចត្រូវការបញ្ជូនពីផ្នែកចៅក្រមស៊ើបអង្កេតមកខាងអង្គជំនុំជម្រះនេះ ។ មានន័យថា ឯកសារហ្នឹងនឹងត្រូវបញ្ជូន ប៉ុន្តែលេខយោង លេខអីហ្នឹង គឺថា

វាមាននៅការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ ។ នៅពេលដែលឯកសារត្រូវបានផ្ទេរមកខាងអង្គជំនុំជម្រះនោះ ពេលហ្នឹងឯកសារហ្នឹងជាឯកសារដើម ហើយឯកសារចម្លង គឺថានៅរក្សាទុកជាមួយខាងនៅការិយាល័យចៅក្រមស៊ើបអង្កេតដដែរ ។

អ៊ីចឹងឯកសារហ្នឹងឯង គឺថាមានពីរហើយ មានលេខពីរយោងផ្សេងគ្នា បើសិនជាឯកសារហ្នឹងចេញពីសំណុំរឿងលេខទី១ គឺថាមានលេខយោងទី១ គឺមានស្រាប់ហើយ ចេញពីខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកទៀតនឹងលេខយោងថ្មីដែលមានចេញជាលេខ អ៊ី៣ ហ្នឹងឯងនឹងអាចនឹងចេញសម្រាប់ខាងផ្នែកអង្គជំនុំជម្រះ ហើយឯកសារហ្នឹងគឺយើងអាចរុករកនៅក្នុងប្រព័ន្ធណាមួយនៃប្រព័ន្ធទាំងពីរនេះក៏ដោយ ។

ចំណុចចុងក្រោយ គឺថាទាក់ទងទៅនឹងថាតើ-- តើលេខយោងពិតប្រាកដយើងកត់ត្រាទុកយ៉ាងម៉េច? នេះជាអ្វីដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងនោះ ។ គឺថាអ្វីដែលយើងមើលឃើញទស្សន៍ទាយទៅខាងមុខនោះ គឺថាយើងនឹងមានកំណត់ត្រាប្រចាំថ្ងៃ នៅក្នុងរបាយការណ៍ប្រចាំថ្ងៃគឺថា យើងយោងទៅលើឯកសារដែលបានបង្ហាញនៅថ្ងៃណាមួយនៃសវនាការនោះ ។ ហើយលេខយោងនឹងឯង គឺនឹងមាននៅក្នុងប្រតិចារឹកផងដែរ ។ ដូច្នេះហើយ គឺថាអាចនឹងជាវិធីមួយសម្រាប់ឲ្យយើងយល់ដឹងបានអំពីការរុករកឯកសារ ឬក៏ឯកសារដែលបានបង្ហាញនោះ ។

ហើយទាក់ទងទៅនឹងការការពារសាក្សី ហើយនិងលទ្ធភាពរបស់យើងនៅក្នុងតុលាការ អ៊ីចឹងជាទូទៅប្រព័ន្ធការពារតុលាការ ប្រព័ន្ធការពារសាក្សីរបស់យើងនឹងឯង គឺប្រហាក់ប្រហែលគ្នាទៅនឹងប្រព័ន្ធដទៃទៀត ដែលមាននៅក្នុងពិភពលោកយើងនេះ ។ គឺថាយើងអាចមានលទ្ធភាព និងមានអត្តសញ្ញាណរបស់សាក្សី ហើយកំណត់អត្តសញ្ញាណផ្សេងៗគ្នា ។ អ្វីដែលមាននៅក្នុងសាលសវនាការនេះគឺជាវិធានសាមញ្ញមួយដែលកើតមានឡើង មានន័យថា យើងអាចមានការពារសាក្សីដែលទទួលបានការការពារហ្នឹងឯង មិនឲ្យសាធារណជនបានឃើញ ។ មានន័យថាគាត់អាចផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការនៅក្នុងកន្លែងដែលសាក្សីអង្គុយ ប៉ុន្តែអាចការពារពីសាធារណជនបានតាមវិធានពីរ មានន័យថា គឺថាបាំងមិនឲ្យខាងសាធារណជនបានឃើញ ដាក់នៅខាងពីក្រោយខ្នងសាក្សី មានន័យថា បិទបាំងមិនឲ្យសាធារណជនបានឃើញ ។ ប៉ុន្តែ អ្នកដែលចូលរួមនៅក្នុងសវនាការ បន្ទប់សវនាការ គឺអាចមើលឃើញសាក្សីនោះបានច្បាស់ ។

នៅក្នុងពេលដំណាលគ្នានោះផងដែរ សំឡេងរបស់សាក្សី ហើយនិងមុខរបស់សាក្សី ដែលថា

00286066



យើងមានកត់ត្រានៅក្នុងប្រព័ន្ធនោះ គឺថាអាចធ្វើការកែប្រែបាន ។ ហើយនៅក្នុងសាលសារធារណជនហ្នឹងឯង គឺអាចឮ ឬក៏មើលឃើញអ្វីយើងបានធ្វើការសម្រួលតែប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកដែលចូលរួមនៅក្នុងបន្ទប់សវនាការ គឺអាចឮ ឃើញសំឡេងពិតប្រាកដ ឃើញមុខពិតប្រាកដបាន ។ ហើយនៅលើអេក្រង់នៅក្នុងសាលសាធារណៈហ្នឹង គឺថានឹងឃើញតែរូបភាពដែលយើងបានធ្វើការកែប្រែ ឬក៏សំឡេងដែលយើងធ្វើការកែប្រែតែប៉ុណ្ណោះ ។

នៅក្នុងអំឡុងពេលនៃនីតិវិធីបែបនោះ មានន័យថា នេះជាវិធានការមួយដែលយើងធ្វើការការពារសាក្សី ។ អ៊ីចឹង កម្រិតមួយទៀតបន្ទាប់សម្រាប់ការការពារសាក្សី នៅពេលនុំងឯងដែរ គឺថាអាចធ្វើឲ្យសាក្សីហ្នឹងផ្តល់សក្ខីកម្មពីចម្ងាយ តាមរយៈប្រព័ន្ធពីរ មានន័យថា អាចធ្វើបាននៅក្នុងទីតាំងតុលាការនេះ ប៉ុន្តែមិនមែននៅក្នុងសាលសវនាការផ្ទាល់ ។ ហើយគឺថាយើងអាចផ្តល់នូវមធ្យោបាយដូចគ្នានឹងអ្វីដែលយើងបានពន្យល់មុននឹងឯង ។ មានន័យថា អ្នកចូលរួមនៅក្នុងសាលសវនាការអាចមើលឃើញគាត់បាន ប៉ុន្តែសារធារណជនមិនអាចមើលឃើញគាត់បានទេ ។

អ៊ីចឹងសមត្ថភាពហ្នឹង លទ្ធភាពហ្នឹងឯងគឺថាយើងមាន នៅក្នុងទីតាំងនេះ តុលាការយើងនេះ ឬក៏អាចចូលរួមពីប្រយោល គឺថានៅក្នុងប្រទេសខ្មែរ ឬក៏នៅពីបរទេសមកជាដើម ។

អ៊ីចឹង នេះគឺជាប្រភេទផ្សេងៗគ្នានៃវិធានការការពារសាក្សីដែលយើងមាន សម្រាប់សាក្សីដែលផ្តល់សក្ខីកម្មពីចម្ងាយហ្នឹងឯងគឺជាផ្នែកមួយនៃវិធានការការពារសាក្សីផងដែរ ដើម្បីការពារអត្តសញ្ញាណរបស់សាក្សីនោះឯង ។ ទៅតាមបទពិសោធន៍របស់យើង នេះគឺជាអ្វីដែល-- គឺជាទម្រង់ដែលយើងអាចប្រើបាន ហើយនឹងមិនមែនជាការគំរាមកំហែងទៅលើសាក្សីនោះទេ ។

យើងអាចធ្វើការបង្ហាញអំពីចំណុចនេះបាន ប្រសិនបើអស់លោក លោកស្រីចង់ឃើញ បន្ទាប់ពីយើងឈប់សម្រាកនោះ ។ យើងអាចនឹងធ្វើការបង្ហាញរយៈពេលខ្លីមួយ បើសិនជាយល់ថាជាការចាំបាច់ និងមានប្រយោជន៍ដល់អស់លោក លោកស្រី ។ ខ្ញុំនឹងបង្ហាញថាតើរបៀបវិធីហ្នឹងឯងយើងអនុវត្តបានយ៉ាងដូចម្តេច ។ បើមិនអ៊ីចឹងទេ បើភាគីណាមួយ ឬក៏ភាគីចូលគ្នាណាមួយដែលចង់ស្នើឲ្យធ្វើការបង្ហាញ ខ្ញុំអាចបង្ហាញជូនបាន ។

**ប្រធានអង្គប្រជុំ៖**

សូមអរគុណ លោក ថារីក ដែលបានឆ្លើយបំភ្លឺលើចំណុចនេះ ។

មានបញ្ហាអ្វីទៀតទេ លោកសហព្រះរាជអាជ្ញា?

00286067



សូមអញ្ជើញ លោកស្រី ជា លាង ។

**លោកស្រី ជា លាង៖**

សូមអរគុណ លោកប្រធាន ។

ដោយសារសំណួរនេះវាអាចពាក់ព័ន្ធទៅខាងអង្គជំនុំជម្រះផង ឬក៏អាចទៅខាង ស៊ីអ៊ឹមអេស ក៏ថាបានដែរ ។ ខ្ញុំមានចង្ងល់អ៊ីចេះ ដោយសារនៅពេលដែលសវនាការ យើងមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ ហើយនិងមានប្រតិចារឹក ។ ដូច្នេះ ខ្ញុំគិតថាពីរហ្នឹង តើមួយណាវាមានតម្លៃជាង? នេះជាសំណួរទីមួយ ។

ហើយ សំណួរទីពីរ ខ្ញុំគិតថាប្រសិនណាបើកំណត់ហេតុជាលាយលក្ខណ៍អក្សរ វាមានលក្ខណៈផ្ទុយគ្នានឹងប្រតិចារឹក តើនីតិវិធីខាងអង្គជំនុំជម្រះនឹងសម្រេចនីតិវិធីដោះស្រាយដោយរបៀបម៉េច?

សូមអរគុណ ។

**ប្រធានអង្គប្រជុំ៖**

អញ្ជើញ លោក ហ្សង់ ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ខ្ញុំអត់មាន មាត្រា ៩៧ នៃវិធានក្នុងទេ ប៉ុន្តែអ្វីដែលខ្ញុំចង់បាន មានន័យថា មានការបង្ហាញយ៉ាងច្បាស់ថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនោះឯង គឺជាកំណត់ហេតុជាផ្លូវការ លើកលែងតែមានការលើកអ្វីផ្ទុយពីនេះ ។ ឧទាហរណ៍ថា មានន័យថានៅពេលដែលប្រតិចារឹកដែលអាចជាចំណុចបន្ថែមដោយបានមើលទៅលើវីដេអូនៃការថតពេលសវនាការនោះ ។

អ៊ីចឹង គឺថាមានយន្តការមួយដែលយើងបានព្រាងទុក សម្រាប់ការកែសម្រួលទៅលើប្រតិចារឹក អ៊ីចឹងគឺនៅក្នុងវិធាន៩៧.៤ បានផ្តល់នូវ ចំណុចដែលថាត្រូវធ្វើសំណើមកខាងសាលសវនាការហ្នឹង នៅពេលដែលចង់ធ្វើឲ្យមានការប្រែប្រួលអ្វីមួយនោះ ។ ហើយមានន័យថា រយៈពេលកំណត់នោះ គឺរយៈពេលបីថ្ងៃ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកចៅក្រម ។

ជាបន្តទៀត សូមអញ្ជើញមេធាវីការពារជនជាប់ចោទ មានអ្វីចង់សួរ ឬក៏មានការកត់សម្គាល់អ្វីទេ ចំពោះបទបង្ហាញរបស់ខាងមន្ត្រីជាន់ខ្ពស់ ស៊ីអ៊ឹមអេស នេះ?

00286068



សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។

អរុណសួស្តី! ចាប់តាំង-- នៅពេលដែលខាងផ្នែកគ្រប់គ្រងតុលាការបានធ្វើការបង្ហាញទុំងឯង គឺថាខ្ញុំចង់សួរបន្តិចថា តើមានការព្យាករណ៍ទុកថា ថាតើយើងមានកញ្ចក់បិទបាំងហ្នឹងមួយ ឬក៏ពីរ ឬក៏យ៉ាងម៉េច? ថាតើនឹងមានការរៀបចំអេក្រង់សម្រាប់ឲ្យពួកយើងមើលនៅតាមកន្លែងដែលយើងអង្គុយនីមួយៗទេ ដើម្បីភ្ជាប់ជាមួយប្រព័ន្ធកុំព្យូទ័រនោះ? នេះជាចំណុចដែលខ្ញុំចង់សួរ ។

សូមអរគុណ ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ លោកប្រធាន សម្រាប់សំណួរនេះ ។

យើងនឹងផ្តល់នូវអេក្រង់បន្ថែមទៀត ។ អ៊ីចឹង យើងក៏អាចពិភាក្សាបន្ថែមទៀតដែរទាក់ទងទៅលើចំណុចនេះជាមួយភាគីពាក់ព័ន្ធនានា ទាក់ទងទៅនឹងតម្រូវការ គឺថាយើងមានលទ្ធភាពមួយចំនួនដើម្បីផ្តល់ការទទួលបាននូវកុំព្យូទ័រនៅក្នុងសាលសវនាការនេះ ។ ហើយ គឺថាអាចភ្ជាប់ផងដែរទៅនឹងបណ្តាញប្រព័ន្ធ*នេតវើក* ដូចថាយើងអាចចូលទៅក្នុង*ខេសហ្វាល*បាន ។ នេះគឺជាអាស្រ័យទៅលើសេចក្តីសម្រេចចិត្តរបស់ខាងអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

អ៊ីចឹង ខ្ញុំមានមតិយោបល់មួយ ។

សម្រាប់លោកដែលនិយាយភាសាបារាំងនោះ អ៊ីចឹងតើយើងត្រូវការដូចថា *ឃើប៊ីត* ជាភាសាបារាំងដែរ ឬក៏យ៉ាងម៉េចហ្នឹង?

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវី លោកស្រីមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

**លោកស្រី ម៉ាទីន ហ្សាកហ្សីន៖**

សូមអរគុណ លោកប្រធាន ។

មុននឹងយើងនិយាយទាក់ទងទៅនឹងចំណុចមួយទៀតនៅក្នុងរបៀបវារៈហ្នឹង ខ្ញុំចង់និយាយបន្តិចទាក់ទងអំពីនីតិវិធី សម្រាប់ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថាតើដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ទទួលបានការការពារដូចជាសាក្សីដែលត្រូវទទួលបានការពារតាមវិធានការការពារដែរនោះទេ? ឧទាហរណ៍ដូច មានន័យថាការផ្តល់សក្ខីកម្មពីចម្ងាយ ឬក៏យ៉ាងម៉េចនោះ?

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោក ហ្សង់ ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

វិធានផ្ទៃក្នុងទាក់ទងទៅនឹងចំណុចនេះ គឺច្បាស់ណាស់ គឺថាដើមបណ្តឹងរដ្ឋប្បវេណីក៏អាចបានទទួលនូវអត្ថប្រយោជន៍នេះផងដែរ អាស្រ័យទៅការវាយតម្លៃទៅលើហានិភ័យនានា ទាក់ទងទៅនឹងវិធានការការពារ ដែលមានចំណុចប្រហាក់ប្រហែលគ្នាទៅនឹងសាក្សីផងដែរ ។

**លោកស្រី ម៉ាទីន ហ្សាកហ្វីន៖**

តើខ្ញុំអាចធ្វើការទទូចដោយសារថា នៅចំណុចខាងក្រោមតើលោកអាចបញ្ជាក់បានទេ មានន័យថាតើដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការផ្តល់សក្ខីកម្មពីចម្ងាយបានទេ? ចំណុចគឺទាក់ទងទៅនឹងការវាយតម្លៃទៅលើហានិភ័យទៅលើដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនោះ ។

ខ្ញុំគិតថា មិនមានការកំណត់ ឬក៏កម្រិតអ្វីមួយទៅលើវិសាលភាពនៃវិធានការការពារ ដែលអាចត្រូវអនុវត្តបាននោះទេ ។

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់ លោក ថារីក អម្បាញ់មិញមិញនេះ ខ្ញុំមានចំណាប់អារម្មណ៍មួយដែលលោកបានលើកឡើងថា មានការប៉ុនប៉ង បង្ហាញជារបាំងការពារសាក្សីនៅក្នុងសាលសវនាការ ហើយនៅក្នុងអំឡុងពេលនៃសម្រាក ឈប់សម្រាកនេះ ហើយបើមានសមាជិក សមាជិកានៃអង្គពិធី ឬក៏ភាគីដែលប៉ុនប៉ងចង់មើលអាចមើលបាន បើសិនជាមានការមូលមាត់គ្នា ឯកភាពគ្នាថាយើងសុំឱ្យខាងគ្រប់គ្រងធ្វើដូច្នេះ ។ មានទេ? មានបំណងឱ្យខាងស៊ីអឹមអេសបង្ហាញអំពីរបៀបអំពីបែបផែននៃការការពារសាក្សីក្នុងសាលសវនាការទេ?

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

ឯកសារដើម

សូមអញ្ជើញ លោក ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមគោរព លោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូង ។

ខាងខ្ញុំបាទជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចង់បាន-- ចង់ឃើញតាមការលើកឡើងរបស់ លោក ថាវីក អម្បាញ់មិញមិញនេះដែរ ។

**ប្រធានអង្គជំនុំ៖**

ខាងអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាចង់ឃើញដែរ ដោយកន្លងមក គឺអាចមើលឃើញតែខ្ញុំទេ ដែលបានចូលរួមម្ដង ហើយអ្នកផ្សេងទៀតមិនទាន់បានឃើញនៅឡើយទេ ។

អ៊ីចឹងគឺទទួលនូវ-- សុំឲ្យខាងស៊ីអឹមអេសហ្វ៊ីង ធ្វើការ១បង្ហាញនូវរបៀបនៃការការពារសាក្សីក្នុងសាលសវនាការ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកខាងមុខនេះ ។ អ៊ីចឹង ខាងលោក ថាវីក ចាំគ្រោងដើម្បីរៀបចំបញ្ហានេះ ។

ជាបន្តមកទៀត ដល់របៀបវារៈបន្ទាប់គឺបញ្ហាជាក់ស្ដែងស្ដីពីការផ្ដល់សេវាកម្មបកប្រែផ្ទាល់មាត់ បកប្រែឯកសារ ។ ហើយនៅក្នុងរបៀបវារៈនេះត្រូវបង្ហាញដោយផ្នែកអ្នកប្រែភាសាផ្ទាល់មាត់ បកប្រែឯកសា ។ ហើយក៏នឹងមានកិច្ចពិភាក្សាដែរ ដោយសារហេតុផលនៃបញ្ហានេះ គឺដូចមានអាទិភាពនៅក្នុងគ្រប់ដំណាក់កាលកន្លងមកនេះ ដែលមានបញ្ហាពិតប្រាកដ ។

ដូច្នេះគឺ យើងខ្ញុំសូមអញ្ជើញ អ្នកសម្របសម្រួលជាន់ខ្ពស់នៃផ្នែកបកប្រែភាសាផ្ទាល់មាត់ បកប្រែឯកសារ ដើម្បីឡើងធ្វើបទបង្ហាញត្រួសៗអំពីបច្ចុប្បន្នភាពនៃបញ្ហាជាក់ស្ដែង បញ្ហាផ្សេងទៀត ដូចជា ខ្វះបុគ្គលិក ឬក៏ពាក់ព័ន្ធទៅនឹងបញ្ញត្តិនៃសេវាកម្មបកប្រែផ្ទាល់មាត់ បកប្រែឯកសារ ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះ ។ ហើយពេលវេលា គឺសូមធ្វើក្នុងរង្វង់ម្ភៃនាទី ។

អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថាឆ្លងតាមទំនាក់ទំនងគ្នា តាមរយៈសំណោរកាលពីថ្ងៃទីម្ភៃបួន ខែធ្នូ ពីរពាន់ប្រាំបី មេធាវីការពារក្ដីឲ្យជនជាប់ចោទបានបញ្ជាក់ថា ខ្លួនមានបំណងចង់សួរនៅថ្ងៃនេះអំពីស្ថានភាពបកប្រែភាសាចំពោះឯកសារដែលត្រូវយកមកប្រើប្រាស់ក្នុងអង្គជំនុំជម្រះផងដែរ ។ នេះគឺជាសុំចំណាប់អារម្មណ៍នៅខាងមន្ត្រីជាន់ខ្ពស់ដែលត្រូវបង្ហាញពីបញ្ហានេះ ។ ហើយ ខ្ញុំសូមអញ្ជើញ សូមអញ្ជើញមន្ត្រីជាន់ខ្ពស់ខាងបកប្រែភាសា សូមធ្វើបទបង្ហាញ ។

**លោកស្រី មីសែល ឃីតធីង៖**

អរុណសួស្តី លោកប្រធាន និងលោកចៅក្រមទាំងអស់! ខ្ញុំឈ្មោះ មីសែល ឃីតធីង ហើយខ្ញុំគឺជាមន្ត្រីជាន់ខ្ពស់ក្នុងផ្នែកគ្រប់គ្រងផ្នែកអ្នកប្រែ និងផ្ទាល់មាត់ និងឯកសារ ហើយលោក សុភី ក៏ជាអ្នកគ្រប់គ្រងម្នាក់នៅក្នុងផ្នែកនេះ លោកនឹងធ្វើបទបង្ហាញជាបន្តពីខ្ញុំ ។ ហើយខ្ញុំនឹងចែកជូនលោកចៅក្រមទាំងអស់ និងភាគីអំពីបញ្ហាជាក់ស្តែងមួយចំនួនទាក់ទងជាមួយនឹងការបកប្រែភាសាផ្ទាល់មាត់ និងបកប្រែឯកសារ ។

ហើយនៅថ្ងៃនេះគឺ ខ្ញុំចង់ជម្រាបផងដែរទាក់ទងជាមួយបញ្ហាពាក់ព័ន្ធជាមួយនីតិវិធីនៃអង្គជំនុំជម្រះតែម្តង ។ ហើយក្នុងពេលជាមួយគ្នានេះដែរ ខ្ញុំត្រៀមខ្លួននឹងឆ្លើយសំណួរផ្សេងៗដែលគូភាគីដែលចង់លើក ។ ហើយផ្នែកដំបូងនៃកិច្ចបង្ហាញរបស់ខ្ញុំនេះគឺ ខ្ញុំនឹងបង្ហាញចំណុចមួយចំនួន ហើយក្រោយមកខ្ញុំនឹងជូនវេទិកានេះទៅលោក សុភី ដែលលោកនឹងឡើងមកបកស្រាយបំភ្លឺបន្ថែម អំពីបញ្ហាជាក់ស្តែងមួយចំនួនទៀតរឿងផ្នែកបកប្រែឯកសារ ។ ហើយខ្ញុំនឹងផ្តល់វេទិកានេះផងដែរ ដើម្បីមានសំណួរឬក៏ការសុំសួរបំភ្លឺបន្ថែម បើសិនជាខ្ញុំបកស្រាយមិនទាន់អស់ ។

ទាក់ទងជាមួយនឹងបញ្ហាជាក់ស្តែងជាមួយនឹងបញ្ហាបកប្រែផ្ទាល់មាត់នេះនៅក្នុងបន្ទប់សវនាការនេះគឺ លោកដឹងហើយថាយើងនឹងមានការផ្តល់ការបកប្រែផ្ទាល់មាត់បណ្តោញពីជាបីភាសា បើសិនជាលោកមើលទៅខាងក្រោយ នៅខាងលើនោះលោកនឹងឃើញបន្ទប់បកប្រែចំនួនបី ហើយលោកនឹងឃើញអ្នកប្រែកំពុងតែបកប្រែ ។ ក៏ប៉ុន្តែឥឡូវនេះ យើងមានអ្នកបកប្រែពីរនៅក្នុងតែមួយ និងបន្ទប់មួយទៀតក៏មានអ្នកបកប្រែពីរនាក់ដែរ ។

ហើយនេះគឺជាអ្វីដែលយើងកំពុងតែរៀបចំក្នុងពេលបច្ចុប្បន្ននៅក្នុងតុលាការ ដើម្បីឱ្យយើងអាចផ្តល់សេវាកម្មនេះឱ្យបានពេញលេញ គឺយើងត្រូវការអ្នកបកប្រែផ្ទាល់មាត់បន្ថែមទៀត ។ ហើយយើងមានគម្រោងនឹងជួលបន្ថែម រើសបន្ថែមនូវបុគ្គលិកសម្រាប់ធ្វើការងារនេះ ហើយនៅអាទិត្យក្រោយយើងនឹងមានអ្នកបកប្រែបរទេសម្នាក់ទៀតមកជួយ ហើយនៅខែក្រោយយើងនឹងរើសបន្ថែមទៀត ។ ហើយលោក សុភី លោកនឹងលើកឡើងអំពីកិច្ចការរើសបុគ្គលិកថ្មីនៅខែកុម្ភៈ ទាក់ទងជាមួយនឹងអ្នកបកប្រែស្រាប់ ។

ហើយស្របពេលឥឡូវនេះយើងមានតែអ្នកបកប្រែបួននាក់ទេ នៅក្នុងបន្ទប់បកប្រែនៅខាងលើនៅពេលឥឡូវនេះ ។ ហើយឥឡូវនេះ ដូចគណៈកម្មការនីតិវិធី និងវិធានកំពុងតែប្រជុំ យើងយកអ្នកបក

ប្រែយើងពីរនាក់បាននៅប្រចាំការនៅទីនោះទៅហើយ ។ ហើយនៅក្នុងនេះគឺ ខាងអង្គភាពបកប្រែនូវឯកសារ និងផ្ទាល់មាត់កំពុងតែព្យាយាមធ្វើអាទិភាពទៅលើការផ្តល់សេវាកម្មបកប្រែទៅដល់ផ្នែកខាងតុលាការឲ្យធ្វើបាន ។ ហើយទាក់ទងជាមួយនឹងសំណើបកប្រែផ្សេងៗទៀត គឺយើងក៏កំពុងតែរៀបចំពិនិត្យមើលទៅតាមហ្នឹងដែរ ប៉ុន្តែក្នុងពេលសព្វថ្ងៃនេះ គឺយើងមិនទាន់មានលទ្ធភាពដើម្បីនឹងអាចផ្តល់អ្នកបកប្រែឲ្យនៅក្នុងព្រឹត្តិការណ៍ជាន់គ្នាពីរដង-- ពីរនៅក្នុងពេលតែមួយបាននៅឡើយទេ ព្រោះយើងខ្វះបុគ្គលិក ។

ហើយទាក់ទងជាមួយនឹងបុគ្គលិកខ្មែរនិងបុគ្គលិក-- នេះគឺយើងមានអ្នកបកប្រែម្នាក់ដែលលោកនឹងមកជួយលោកចៅក្រមនៅក្នុងអង្គជំនុំជម្រះ បើសិនជាលោកចៅក្រមចង់ពិគ្រោះយោបល់អ្វីខ្លីៗ ហើយត្រូវការគាត់បកប្រែពីអង់គ្លេសទៅខ្មែរ ខ្មែរទៅអង់គ្លេស នោះគាត់បានឡើងបង្ហាញខ្លួនចំពោះមុខលោកចៅក្រមអម្បាញ់មិញមិញហើយ ។

ហើយយើងមិនមានអ្នកបកប្រែភាសាបារាំងខ្មែរ ខ្មែរបារាំងជួយលោកចៅក្រមនៅឡើយទេ ។ ខ្ញុំសុំអធ្យាស្រ័យក្នុងពេលនេះ ។ ហើយបើសិនជាលោកចៅក្រមចង់ចូលទៅពិភាក្សាពិគ្រោះសម្រេចអីនោះ លោកចង់បានអ្នកបកប្រែនៅខាងលើឯណោះ ជួយសម្រួលក្នុងកិច្ចការពិគ្រោះយោបល់សម្រេចនេះ លោកអាចនឹងស្នើមកខាងយើងខ្ញុំដើម្បីឲ្យពួកគាត់ចុះមកក្រោម ដើម្បីជួយសម្រួលកិច្ចសន្ទនាគ្នានៅក្នុងកិច្ចពិភាក្សានេះ ។

ខ្ញុំក៏សូមជម្រាបផងដែរ គឺអ្នកដែលបកប្រែដែលអនុញ្ញាតឲ្យមកអង្គុយនៅក្នុងបន្ទប់បកប្រែនៅទីនេះគឺមានតែពួកគាត់ជាអ្នកបកប្រែប៉ុណ្ណោះ គឺមិនមានអ្នកផ្សេងដែលអាចអនុញ្ញាតឲ្យចូលទៅនឹងទីនុំងបានទេ ។

ហើយនៅក្នុងចំណុចមួយទៀត គឺខ្ញុំចង់ជម្រាបផងដែរថា អ្នកបកប្រែផ្ទាល់មាត់នេះ គឺយើងនឹងប្រើសម្គាល់អ្នកនិយាយនៅក្នុងសវនាការ ឬកិច្ចប្រជុំ ។ បានន័យថា គាត់-- យើងចង់-- បើអ្នកបកប្រែតែម្នាក់ឯង ហើយបកប្រែឲ្យលោកចៅក្រម ឬភាគីច្រើនខុសៗគ្នា អ៊ីចឹង អ្នកបកប្រែនឹងប្រើពាក្យសម្គាល់ថាឥឡូវនេះ គឺសម្តីរបស់លោកនេះ ឬក៏លោកនោះ ដើម្បីឲ្យអ្នកស្តាប់អាចតាមទាន់ និងក៏ឲ្យខាងធ្វើប្រតិចារឹកហ្នឹង លោកអាចកត់ទាន់បានផងដែរ ដើម្បីថាតើនេះគឺជាប្រសាសន៍របស់អ្នកណា ព្រោះអីអ្នកបកប្រែតែម្នាក់ឯង បកឲ្យលោកអ្នកគ្រប់គ្នានៅទីនេះ ។

ហើយ ខ្ញុំក៏សូមជម្រាបផងដែរការបកប្រែបណ្តោញនេះគឺ ជាទូទៅវាវែងជាងភាសាដើម អ៊ីចឹង

ទេ សុំឲ្យលោកចៅក្រមមេត្តាពិនិត្យផ្អាកបន្តិចផងដែរ ស្តាប់សំឡេងអ្នកបកប្រែផង បើសិនជាគាត់មិនទាន់ទេ លោកអាចផ្អាកដើម្បីទុកឱកាសឲ្យលោកអាចបកទាន់ ព្រោះនៅពេលដែលលោកចៅក្រម ឬក៏ភាគីដូរអ្នកនិយាយនៅក្នុងសវនាការ អ្នកបកប្រែក៏ត្រូវការពេលសម្រាក មកពេលយើងដូរគ្នានឹងផងដែរ បានន័យថា ទុកឲ្យគាត់បកប្រែឲ្យទាន់ ។ បើមិនអ៊ីចឹងទេ គាត់នឹងពិបាកនឹងបកឲ្យទាន់ ព្រោះនៅក្នុងការបកពីអង់គ្លេស ភាសាខ្មែរ យើងប្រហែលជាមានចំណុចដែលត្រូវបញ្ជាក់ផងដែរ ព្រោះការដែលបកប្រែបែបនេះ គឺយើងបកផ្ទាល់ បានន័យថា បកពីអង់គ្លេសមកខ្មែរផ្ទាល់ ។ ក៏ប៉ុន្តែ នៅពេលដែលបកពីបារាំងទៅខ្មែរ គឺយើងត្រូវតែ *រីឡេ* បានន័យថា លោកនិយាយជាភាសាបារាំង យើងត្រូវមានអ្នកបកប្រែពីបារាំងទៅអង់គ្លេស ហើយអ្នកបកប្រែនោះគឺនឹងបកប្រែពីអង់គ្លេសមកខ្មែរ ។ អ៊ីចឹង វាត្រូវការពេលវេលាមួយចំនួនដែលត្រូវការឲ្យលោកចៅក្រម និងអ្នកចូលរួមទាំងអស់មេត្តាយឺត ហើយនិងរង់ចាំអ្នកបកប្រែផង ។

ហើយនៅក្នុងចំណុចនេះផងដែរ គឺនៅពេលដែលយើងបកពីភាសាខ្មែរទៅបារាំង លោកដឹងហើយគឺ--នៅពេលដែលលោកនិយាយភាសាខ្មែរ គឺយើងត្រូវតែបកប្រែពីប្រសាសន៍លោកចៅក្រម ទៅជាភាសាអង់គ្លេសសិន ហើយទៅអ្នកបកប្រែអង់គ្លេស-បារាំង នឹងចាប់ពីភាសាអង់គ្លេសនេះទៅបារាំង គឺយើងមិនមានការបកប្រែផ្ទាល់ពីភាសាបារាំងខ្មែរ ឬក៏នៅក្នុងករណីនេះទេ ។

អ៊ីចឹង បានថា ខ្ញុំសុំឲ្យលោកអ្នកចូលរួមទាំងអស់ បានឲ្យយកការចាប់អារម្មណ៍ផង ព្រោះអ្នកបកប្រែជឿថាគាត់នឹងមានបញ្ហាបែបនេះហើយបើខ្ញុំជឿថាបើសិនជាលោកប្រធាន លោកដឹង លោកអាចជួយជម្រាបទៅអ្នកចូលរួមឲ្យយឺត ហើយនិងរង់ចាំអ្នកបកប្រែផង ដើម្បីជួយសម្រួលនីតិវិធីរបស់យើង ។

ហើយមួយទៀតគឺ ខ្ញុំខ្លួនឯងហ្នឹងង ថាឲ្យគេអានយឺតទេ ក៏ប៉ុន្តែបើខ្ញុំឡើងនិយាយហ្នឹងគឺខ្ញុំច្រើនតែញាប់ខ្លួនឯងទៅហើយ ក៏ប៉ុន្តែខ្ញុំអធ្យាស្រ័យ ហើយសុំឲ្យលោកផ្សេងៗកុំធ្វើតាម បានន័យថា ពេលលោកធ្វើ លោកសុំនិយាយឲ្យបានយឺត ហើយច្បាស់ដើម្បីឲ្យងាយស្រួលបកប្រែ ។ ហើយខ្ញុំក៏សុំរំឭកផងដែរថា នេះគឺពេលខ្លះ លោកត្រូវពិនិត្យមើលសញ្ញាណ ឬក៏បញ្ជាក់នៅមុខនឹងផងដែលគេស្នើថាលោកសុំមេត្តានិយាយឲ្យបានយឺត ។

អ៊ីចឹងនេះគឺជាអ្វីដែលខាងអ្នកបកប្រែសុំអំពាវនាវ សុំឲ្យលោកទាំងអស់ជួយខាងអ្នកបកប្រែផង គឺអាសារមើលសញ្ញាហ្នឹង ដើម្បីអានយឺត ។ ហើយខ្ញុំក៏សុំជម្រាបផងដែរនៅពេលដែលលោកនិយាយ

ពីរនាក់ក្នុងពេលតែមួយ អ្នកបកប្រែគឺមិនអាចបកទាន់ទេ ហើយយើងនឹងបិទមីក្រូមិនបកទេ ព្រោះពេលដែលលោក ដែលនិយាយពីរនាក់ក្នុងពេលតែមួយ ហើយយើងខ្ញុំខាងលើបកប្រែមិនកើតទេ ។ អ៊ីចឹងសុំនិយាយម្នាក់ម្តង ។

ហើយ នៅក្នុងនេះគឺ អ្នកបកប្រែមុននឹងបកប្រែបានល្អគាត់ត្រូវការឯកសារ ឬក៏ចំណុចអ្វីដែលមាន ដែលត្រូវលើកឡើងមកបង្ហាញក្នុងសវនាការ អ៊ីចឹងទេ អ្នកបកប្រែមានសេចក្តីសោមនស្សរីករាយ និងដឹងគុណបើសិនជាលោកទាំងអស់ផ្តល់ឯកសារ ហើយដើម្បីជួយឱ្យអ្នកបកប្រែបានល្អ ។ ហើយខ្ញុំដឹងថាដើម្បីការពារក្តីឱ្យបានល្អគឺទាល់តែអ្នកបកប្រែ បកប្រែបានល្អផងដែរ ខ្ញុំជឿថាខាងមេធាវីការពារក្តីគាត់ចង់បានអ៊ីចឹង ។

អ៊ីចឹង ពេលដែលលោកចៅក្រមឮសំឡេងអ្នកបកប្រែនៅក្នុងករណីនេះគឺ បានន័យថាអ្វីដែលស្តាប់ទៅភាគីគឺយើងឮសំឡេងអ្នកបកប្រែ អ៊ីចឹងបានន័យថាឯកសារខ្ញុំដឹងថាឯកសារដែលលាក់ការណ៍សម្ងាត់ទាំងណា ដែលលោកថាបើមិនចង់ឱ្យបែកការណ៍ទៅឆ្ងាយ ក៏ប៉ុន្តែមិនគួរលាក់ការណ៍ជាមួយអ្នកបកប្រែទេ ព្រោះអ្នកបកប្រែត្រូវការឯកសារទាំងអស់នេះ ដើម្បីត្រៀមខ្លួនកូពី ដើម្បីចែកគ្នា ដើម្បីត្រៀមខ្លួនឱ្យបានល្អជាមុន ដើម្បីជួយលោកទាំងអស់ហ្នឹងឱ្យមានការប្រព្រឹត្តិរលូននៅក្នុងការងារនៅក្នុងសវនាការតែប៉ុណ្ណោះ ។

ខ្ញុំក៏សុំជម្រាបផងដែរថា ពេលដែលលោកចង់បង្ហាញរូបភាពវីដេអូអ្វីនៅក្នុងសវនាការ នៅក្នុងនេះដំហររបស់អ្នកបកប្រែគឺយើងអាចបកប្រែវីដេអូបាននៅក្នុងករណីដែលយើងឃើញវីដេអូហ្នឹងពីមុនមួយថ្ងៃ ព្រោះអីរូបភាពអាចយើងនឹងពិបាកមើល ហើយនិងយើងទើបតែនឹងឃើញភ្លាមៗធ្វើឱ្យយើងអាចនឹងពិបាកនឹងមានឱកាសនឹងអាចយល់ និងបានត្រៀមខ្លួនបកប្រែឱ្យបានពេញលេញ ។ អ៊ីចឹងខ្ញុំសុំស្នើឱ្យលោកចៅក្រមមេត្តាជួយយកបញ្ហានេះយកទៅពិចារណាផង ។

ហើយនៅមានបញ្ហាមួយទៀត ដែលខ្ញុំលើកផងដែរ គឺទាក់ទងជាមួយនឹងប្រតិចារឹក ហើយជាពិសេស គឺការរំពឹងចង់បានឯកសារប្រតិចារឹកហ្នឹង ព្រោះនៅក្នុងនេះបើយើងមានប្រព័ន្ធបកប្រែ គឺដូចខ្ញុំបានពន្យល់រៀបរាប់ហើយ គឺមែនទែនទៅគឺយើងមិនរំពឹងថាប្រតិចារឹកនឹងអាចធ្វើបានដែលឥតខ្ចោះទាំងត្រូវទាំងវេយ្យាករណ៍ ទាំងត្រូវទាំងឃ្លោងឃ្លា ភាសាអង់គ្លេស ឬក៏ភាសាដើម មួយរយភាគរយនោះទេ ហើយអ៊ីចឹងនៅពេលដែលមាននរណាម្នាក់ លោកឡើងមកនិយាយគឺ ដោយមិនមានការអានបានន័យថា ខ្ញុំឃើញថា ក្នុងករណីដែលប៉ែតសិបពាក្យនៅក្នុងមួយរយពាក្យនៅក្នុងមួយនាទីអ៊ីចឹងគឺ គេ

យើងអាចនឹងធ្វើប្រតិចារឹកបាន ដូចថា ពេញលេញច្រើនជាងការដែលនិយាយលឿន ។ ហើយនៅក្នុងនេះគឺពេលខ្លះ ខ្ញុំឃើញថាមេធាវីហ្នឹងគាត់និយាយរហូតដល់ពីររយពាក្យក្នុងមួយនាទីក៏មានដែរ ក្នុងនេះខ្ញុំគិតថា បើសិនជាយើងកុំ-- ខ្ញុំដឹងថាពេលខ្លះគាត់មានអារម្មណ៍ដូចជារំភើបខ្លាំងពេកនៅក្នុងការនិយាយ គាត់និយាយលឿន ហើយអ៊ីចឹងទេ បើលឿនកាន់តែខ្លាំង គេហៅថាភាពត្រឹមត្រូវនៃការធ្វើប្រតិចារឹក ឬក៏បកប្រែក៏កាន់តែចុះដែរ ។ អ៊ីចឹងទេ សុំលោកមេត្តាចងចាំនូវចំណុចនេះផងដែរ ។

អ៊ីចឹងបើសិនជាលោកចង់ធ្វើអ៊ីចឹង សុំមេត្តាកុំ-- បានន័យថាបន្ថែមម៉ោងធ្វើបទបង្ហាញជាជាងការបង្ខើចម៉ោង ហើយឲ្យធ្វើឲ្យញាប់ អាហ្នឹងវាធ្វើឲ្យយើងខ្ញុំពិបាកនឹងតាម ។ ហើយមែនទែនទៅយើងខ្ញុំនឹងបង្កើនចំនួនបុគ្គលិករបស់យើងបន្ថែមទៀត ជាពិសេស អ្នកបកប្រែភាសាខ្មែរ-អង់គ្លេស អង់គ្លេស-ខ្មែរ ហើយយើងក៏នឹងកំពុងតែព្យាយាមរកអ្នកបកប្រែដែលមានសមត្ថភាពសម្រាប់បកប្រែភាសាបារាំង-ខ្មែរ ខ្មែរ-បារាំង ហើយបើយើងរកមិនបានទេ គឺយើងមានយន្តការសម្រាប់បណ្តុះបណ្តាលអ្នកដែលមានស្រាប់នៅទីនេះ ដើម្បីឲ្យក្លាយទៅជាអ្នកដែលមានជំនាញបកប្រែបាន ។

ហើយខ្ញុំសូមផ្តល់ឱកាសនេះជូនដល់លោក សុភី ដែលជាសហការីរបស់ខ្ញុំ និយាយពីផ្នែកបកប្រែភាសា ។ ហើយប្រសិនជាលោកមានចម្ងល់ ឬក៏សំណួរអ្វីទាក់ទងជាមួយនឹងការបកប្រែ ឬក៏ប្រតិចារឹក បន្ទាប់ពីបទបង្ហាញនេះទៅលោកអាចសួរបាន ។ សូមអរគុណ ។

**លោក គង់ សុភី៖**

សូមគោរព លោកចៅក្រម ។

ខ្ញុំសូមធ្វើបទបង្ហាញពាក់ព័ន្ធពីរឿងការងារបកប្រែ ។ ជាគោលការណ៍ខាងអង្គភាពយើងខ្ញុំនេះគឺផ្តល់ការបកប្រែទៅតាមការស្នើសុំរបស់ការិយាល័យទាំងអស់ ។ ហើយកន្លងមកនេះ យើងបានផ្តល់ការបកប្រែទៅដល់ខាងសឹងតែដល់គ្រប់ភាគីទាំងអស់នៅក្នុងសវនាការនេះ មានខាងសហព្រះរាជអាជ្ញា មានខាងមេធាវីការពារក្តី មានខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយទន្ទឹមនឹងហ្នឹង ក៏ផ្តល់ការបកប្រែទៅដល់ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ទៅដល់អង្គជំនុំជម្រះសាលាដំបូង អង្គបុរេជំនុំជម្រះ ហើយក៏ផ្តល់ការបកប្រែទៅដល់ការរៀបចំឯកសារមួយចំនួនទៀត សម្រាប់កិច្ចប្រជុំរបស់គណៈកម្មការនីតិវិធី កិច្ចប្រជុំរបស់គណៈកម្មការរដ្ឋបាល តុលាការ និងការរៀបចំឯកសារសម្រាប់កិច្ចប្រជុំពេញអង្គជាដើម ។

ជាគោលការណ៍ គឺខាងអង្គភាពយើងខ្ញុំនេះបកប្រែឯកសារ ទោះបីជាឯកសារហ្នឹងសំណុំរឿង

ក៏ដោយ ឯកសារការងាររដ្ឋបាលក៏ដោយ ជាឯកសារពាក់ព័ន្ធនឹងរឿងក្ដីក៏ដោយ យើងខ្ញុំបកប្រែតែឯកសារណាដែលភាគីស្នើសុំឱ្យខាងអង្គភាពយើងបកប្រែ នេះជាគោលការណ៍ ។

ហើយចំណុចទីពីរ គឺយើងខ្ញុំបកប្រែដោយគោរពទៅតាម *ដេតឡាញ* ដែលគេបានស្នើសុំ ដែលបាន ដែលអ្នកដាក់សំណើសុំហ្នឹងបានស្នើសុំ ។ ក្នុងករណីណាដែលយើងខ្ញុំពិនិត្យឃើញថា ដោយសារបញ្ហាចំនួនបុគ្គលិកមិនអាចបកប្រែបាន យើងខ្ញុំជួយពិភាក្សាជាមួយអ្នកដាក់សំណើហ្នឹង យើងធ្វើការចរចាថាតើអាចពន្យារពេលទៅថ្ងៃណាបាន? បើសិនមិនអាចពន្យារពេលបានទេ គឺខាងយើងខ្ញុំមានវិធានការដោយឡែកមួយទៀត គឺយើងបញ្ជូនទៅឱ្យអ្នកខាងក្រៅបក ។ អាចជាអ្នកបកប្រែជាឯកជន ឬជាអង្គភាពដែលទទួលការបកប្រែពីខាងក្រៅ ។

ពាក់ព័ន្ធនឹងការបកប្រែនេះ ខ្ញុំសូមជម្រាបជូនថា នៅក្រោយពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីកាមួយពាក់ព័ន្ធនឹងការបកប្រែមក គឺខាងអង្គភាពយើងខ្ញុំបានបញ្ជូនអ្នកបកប្រែសម្រាប់ក្រុមមេធាវីការពារក្ដីចំនួន៥ យើងបញ្ជូន៥រូបទៅដើម្បីជួយក្រុមមេធាវីនោះ ដើម្បីពិនិត្យមើលសាឡើងវិញទៅលើឯកសារនៅក្នុងសំណុំរឿង ដើម្បីបញ្ជាក់ថាតើឯកសារណានៅក្នុងសំណុំរឿងដែលត្រូវបកប្រែទៅជាភាសាណា? ហើយក្រោយដែលពេលខ្ញុំបានចាត់បញ្ជូនមន្ត្រីនេះ គឺយើងបានទទួលការឆ្លើយតបមកវិញថា មានមេធាវីចំនួនពីរក្រុម គាត់អត់ទទួលយក ហើយមានមេធាវីពីរក្រុមទៀតគាត់សម្រេចចិត្តប្ដឹងឧទ្ធរណ៍ទៅលើដីកាបកប្រែនេះ ។ ហើយដោយឡែកមានមេធាវីមួយក្រុម មេធាវីមួយក្រុមទៀតគាត់ទទួលសហការយក ។ យកអ្នកបកប្រែហ្នឹងដើម្បីយកទៅពិនិត្យមើលសំណុំរឿង ដើម្បីត្រួតពិនិត្យលើឯកសារទាំងអស់ហ្នឹង ។

ហើយដោយគោរពទៅតាមដីកានេះ ស្ដីពីការបកប្រែនេះគឺអង្គភាពយើងខ្ញុំបានចាប់ផ្ដើម បានធ្វើការសហការគ្នាយ៉ាងជិតដិតជាមួយខាងការិយាល័យសហព្រះរាជអាជ្ញា ក៏ដូចជាខាងមេធាវីការពារក្ដី ហើយយើងបានរៀបចំកិច្ចប្រជុំពីរសប្ដាហ៍ម្ដងជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ដូចជាក្រុមមេធាវីការពារក្ដីដែរ ដើម្បីទីមួយ មានគោលដៅពីរ៖ ទីមួយ គឺពិនិត្យមើលលើឯកសារដែលនៅក្នុងសំណុំរឿង ថាតើឯកសារណាដែលជាឯកសារអាទិភាព ហើយទៅខាងគាត់ហ្នឹងអ្នកបញ្ជូនបញ្ជីឯកសារអាទិភាពនេះមកឱ្យយើងខ្ញុំ ហើយខ្ញុំអ្នកចាត់ចែងបកប្រែ ។ ហើយកន្លងមកនេះពាក់ព័ន្ធនឹងរឿងក្ដីសំណុំរឿងទីមួយនេះ គឺយើងបានធ្វើការ សហការជាមួយខាងក្រុមមេធាវីការពារក្ដីលោក កាំង ហ្គេកអ៊ាវ នោះមានក្រុមមេធាវីរបស់លោក ការ សាវុត្ថ និង

លោក ហ្វ្រង់ស្វ័រ រូ នេះគឺយើងបានធ្វើការសហការជាមួយគ្នា ហើយខាងគាត់បានបញ្ជូនបញ្ជីឯកសារជាអាទិភាពសម្រាប់ការបកប្រែ ។ ហើយខាងយើងខ្ញុំបានចាត់ចែងការបកប្រែទៅ ហើយយើងគោរពទៅតាម *ដេតឡាញ* ខាងនោះ ។

ទន្ទឹមនឹងហ្នឹងដែលពាក់ព័ន្ធនឹងសំណុំរឿងទីមួយនេះ យើងបានទទួលបញ្ជីឯកសារជាអាទិភាពពីខាងការិយាល័យសហព្រះរាជអាជ្ញាហ្នឹងមានរហូតទៅដល់ប្រាំបញ្ជីធំៗ ហើយបញ្ជីមួយៗមានចំនួនរាប់ពាន់សន្លឹក ។ ហើយបញ្ជីចុងក្រោយនេះខាងលោក បៀល គាត់បញ្ជូនមកយើងខ្ញុំនេះ កាលពីសប្តាហ៍មុននេះគឺមានរហូតដល់មួយពាន់ប្រាំមួយរយសន្លឹកដែលត្រូវការបកប្រែ ។ ហើយបកប្រែជាបន្ទាន់ឲ្យហើយក្នុងពាក់កណ្តាលខែពីរនេះ ។

ជាគោលការណ៍ ខាងគឺយើងខ្ញុំបាន ខាងអង្គភាពយើងខ្ញុំបានផ្តល់ការបកប្រែហ្នឹងជាអាទិភាពបំផុតទៅលើគ្រប់ឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងទីមួយ ។ ហើយនៅមានក្នុងសំណុំរឿងទីមួយ ហើយយើងបានផ្តល់ *ដេតឡាញ* ហ្នឹងគឺនៅចុងខែពីរហ្នឹងឲ្យហើយទាំងអស់ គ្រប់ឯកសារដែលមាននៅក្នុងសំណុំរឿងទីមួយហ្នឹង ។

ហើយខ្ញុំសូមបញ្ជាក់មួយទៀត ឯកសារដែលមាននៅក្នុងសំណុំរឿងទីមួយនេះ គឺឯកសារដែលភាគីទាំងអស់បានផ្ញើជូនមកយើងខ្ញុំឲ្យមានបកប្រែ ជាមួយនឹងការបញ្ជាក់ថា ឯកសារទាំងអស់នោះជាឯកសារអាទិភាព ។ ចំពោះឯកសារដទៃទៀតដែលភាគីអត់បញ្ជាក់ថា ឯកសារនោះជាឯកសារអាទិភាពទេ ខាងយើងខ្ញុំទុកក្នុងបកប្រែក្នុងដំណាក់កាលបន្ទាប់ទៀត ។

ដូចទៅនឹងអ្វីដែលជារបាយការណ៍ខាងយើងខ្ញុំបានផ្ញើជូនទៅអង្គជំនុំជម្រះសាលាដំបូងកាលពីចុងខែធ្នូ នេះ ពាក់ព័ន្ធទៅនឹងរបាយការណ៍នៃការបកប្រែនេះ គឺខាងយើងខ្ញុំបានបញ្ជូនរបាយការណ៍ពាក់ព័ន្ធនឹងការបកប្រែនេះពីរខែម្តង ។

ពាក់ព័ន្ធនឹងករណីសំណុំរឿងទីមួយនេះ គឺខាងយើងខ្ញុំបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងពីរបាយការណ៍នៃការបកប្រែហ្នឹងមានផ្នែក-- មានផ្នែកទីមួយគឺឯកសារដែលយើងកំពុងតែបកប្រែ ហើយផ្នែកទីពីរឯកសារដែលរង់ចាំការបកប្រែ ហើយផ្នែកទីបី ឯកសារដែលបានបកប្រែហើយ ។

ប្រសិនជាលោកចៅក្រមអនុញ្ញាត ខ្ញុំរាយការណ៍ជូនដោយលម្អិតអំពីចំនួនសំណុំឯកសារដែលមាននៅក្នុងសំណុំរឿងទីមួយនេះ ហើយដែលបានផ្ញើជូនមកឲ្យយើងខ្ញុំបកប្រែនៅក្នុងប្រព័ន្ធបកប្រែយើងខ្ញុំនេះ ។ នៅក្នុងសំណុំរឿងទីមួយដែលឯកសារដែលយើងទទួលបាននៅក្នុងប្រព័ន្ធបកប្រែយើងហ្នឹង

ទាំងអស់គឺមានប្រាំពីររយកៅសិបបីឯកសារ ហើយដែលមានចំនួនមួយម៉ឺនបួនពាន់ប្រាំរយកៅសិបប្រាំបួនសន្លឹក ។

ហើយក្នុងឯកសារទាំងប្រាំពីររយកៅសិបបីឯកសារនេះ មានឯកសារបួនរយដប់ពីរសន្លឹក ដែលបានចាត់ទុកថាជាឯកសារអាទិភាពនោះ គឺយើងបានចាត់ចែងបកប្រែហើយ ហើយយើងនឹងបកប្រែឱ្យហើយនៅបំណាច់ខែពីរខាងមុខនេះ ។

ហើយមានមួយផ្នែកទៀតដែលជាឯកសារ នៅក្នុងសំណុំរឿងទីមួយដែរ ប៉ុន្តែ យើងអត់បានទទួលការចាត់ថ្នាក់ជាឯកសារជាអាទិភាពទេ មានចំនួនពីររយហុកសិបប្រាំឯកសារ ។

ហើយមានមួយផ្នែកទៀតគឺឯកសារចំនួនមួយរយដប់ប្រាំមួយឯកសារហ្នឹង គឺយើងបានបកប្រែរួចរាល់អស់ហើយ ។

អ៊ីចឹងសូមបញ្ជាក់ជូនទៅវិញប្រសិនបើភាគីទាំងអស់ពិនិត្យមើលឃើញក្នុងរបាយការណ៍ហ្នឹងទៅលើឯកសារផ្នែក(ខ) ដែលយើងបានរាយការណ៍ជូនហ្នឹង ដែលកន្លងមកមិនបានចាត់ទុកជាការងារជាអាទិភាពទេ ប្រសិនបើភាគីយល់ឃើញថា ឯកសារនៅក្នុងផ្នែកហ្នឹងមួយ ឯកសារណាមួយជាអាទិ-ភាព សូមប្រាប់មកយើងខ្ញុំទៅ យើងខ្ញុំនឹងចាត់ទុកឯកសារនោះជាអាទិភាព ហើយយើងនឹងចាត់ចែងការបកប្រែជាបន្ទាន់ ។

ទន្ទឹមនឹងការងារទាំងអស់នេះដែរ កន្លងមកជាការពិតខាងអង្គភាពយើងខ្ញុំបានជួបប្រទះនឹងបញ្ហារឿងកង្វះបុគ្គលិកមែន ។ រឿងពាក់ព័ន្ធបញ្ហាកង្វះបុគ្គលិកនេះ គឺវាពាក់ព័ន្ធនឹងបញ្ហាថវិកា ។ ប៉ុន្តែអ្វីដែលយើងអាចដោះស្រាយបាននោះ គឺយើងមានយន្តការបន្ថែមមួយទៀត គឺយើងផ្តល់ការបកប្រែឯកសារហ្នឹងទៅផ្នែកខាងក្រៅ ។ អាចជាអ្នកបកប្រែ បុគ្គលនីមួយៗអាចបកប្រែជា ខ្មែរ-អង់គ្លេស, ខ្មែរ-បារាំង ឬ បារាំង-អង់គ្លេស ឬ អង់គ្លេស-បារាំង ទីមួយ ។

ហើយទីពីរខាង តាមរយៈថវិការបស់ខាងផ្នែករបស់ *យូអ៊ិន* នោះគឺយើងបានធ្វើ *ប្រូខួរមិន* ទៅឱ្យអង្គភាពខាងក្រៅឱ្យមានការបកប្រែ ហើយកន្លងមកយើងបាន-- អង្គជំនុំជម្រះក្នុង *អ៊ីស៊ីស៊ីស៊ី* ហ្នឹងបានចុះកិច្ចសន្យាផ្តល់ការបកប្រែទៅឱ្យខាង *ឌីស៊ីខេម* ទៅដល់ខាងក្រុមហ៊ុនអប្សរា ដែលគាត់បកប្រែពីខ្មែរទៅបារាំង ទៅបារាំងទៅខ្មែរ និងមានផ្តល់កិច្ចសន្យាមួយទៀតសម្រាប់ទៅដល់ក្រុមហ៊ុនអន្តរជាតិដែលមានឈ្មោះថា *តេឡេលីងហ្គ័រ* ហ្នឹង គឺគាត់បកប្រែពីបារាំង-អង់គ្លេស, អង់គ្លេស-បារាំង គឺតាមរយៈយន្តការទាំងអស់នេះហើយដែលខាងអង្គភាពយើងខ្ញុំដែលធានាថា អាចផ្តល់ការបកប្រែហ្នឹងឱ្យបានទាន់

ពេលវេលាដល់ភាគីទាំងអស់ ។ ខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណឹង សូមអរគុណ ។

**ប្រធានអង្គជំនុំះ**

សូមអរគុណលោកស្រី មីស៊ែល និង លោក គង់ សុភី ដែលបានធ្វើបទបង្ហាញជូនដល់អង្គប្រជុំ យើងបានយល់ បានជ្រាប អំពីការងារ អំពីផលលំបាក ការងារលំបាកផ្សេងៗដែលអង្គភាពបកប្រែភាសាហ្នឹងបានជួបប្រទះ ។ ហើយដើម្បីជាកិច្ចបន្ត ដើម្បីច្បាស់ពីបញ្ហានេះ គឺសូមប្រគល់នូវវេទិកានេះទៅភាគីដែលពាក់ព័ន្ធដើម្បីតាំងសំណួរ ។

ហើយជាដំបូងសូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តើមានសំណួរ ឬក៏មានការកត់សម្គាល់អ្វីចំពោះបទបង្ហាញរបស់មន្ត្រីជាន់ខ្ពស់នៃផ្នែកបកប្រែភាសានេះដែរឬទេ? បើមានសូមអញ្ជើញ! សូមអញ្ជើញ លោកមេធាវី ។

**លោក គង់ ពិសីះ**

ខ្ញុំបាទសូមអរគុណ លោកប្រធានអង្គជំនុំជម្រះ ។ ខ្ញុំសូមទាញអារម្មណ៍ថា នៅពេលដែលយើងធ្វើការកាត់ក្តីនៅក្នុងសាលាក្តីនេះ គឺយើងឆ្លងកាត់តាមរយៈការបកប្រែ ។ អ៊ីចឹងយើងគិតថា អ្នកណាម្នាក់ក៏មិនអាចធ្វើអីឥតខ្ចោះដែរ ក៏ប៉ុន្តែនៅក្នុងការបកប្រែកាលណាដែលមានការខ្វះចន្លោះត្រង់ណា គឺថាអ្នកដែលកាត់ក្តី អ្នកចូលរួមកាត់ក្តីហ្នឹងនឹងពិចារណានូវអ្វីដែលបានលើកឡើងនោះហើយ ។

កន្លងមកខ្ញុំមិនទិតៀនអ្នកបកប្រែទេ តែកន្លងមកខ្ញុំសូមអរគុណហើយ ប៉ុន្តែ តាមដែលខ្ញុំមានបទពិសោធន៍ទៅឃើញថា នៅពេលដែល ខ្ញុំស្តាប់ជាភាសាខ្មែរ ហើយនៅពេលនោះមានអ្នកស្តាប់ភាសាអង់គ្លេសគាត់អត់បានដឹងថាខ្លឹមសារដែលគេនិយាយភាសាខ្មែរហ្នឹងយ៉ាងម៉េច? ហេតុដោយសារតែខ្ញុំដឹងដោយមកពីអ្នកនោះគាត់សួរទៅគេ គាត់សួរទៅអង្គជំនុំជម្រះ ឬក៏សួរទៅភាគីម្ខាងទៀតថា ចុះអាចំណុចនេះ ត្រង់នេះយ៉ាងម៉េចដែរ? តាមការពិតនៅក្នុងខ្ញុំ ខ្ញុំមានភាសាខ្មែរ ដល់ពេលឮសួរគាត់សួរអ៊ីចឹងទៅហាក់បីដូចជា ប្រហែលជាគាត់មិនបានស្តាប់ ឬក៏អ្នកបកប្រែហ្នឹងខ្វះចន្លោះ នេះត្រង់ចំណុចហ្នឹងមួយ ។

ចំណុចមួយទៀតខ្ញុំសូមសួរទៅអង្គភាពផ្នែកខាងបកប្រែហ្នឹងដែរ គាត់បានលើកឡើងថា ឯកសារដែលមានច្រើនអ៊ីចឹង គាត់បញ្ជូនទៅក្រុមហ៊ុនផ្សេងៗ មានទាំងក្រុមហ៊ុនបរទេស ក្រុមហ៊ុនអប្សរាអ៊ីចឹង ។ តាមដែលខ្ញុំដឹងកន្លងមកអ្នកបកប្រែមុននឹងធ្វើ ចូលធ្វើការបកប្រែគាត់តែងតែមានការស្បថដើម្បីរក្សាការសម្ងាត់នូវឯកសារផ្សេងៗ ។ ចុះបើសិនណាគាត់បញ្ជូនឯកសារទាំងនោះយកទៅឲ្យក្រុមហ៊ុនផ្សេងៗបកប្រែ សួរថាតើក្រុមហ៊ុនទាំងនោះគេមានបានធ្វើដូចជាអ្នកដែលបកប្រែនៅក្នុងអង្គភាព

នៅក្នុងតុលាការនេះដែរឬទេ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មានសំណួរអ្វីទៀតទេ? ដាក់សំណួរឲ្យហើយទៅ ហើយអញ្ជើញខាងអ្នកមន្ត្រីជាន់ខ្ពស់បកប្រែភាសាហ្នឹង បកប្រែហ្នឹងគាត់នឹងធ្វើការបំភ្លឺអំពីចំណុចនេះ ដែលចំណុចណាដែលអាចបំភ្លឺបាន ហើយចំណុចណាដែលមិនបំភ្លឺមិននឹងពិភាក្សាគ្នាបន្តទៅទៀត ។ មានទេ? សូមអញ្ជើញលោកស្រី ។ សូមអញ្ជើញ!

**លោកស្រី ស៊ីលឃីស្ទូត ហ្សឹនស្គី៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំមានសំណួរបច្ចេកទេស ព្រោះការបកប្រែនេះ គឺយើងត្រូវធ្វើតាមរយៈស្នើសុំតាមប្រព័ន្ធ ឬមានទម្រង់ស្នើសុំ ហើយមែនទែនបើស្នើសុំបកប្រែបានទាល់មកតុលាការ អ.វ.ត.ក ។ ហើយខ្ញុំចង់សួរដែរថា តើដើម្បីស្នើសុំបកប្រែយើងអាចធ្វើក្រៅពីមកតុលាការហ្នឹងបានទេ? បានន័យថា អាចសុំស្នើតាមរយៈពីចំងាយ ឬក៏អាចស្នើសុំបកប្រែមិនចាំបាច់ប្រែទម្រង់នេះបានដែរឬទេ? ឬក៏អាចថាស្នើសុំតាមមាត់ទទេសិនទៅរួចទៅចាំស្នើសុំសរសេរជាលាយលក្ខណ៍អក្សរតាមក្រោយទៅបានទេ? ព្រោះខ្ញុំបានមានបទពិសោធន៍កន្លងមកគឺឃើញថា មុននឹងសុំបកប្រែអីបានទាក់តែយើងធ្វើឯកសារ ហ្នឹងទៅតាមប្រព័ន្ធ ហើយសរសេរទម្រង់បែបបទ បំពេញស្នើសុំបកប្រែហ្នឹងឲ្យច្បាស់លាស់សិន ។ គ្រាន់តែខ្ញុំចង់សុំឲ្យលោកចៅក្រម ឬក៏ផ្នែកខាងបកប្រែសុំជួយមក ថាតើអាចមានយន្តការ ឬក៏វិធីអីផ្សេងក្រៅពីហ្នឹងទេ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ខាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចមិនមានសំណួរអីទៀតទេមែនទេ? សូមជូនវេទិកានៃទៅមន្ត្រីជាន់ខ្ពស់ ។ ហុង គីមសួន ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធានម្តងទៀត ខ្ញុំបាទក៏សូមអរគុណផងដែរដល់លោកប្រធាន និងលោកស្រីខាងប្រធានដឹកនាំខាងបកប្រែភាសា ។ នៅខាងផ្នែកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំយើងខ្ញុំនេះមានផលវិបាកពីមុនមក ឥឡូវបានធូរខ្លះដោយសារខាងលោកខាងបកប្រែហ្នឹងគាត់បានឆ្លៀតឱកាសដូចថា អ្នកស្រី ស៊ីលកិ គាត់បានលើកអម្បាញ់មិញដែរ គាត់ជួយមួយផ្នែក ។

ប៉ុន្តែផលវិបាកដែលយើងធ្លាប់បានជួននោះគឺ នៅពេលធ្វើការបកប្រែនៅពេលសរសេរសារណា។

អ៊ីចឹងនីតិវិធីរបស់ខាងតុលាការ *អ៊ីស៊ីស៊ីស៊ី* នេះមានរយៈពេលកំណត់ ជួនកាលយើងដែលវាខ្វះធនធានផង យើងសរសេរសារណាស្រាវជ្រាវឯកសារពីបរទេស ជាភាសាបារាំង ឬភាសាអង់គ្លេសហ្នឹង យើងត្រូវការបកប្រែឲ្យមកជាខ្មែរហើយ ធ្វើការពិគ្រោះគ្នារួច បានបញ្ជូនឯកសារសារណាហ្នឹងទៅស្នើសុំខាងអង្គភាពបកប្រែនេះជួយបកប្រែឲ្យទៅជាភាសាអង់គ្លេស ឬជាភាសាបារាំងមុនយើងដាក់បញ្ជូលមកតុលាការនេះ ។

អ៊ីចឹងការបកប្រែនេះវាមានការផលវិបាកចំពោះខាងក្រុមយើងខ្ញុំ គឺវាលើសពេលវេលា ។ អ៊ីចឹងតុលាការមានកំណត់ពេល ឧទាហរណ៍ថា ជូនដំណឹងឲ្យភាគីដាក់សារណាឲ្យទាន់ពេលកំណត់ថ្ងៃមួយសប្ដាហ៍ ឬក៏ដប់ថ្ងៃអីចឹង ។ អ៊ីចឹងការបកប្រែជួនកាលសំណើសុំមកខាងអង្គភាពបកប្រែទៅគាត់ជាប់រវល់ ។ ដូចគាត់បានលើកឡើងអម្បាញ់មិញអ៊ីចឹងគឺថា បុគ្គលិករបស់គាត់ លោក សុភី បានថាជូនទៅខាងចៅក្រមនោះអស់ពីរនាក់ នៅសល់បួននាក់បកប្រែប្រដេញមាត់ផង បកប្រែតាមអង្គប្រជុំផង និងបកប្រែសរសេរប្ដូរផ្លាស់ពីភាសាខ្មែរ-បារាំង, ខ្មែរ-អង់គ្លេសទៅវិញទៅមក ។

អ៊ីចឹងនៅក្នុងនេះដែរជាសំណើទេ ជាសំណើរបស់ខ្ញុំបាទ ដោយសារខាងមេធាវីរដ្ឋប្បវេណីខាងក្រុមយើងខ្ញុំនេះ គឺខ្វះខាតទាំងស្រុងនូវធនធាននេះ គឺសុំឲ្យមានលោកប្រធានជួយទៅខាងអង្គភាពបកប្រែហ្នឹងជួយផ្ដល់ឱកាសចំពោះឯកសារខាងយើងខ្ញុំនេះឲ្យទាន់ពេលវេលាផង ។ ព្រោះថាបើលោកឆ្លើយថាជាប់រវល់ ខ្ញុំអត់បានដឹងទេ គឺដឹងដោយសារលោកខាងបកប្រែតែម្ដង គាត់ថា ពេលខ្លះគាត់អត់អាចជួយបានទេ គឺគាត់ជាប់រវល់ ដូចគាត់មានប្រសាសន៍ថាបកប្រែរាប់ពាន់សន្លឹកឯណោះ ។ អ៊ីចឹងខាងខ្ញុំសារណាម្ដងមានដប់ម្ភៃទំព័រនេះ គឺមានជួបផលលំបាកហើយ ។

អ៊ីចឹងសំណើថា ខាងខ្ញុំដាក់សុំឲ្យបកប្រែជាភាសាខ្មែរ ហើយយើងយកទៅមើលឡើងវិញទៀតទើបបញ្ជូនមកទៅជាភាសាអង់គ្លេងឲ្យវាជា *ខូរិច* ឲ្យបានល្អ ទើបបានដាក់ជូន ។ អ៊ីចឹងសូមឲ្យលោកប្រធានមេត្តាផ្ដល់ឱកាសពេលវេលា នីតិវិធីសម្រាប់ឲ្យយើងខ្ញុំបានវែងជាង ការកំណត់របស់តុលាការ ។ មិនមែនទាំងអស់ទេ គឺមានពេលខ្លះ យើងខ្ញុំត្រូវការសុំពេលវេលាបន្ថែមអ៊ីចឹង សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកមេធាវី ឥឡូវសូមអញ្ជើញលោកស្រី មីសែល ហើយនិង គង់ សុភី អាចឆ្លើយតបនឹងសំណួរពាក់ព័ន្ធនឹងបទបង្ហាញរបស់លោក លោកស្រីបានទេ? សូមអញ្ជើញ!

**លោកស្រី មីសែល ឃីធីង៖**

សូមអរគុណលោកប្រធាន ដំបូងខ្ញុំចង់លើកបញ្ជាក់បន្តិចអំពីភាពផ្សេងគ្នារវាងការបកប្រែផ្ទាល់មាត់និងការបកប្រែឯកសារ ដើម្បីឱ្យអស់លោកអ្នកបានយល់បានយល់ដឹងច្បាស់អំពីចំណុចនេះ ។ ការបកប្រែផ្ទាល់មាត់ គឺនៅពេលដែលអ្នកណាម្នាក់និយាយ ដូចជាខាងសហសេវិករបស់ខ្ញុំកំពុងតែធ្វើនៅខាងលើនេះ គឺមានន័យថា គេស្ដាប់នូវអ្វីដែលខ្ញុំកំពុងនិយាយ ហើយគេបានធ្វើការបកប្រែទៅជាភាសាមួយទៀត ។ នេះជាអ្វីដែលយើងធ្វើដែលនៅពេលដែលយើងសម្រុះសម្រួលនៅក្នុងអង្គប្រជុំ ទោះបីជាយើងមិនប្រើនូវឧបករណ៍សម្រាប់បំពងសំលេងក៏ដោយ ។ អ៊ីចឹង ការបកប្រែឯកសារគឺជាការបកប្រែទៅលើក្រដាស ទៅលើអត្ថបទ ។ អ៊ីចឹងមានន័យថា គេបានបង្កើតទៅជាឯកសារថ្មីមួយ ដែលជាឯកសារសរសេរ ជាឯកសារក្រដាសស្នាម នេះគឺភាពផ្សេងគ្នារវាងសេវាទាំងពីរ ។

ទាក់ទងនឹងសេចក្ដីបារម្ភលើកទីមួយ មានន័យថា ជួនការសំណួរហ្នឹងត្រូវបានលើកឡើង ហើយបញ្ហាយើងមិនដឹងថាតើអ្នកស្ដាប់ហ្នឹងយកចិត្តទុកដាក់ ឬមួយក៏អ្នកបកប្រែហ្នឹងគាត់មិនបានបកប្រែត្រឹមត្រូវ ។ នេះសំណួរដែលយើងបានពិភាក្សាគ្នានៅក្នុងបន្ទប់បកប្រែផងដែរ ។ អ៊ីចឹងគឺថាយើងមានលទ្ធ-ភាពក្នុងការមើលនៅក្នុងប្រតិចារឹក ។ អ៊ីចឹងខាងក្រុមអ្នកបកប្រែផ្ទាល់មាត់ហ្នឹង នឹងធ្វើការសហការទៅលើចំណុចដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃអ្វីដែលបាននិយាយ ពីព្រោះយើងអាចមានលទ្ធភាពនៅថ្ងៃដែលថាយើងមិនធ្វើការនៅក្នុងបន្ទប់បកប្រែនុ៎ងឯង គឺថានៅក្នុងអង្គជំនុំជម្រះនោះឯង ដែលមិនធ្វើការជារៀងថ្ងៃ គឺថាយើងអាចធ្វើការនៅលើប្រតិចារឹកដើម្បីបង្កើននូវភាពត្រឹមត្រូវទៅតាមលទ្ធភាពរបស់យើង ។

ទាក់ទងនឹងភាពសម្ងាត់នៃការបកប្រែឯកសារក្រដាសស្នាមសម្រាប់អ្នកស្ថិតនៅខាងក្រៅនោះ គឺថាអ្នកដែលបានធ្វើកិច្ចសន្យាជាមួយយើងទាំងអស់ហ្នឹងបានចុះនូវកិច្ចព្រមព្រៀងមួយទាក់ទងទៅនឹងភាពសម្ងាត់នៃឯកសារនោះ មុនពេលដែលយើងផ្ដល់នូវឯកសារឱ្យទៅក្រុមហ៊ុន ឬក៏អ្នកឯកជនហ្នឹងបកប្រែ ។ ហើយនៅពេលដែលការបកប្រែ ឬក៏ក្រុមហ៊ុនបកប្រែហ្នឹងឯងបញ្ជូនឯកសារដែលអ្នក បកប្រែនោះ គឺថាអ្នកបកប្រែខ្លួនឯងផ្ទាល់ក៏ត្រូវចុះកិច្ចព្រមព្រៀងទៅលើភាពសម្ងាត់នៃឯកសារនោះផងដែរ ។

ទាក់ទងទៅនឹងការធ្វើសំណើឱ្យបកប្រែពីកន្លែងចម្ងាយនោះ ខ្ញុំមិនដឹងថាអាចធ្វើបាន ឬក៏យ៉ាងម៉េចទេ ខ្ញុំទាក់ទងជាមួយផ្នែកបច្ចេកទេស ថាតើអាចឱ្យមានការស្នើសុំការបកប្រែពីចម្ងាយបានដែរ ឬក៏យ៉ាងម៉េចនោះ? ជាពិសេសទាក់ទងនឹងអ្នក ឬក៏ក្រុមផ្នែកការពារក្ដីដែលមិនចាំបាច់មានវត្តមាន ឬធ្វើការនៅលើទីតាំងរបស់តុលាការនេះផ្ទាល់ ។ ហើយយើងប្រហែលជាអាចធ្វើនូវប្រព័ន្ធមួយដែលអាចធ្វើ

សំណើសុំការបកប្រែពីចម្ងាយបាន ។

ទាក់ទងទៅនឹងចំណុចចុងក្រោយ គឺទាក់ទងទៅនឹងការបកប្រែសារណានោះ ហើយនិងការកំណត់ពេលវេលា ។ អ្វីដែលខ្ញុំមិនអាចនិយាយបាន គឺយើងបានធ្វើការជិតស្និទ្ធណាស់ជាមួយភាគីនានាជាមួយខាងក្រុមការពារក្តី ហើយនិងជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗគឺថា យើងត្រូវមានបើសិនជាភាគីណាមួយមានបំណងចង់ដាក់សារណាឲ្យធ្វើការបកប្រែឲ្យទាន់ពេលវេលា ។ ឧទាហរណ៍សម្រាប់រយៈពេលមួយសប្តាហ៍នោះ ឬក៏មានក្រុមរបស់គេត្រូវធ្វើការស្រាវជ្រាវសិន ធ្វើសេចក្តីព្រាងសិន។ អ៊ីចឹងគេក៏ត្រូវធ្វើសេចក្តីព្រាងដើម្បីទុកឱកាសដើម្បីឲ្យអ្នកបកប្រែ បកប្រែឯកសារនោះផងដែរ។ ឧទាហរណ៍បើសិនជាគេមកជួយយើងនៅថ្ងៃច័ន្ទ ហើយគេប្រាប់ថា ឥឡូវនៅថ្ងៃច័ន្ទក្រោយហ្នឹងឯងនឹងត្រូវដាក់នូវឯកសារ ឬសារណានោះរយៈពេលមួយអាទិត្យនេះ ហើយយើងនឹងប្រាប់វិញដើម្បីបកប្រែឯកសាររយៈពេល២០ថ្ងៃនេះ យើងនឹងត្រូវការរយៈពេលពីរថ្ងៃ ប្រសិនបើយើងបានទទួលសារណានេះបានមុន ដើម្បីកំណត់ទៅតាមពេលវេលាដែលបានកំណត់ក្នុងការដាក់សារណានោះទៅអង្គជំនុំជម្រះ ។

អ៊ីចឹងមានន័យថា ភាគីនានាត្រូវព្យាយាមរក្សាពេលដើម្បីទុកឱកាសឲ្យឯកសារនោះបានបកប្រែ ពីព្រោះអី? គឺថាយើងមិនមានអ្នកបកប្រែឲ្យបានគ្រប់គ្រាន់ទេ ដូចខ្ញុំអ៊ីចឹង ខ្ញុំមិនអាចធ្វើបានទេ ទាក់ទងនឹងការកំណត់ពេលវេលាដែលកំណត់ដោយអង្គជំនុំជម្រះនោះ ។

អ៊ីចឹងមានន័យថា ខ្ញុំប្រហែលជាអាច គ្រាន់តែអាចព្យាករណ៍បាននូវពេលវេលាកំណត់សម្រាប់ឯកសារដែលអាចនឹងបកប្រែទាន់ពេលវេលានោះ ។ ហើយប្រសិនបើលោកត្រូវការពេលវេលាបន្ថែម ពីព្រោះ គឺថាមាន ជួនកាលពេលរវល់ខ្លាំងនៅក្នុងការបកប្រែ ។ ហើយបើសិនជាយើងគ្មានលទ្ធភាពក្នុងការដាក់ឯកសារទាន់ពេលវេលានោះ គឺថាត្រូវទាក់ទងមកខាងអង្គជំនុំជម្រះ ហើយនឹងត្រូវធ្វើការពន្យល់ឲ្យបានច្បាស់លាស់ ។ ហើយយើងអាចធ្វើការបកប្រែបាន គឺថាពន្យល់បាននោះ ប្រសិនបើយើងត្រូវបានដឹងច្បាស់លាស់ពីពេលដំបូងក្នុងការរៀបចំដាក់បញ្ជូននូវសារណានោះ ។

អ្វីដែលខ្ញុំចង់និយាយថា បើសិនជាមកជួបខ្ញុំនៅម៉ោងពីរនៅថ្ងៃសុក្រ ហើយមានឯកសារម្ភៃទំព័រ ហើយត្រូវឲ្យបកប្រែឲ្យហើយនៅថ្ងៃច័ន្ទនោះ គឺថាពួកខ្ញុំមិនអាចធ្វើបានទេ ។ ប៉ុន្តែ ប្រសិនបើដូចថាលោកមកជួបខ្ញុំនៅថ្ងៃច័ន្ទ ហើយខ្ញុំដូចថា ឯងសារហ្នឹងប្រញាប់ ខ្ញុំនឹងរៀបចំចាត់ចែងក្រុមអ្នកបកប្រែដើម្បីបកប្រែឯកសារនោះឲ្យទាន់ពេលវេលាទៅតាមពេលកំណត់ណាមួយ ប្រសិនបើសិនជាយើងមានលទ្ធភាពក្នុងការធ្វើដូច្នោះ ។

អ៊ីចឹងខ្ញុំចង់ឲ្យភាគីពាក់ព័ន្ធនានាយកចិត្តទុកដាក់ផងដែរទៅលើការចាត់ចែងពេលវេលាសម្រាប់ការបកប្រែឯកសារ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី មីសែល ដែលបានធ្វើការឆ្លើយបំភ្លឺយ៉ាងក្បោះក្បាយ ហើយតបទៅគ្រប់ចំណុចនេះសំណួរដែលពាក់ព័ន្ធ ។ លោក គង់ សុភី មានអ្វីចង់បន្ថែមទេ? បើមិនមានទេ សូមជូនវេទិកាទៅសហព្រះរាជអាជ្ញា ។

សហព្រះរាជអាជ្ញាមានអ្វីចង់កត់សម្គាល់ ឬក៏ចង់សួរពាក់ព័ន្ធទៅនឹងប្រធានបទដែលបង្ហាញដោយមន្ត្រីជាន់ខ្ពស់ផ្នែកបកប្រែភាសានេះទេ? សូមអញ្ជើញលោក ពេទីត ។

**លោក រ៉ូបឺត ពេទីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានការបង្ហាញខ្លីមួយក្នុងការបន្ថែមទៅលើអ្វីដែលខាងគ្រប់គ្រងតុលាការ និងខាងផ្នែកបកប្រែភាសាបាននិយាយ ។ ខ្ញុំចង់និយាយបន្ថែមអំពីស្ថានភាពឯកសារ ដែលខាងការិយាល័យរបស់ខ្ញុំបានស្នើឡើងនោះ ។ អ៊ីចឹង ប្រហែលជាស៊ីពេលដប់នាទី អ្វីដែលខ្ញុំនឹងនិយាយទាក់ទងទៅនឹងការអនុវត្ត និងពេលវេលាដែលយើងបានកំណត់ពេលពីម្សិលមិញ ប្រហែលជាចប់ពេលខ្ញុំធ្វើការបង្ហាញចប់ប្រហែលជាយើងអាចសម្រាកបាន ទៅតាមពេលវេលា ទៅតាមរបៀបវារៈរបស់យើង។

អ៊ីចឹងខ្ញុំគ្រាន់តែធ្វើការសាកល្បងទៅលើភស្តុតាងដែលមាន ប្រព័ន្ធបង្ហាញភស្តុតាងដែលមាននោះដែរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ពេទីត! អនុញ្ញាត ។

អញ្ជើញលោក ពេទីត យើងនៅមានម៉ោង នៅមានពេលដប់មីនុត មុននឹងសម្រាក ។ អ៊ីចឹងសូមលោកធ្វើបទបង្ហាញ សូមអញ្ជើញ លោក ពេទីត ។

**លោក រ៉ូបឺត ពេទីត៖**

សូមអរគុណ ខាងការិយាល័យសហព្រះរាជអាជ្ញារបស់ខ្ញុំគឺជាអ្នកដែលដាក់បន្ទុកធ្ងន់ជាងគេទៅលើការបកប្រែឯកសារ ឬក៏សំណើបកប្រែឯកសារ ។ យើងខ្ញុំគិតថា ហ្នឹងជាអត្ថប្រយោជន៍ណាស់ បើសិន ជាយើងមានភាគីទាំងអស់ពាក់ព័ន្ធ មានវត្តមាននៅទីនេះ ដែលនឹងមានព័ត៌មានបន្ថែមពីលើទៅ

លើអ្វីដែលយើងបានធ្វើ អ្វីដែលយើងមិនចង់ធ្វើ ហើយនិងជាបច្ច័យ ហើយនិងអ្វីដែលនឹងកើតឡើងទាក់ទងទៅនឹងធនធានដែលយើងមាន ។ ការពិតណាស់ អ្វីដែលខ្ញុំនឹងនិយាយក្នុងនេះឯង គឺទាក់ទងតែទៅនឹងផ្នែកការិយាល័យសហព្រះរាជអាជ្ញាទេ ហើយនិងស្ថានភាពរបស់យើងផ្ទាល់ ហើយនិងឯកសារដែលយើងនឹងនិយាយយោង ។ នេះមានន័យថា គឺអាស្រ័យទៅលើអង្គជំនុំជម្រះផងដែរ និងទៅលើមតិយោបល់របស់ភាគីដទៃទៀតនៅពេលដែលយើងបានធ្វើការបង្ហាញជូនរួច ។

អ៊ីចឹងដើម្បីឱ្យអ្នកទាំងអស់គ្នាមានការយល់ដឹងខ្លះអំពីអ្វីជាការពិត ឬក៏ជាទឡ្ហីករណ៍នៅពេលក្រោយ ខ្ញុំនឹងធ្វើការសាកល្បងទៅលើប្រព័ន្ធក្នុងការបង្ហាញភស្តុតាង ។ ខ្ញុំប្រហែលជាហ្នឹងបង្ហាញ*ស្លាយ*ទីមួយ ។

អ៊ីចឹងនេះគឺជាស្លាយទៅមួយ អ្វីដែលមាននៅលើអេក្រង់របស់លោកអ្នកហ្នឹង នេះគឺគ្រាន់តែជាការផ្តល់នូវគំនិតតូចមួយអំពីប្រភេទឯកសារដែលមាននៅក្នុងសំណុំរឿង ។ នេះជាតួលេខទូទៅ ដែលជាការប៉ាន់ស្មានតែប៉ុណ្ណោះ ក៏ប៉ុន្តែមកដល់ពេលនេះយើងធ្វើការវាយតម្លៃថា ប្រហែលជាឯកសារពីរពាន់ប្រាំបីរយដប់ប្រាំដែលមាននៅក្នុងសំណុំរឿង ដែលរួមបញ្ចូលបញ្ចូលទាំងចម្លើយសារភាព ឬក៏សក្ខីកម្មរបស់សាក្សី គឺកំណត់ហេតុនៃការបទសម្ភាសន៍ ដែលខាងការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើនិងចម្លើយ ឬក៏សក្ខីកម្មផ្សេងៗពីមុនមក ។ ហើយនៅក្នុងចំណោមឯកសារទាំងអស់នុ៎ងឯង គឺនៅខាងការិយាល័យរបស់យើងខ្ញុំធ្វើការវាយតម្លៃថា ប្រហែលជាឯកសារចំនួនពីរពាន់ម្ភៃពីរ គឺថាវាទាក់ទងទៅនឹងអង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេច ឬក៏យើងអាចធ្វើការនិយាយថា អ៊ីចឹងនៅក្នុងបទបង្ហាញរបស់យើងនេះឯង គឺទាក់ទងនឹងឯកសារនេះឯង ។

អ៊ីចឹងក្នុងចំណោមឯកសារទាំងពីរពាន់ម្ភៃពីរនោះ សាមសិបមួយភាគរយនៃឯកសារនោះគឺជាផ្នែកមួយនៃសំណុំរឿងពីដើម-- ពីដើមទីមក ហើយហុកសិបប្រាំភាគរយហ្នឹងឯងគឺជាឯកសារដែលបានបញ្ចូលទៅក្នុងសំណុំរឿងនៅពេលក្រោយនុ៎ងឯង ។ មានន័យថា នៅពេលក្រោយមានចេញដីកាដំណោះស្រាយការពីថ្ងៃ២៨ ខែ៥ ឆ្នាំ២០០៨ ហើយចំនួនតូចមួយនៃចំនួននោះ គឺបាន-- នៅពេលដែលដីកាដំណោះស្រាយបានចេញហើយ ភាគច្រើនហ្នឹងឯងគឺជាប្រតិចារឹកដែលបានដាក់បញ្ចូល ។ មានន័យថា អ្វីដែលខាងការិយាល័យរបស់យើងខ្ញុំបានព្យាយាមដាក់បញ្ចូលជាភស្តុតាងនោះ គឺខ្ញុំនឹងធ្វើការបង្ហាញឱ្យបានច្បាស់លាស់អំពីគោលបំណងរបស់ការិយាល័យសហព្រះរាជអាជ្ញារបស់យើងខ្ញុំទៅតាមកាលបរិច្ឆេទដែលមានកំណត់នៅពេលខាងមុខ ។

នេះគឺជា*ស្លាយ*ទីពីររបស់យើងខ្ញុំ ដើម្បីផ្តល់បន្ថែមទៀតអំពីការបង្ហាញអំពីឯកសារអស់ទាំងនុ៎ង ក្នុងចំណោមឯកសារពីរពាន់ម្ភៃពីរនោះ ហាសិបបីភាគរយ គឺនៅដំណាក់កាលណាមួយគ្រាន់តែជាឯកសារយោង មានន័យថា វាមាននៅក្នុងចុងទំព័រ ហើយនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬក៏នៅក្នុងដីកាដំណោះស្រាយ ។ ហើយជាការពិតណាស់ នេះគ្រាន់ជាការបង្ហាញតែប៉ុណ្ណោះដែលខាងភាគីពាក់ព័ន្ធនានាគួរតែកត់សម្គាល់ទៅលើប្រភេទឯកសារទាំងនេះ ហើយនៅពាក់កណ្តាលហ្នឹងឯងនៅលើស្លាយហ្នឹងឯងគឺ ក្នុងចំណោមឯកសារយោងទាំងអស់នុ៎ង គឺឯកសារចំនួនប្រាំមួយ ឬម្ភៃប្រាំបីត្រូវបានដាក់បញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររួចហើយ ។ អញ្ចឹង ឯកសារចំនួន៧៩១ទៀត នៅក្នុង*ហ្វាណល សាប់មីសស៊ិន* នោះ ហើយនិងមានមួយភាគរយ គឺមាននៅក្នុងដីកាដំណោះស្រាយ ។

អ៊ីចឹង ចូលដល់ចំណុចទីបី គឺថាទាក់ទងទៅនឹងអ្វីដែលជាសុបិនអាក្រក់ ដែលនឹងអាចកើតមានទាក់ទងទៅនឹងខាងផ្នែកបកប្រែឯកសារ ។ នេះគឺជាស្លាយទីបី ។ អ៊ីចឹង ក្នុងចំណោមឯកសារទាំងអស់ដែលថាយើងព្យាយាមនឹងនិយាយអំពីនោះ ដែលមានទាក់ទងទៅនឹងវិធាន៩២ ទាក់ទងទៅក្នុងការបញ្ជូនឯកសារនោះ ។ ដំបូងបង្អស់គឺ នៅក្នុងក្រុមទីមួយនិងក្រុមទីពីរគឺបង្ហាញអំពីចំនួន គឺថាជាឯកសារចំនួន ២០០ គឺកំណត់ហេតុសម្ភាសន៍របស់សាក្សីជាទូទៅ ។ នេះមិនមែនជាកំណត់ហេតុសម្ភាសន៍សាក្សីទេ ក៏ប៉ុន្តែយើងបានស្នើឱ្យមានការបកប្រែនូវៗបទចម្លើយ ឬក៏សក្ខីកម្មពីមុនដែលសាក្សីបានផ្តល់ជូន ឬក៏ដែលបុគ្គលឯកជនណាមួយបានផ្តល់ជូនមកឱ្យការិយាល័យរបស់យើងខ្ញុំ ។

មានន័យថា គឺថាយើងបានស្នើឱ្យបកប្រែឯកសារអស់ទាំងនេះ ដែលជាសក្ខីកម្ម ឬក៏សេចក្តីថ្លែងការណ៍របស់សាក្សី ឬក៏អ្នកដែលនឹងអាចក្លាយទៅជាសាក្សីនៅក្នុងសំណុំរឿង ។ ដូច្នេះ ហើយគឺថាខាងផ្នែកជំនុំជម្រះហ្នឹង នឹងអាចមានលទ្ធភាពពិនិត្យមើលឯកសារអស់ទាំងនេះ ដោយយើងគិតថាវាជាឯកសារសំខាន់សម្រាប់ការបង្ហាញអំពីការពិត ។

នៅខាងផ្នែកខាងស្តាំដៃហ្នឹងឯង គឺថាឯកសារដែលសំណើបកប្រែហ្នឹងឯងបានចេញ បានស្នើដែលថា ម្ភៃប្រាំ ខែប្រាំមួយ និងនៅថ្ងៃទីដប់បួន ខែវិច្ឆិកា សូន្យប្រាំបីហ្នឹង ។ ហើយបានស្នើឱ្យបញ្ជូនទៅលើភាសាដែលយើងចាំបាច់នោះ ។ ហើយការបកប្រែទាំងអស់គួរតែមានសម្រាប់ភាសាការងារទាំងអស់ គឺខ្មែរ អង់គ្លេស និងបារាំង ។

នៅក្នុងក្រុមទី-- មួយក្រុមទៀតហ្នឹងឯង គឺក្រុមបី ក្រុមបួន និងក្រុមប្រាំ ដែលជាផ្នែកកណ្តាល

នៃស្លាយនេះ ដែលមានន័យថាឯកសារភាគច្រើននៅក្នុងក្រុមនេះ ។ នៅក្នុងក្រុមទីបី ហើយនិងក្រុមទីប្រាំ សូមពិនិត្យមើលក្រុមបីនិងក្រុមប្រាំ ។ ក្រុមបីគឺឯកសារភាគច្រើននោះ ដែលកៅសិបប្រាំភាគរយ គឺជាឯកសារបើកចំហ ឬក៏ជាការរាយករណ៍ពីខាងផ្នែកសារព័ត៌មានជាដើម ។ មានន័យថា ជាប្រភេទឯកសារផ្សេងៗដែលជាឯកសារចំហ ដែលបានលើកឡើងអំពី-- ការលើកឡើងអំពីថានៅពេលនោះឯងថានឹងមានជម្លោះប្រដាប់អាវុធ នៅក្នុងអំឡុងពេលនោះជាមួយនឹងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ។

បើសិនជាយើងបានធ្វើការទទួលការណែនាំ ហើយយើងបានធ្វើការពិភាក្សាគ្នាជាមួយខាងផ្នែកមេធាវីការពាក្តី ដើម្បីធ្វើកំណត់ចំនួនអប្បបរិមាអំពីឯកសារដែលយើងបានធ្វើការបកប្រែ ឬក៏ស្នើធ្វើការបកប្រែ ហើយនិងពិនិត្យមើលថាតើឯកសារណាដែលជាឯកសារអាទិភាព បើសិនជាមាន ហើយឬក៏ដែលមានការចាំបាច់ឲ្យមានការបកប្រែនោះ ។

ជាការពិតណាស់ នៅពេលដែលយើងបានធ្វើការពិភាក្សាគ្នា មិនមែនមានន័យថាជាការពិភាក្សាដែលចងទៅចងទៅលើភាគីណាមួយនោះទេ ។ ហើយយើងក៏មានបំណងផងដែរ បានឯកភាពថាឯកសារអស់ទាំងនោះ គឺមានន័យថា របាយការណ៍នៅក្នុងសារព័ត៌មាន ឬក៏ដើម្បីបង្ហាញ ឬក៏គាំទ្រ ឬក៏បង្ហាញអំពីការពិតនោះ ប្រហែលជាខាងផ្នែកមេធាវីការពារក្តីគាត់មិនយល់ថាមានចំណាប់អារម្មណ៍ក្នុងការបកប្រែឯកសារទាំងនោះទេ ពីព្រោះភាគច្រើននោះឯង គឺភាគច្រើនជាភាសាអង់គ្លេស ដែលជាភាសាដើមនៃឯកសារទាំងនោះ ។

នៅក្នុងក្រុមទីប្រាំនៃឯកសារអស់ទាំងនោះ គឺបង្ហាញអំពីឯកសារចំនួន៧៩៨ឯកសារ គឺជាឯកសារដែលយើងចាត់ទុកថាជាឯកសាររបស់មន្ទីរស-២១ ពីព្រោះភាគច្រើនឯកសារអស់ទាំងនោះ ឬក៏ឯកសារទាំងអស់នោះឯង គឺមានន័យថា បានចេញមកពីប្រតិបត្តិការនៃមន្ទីរស-២១ ។ ហើយប្រហែលជាហុកសិបភាគរយនៃឯកសារទាំងនុំង គឺជាបញ្ជីអ្នកទោស ឬក៏នីតិវិធីក្នុងការបញ្ជូន ឬក៏បញ្ចូលអ្នកទោសទៅក្នុងមន្ទីរស-២១នោះ និងរបាយការណ៍ផ្សេងៗពាក់ព័ន្ធនឹងមន្ទីរស-២១ ដែលជាគោលការណ៍ មានន័យថានេះគឺជាឯកសារដើម ឯកសារដើមនៅក្នុងមន្ទីរ ។

ហើយអ្នកទាំងអស់គ្នាដែលគួរកត់សម្គាល់ នេះគឺជាឯកសារគ្រឹះស្ថាន ជាមូលដ្ឋានដែលយើងបានព្យាយាមប្រើ ក្នុងការកសាងនូវបញ្ជីអ្នកទោសនៅក្នុងមន្ទីរស-២១ ។

ជាថ្មីម្តងទៀត នេះគឺជាឯកសារសំណៅដើម ហើយចំណោមឯកសារ៧៩៨ហ្នឹង អាភាគចុងក្រោយគេហ្នឹងឯង គឺជាឯកសារដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃប្រតិបត្តិការរបស់ស-២១ ។

ហើយដែលយើងបានលើកឡើងថានឹងមានឯកសារបន្ថែម ឬក៏ចំណារដៃរបស់ជនជាប់ចោទនេះ ឬក៏ចំណារដៃទាក់ទងអំពីដំណើរ ឬក៏ប្រតិបត្តិការរបស់ស-២១ ទាក់ទងទៅនឹងក្បាលម៉ាស៊ីនសន្តិសុខជាដើម ។

ទាក់ទងទៅនឹងបញ្ជីអ្នកទោសៗនោះ គឺថាយើងមានការព្រមព្រៀងគ្នាដែលថា ខាងក្រុមមេធាវីការពារក្តី មិនចាំបាច់ធ្វើការបកប្រែឯកសារនេះទៅជាភាសាបារាំងទេ ។ អ៊ីចឹងនេះគឺអាស្រ័យទៅលើការពិភាក្សាដែលយើងបានធ្វើជាមួយនឹងខាងក្រុមមេធាវីការពារក្តី ។

នៅក្នុងក្រុមទីបួន ដែលមានចំនួនឯកសារចំនួន៤៧១ ការដែលឯកសារនេះភាគច្រើនគឺយើងអះអាងថា ជាឯកសារដើម្បីធ្វើការបង្ហាញនូវការពិត អំពីរចនាសម្ពន្ធរបស់កម្ពុជាប្រជាធិបតេយ្យនៅពេលដែលព្រឹត្តិការណ៍កើតមានឡើងនោះ ។

អ៊ីចឹង ឯកសារអស់ទាំងហ្នឹងភាគច្រើនគឺមានជាភាសាខ្មែរ ហើយមានឯកសារដែលយើងបានអះអាងថា បានកើតមានឡើងទៅតាមកម្រិតផ្សេងៗគ្នានៃរចនាសម្ពន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ហើយយើងបានស្នើឲ្យធ្វើការបកប្រែ ។ ហើយភាគច្រើនបំផុតនោះគឺបកប្រែជាពីរភាសាផ្លូវការរបស់សាលាក្តីនេះ ។ គឺអាស្រ័យទៅលើសំណើដែលភាគីផ្សេងៗអាចនឹងលើកឡើង ឬក៏ស្នើឲ្យធ្វើការបកប្រែផងដែរនោះ ឬក៏អាស្រ័យទៅលើការពិភាក្សារបស់យើងជាមួយភាគីផ្សេងៗនៅក្នុងពេលអនាគត ។

នៅក្នុងក្រុមទីប្រាំមួយ គឺជារូបថត ឬក៏រូបភាព ឬក៏*វីដេអូ* ដែលមានជារូបរាងដែលមានបញ្ចូលរួចស្រេចនៅក្នុងសំណុំរឿង ។ មានន័យថា ក្រុមប្រាំមួយនេះមិនចាំបាច់មានត្រូវការការបកប្រែអ្វីទេ ។ ទោះបីជាមានការបកប្រែសំឡេង កំណត់ហេតុសំឡេងខ្លះ ឬក៏*វីដេអូ*ខ្លះ ។

ក្រុមទីប្រាំពីរ ដែលមានពីរភាគរយនៃឯកសារអស់ទាំងនោះ គឺជាឯកសារផ្សេងៗទៀត ដែលមាននៅក្នុងសំណុំរឿងដែលបានដាក់បញ្ចូលរួចហើយនោះ សម្រាប់ការស្វែងរកការពិតនៅក្នុងអង្គជំនុំជម្រះរបស់យើងនេះ ។ ដូចដែលខ្ញុំបាននិយាយពីមុនមកអ៊ីចឹង នេះគឺជាការបង្ហាញអំពីស្ថានភាពរបស់ការិយាល័យរបស់យើងខ្ញុំ ហើយទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះផងដែរ គឺថាយើងបានអញ្ជើញនិងបានចូលរួម ហើយយើងនឹងព្យាយាមៗធ្វើបន្តទៀតទៅតាមលទ្ធភាព ដើម្បីកម្រិតការដាក់បន្ទុកសំណើបកប្រែទៅលើខាងផ្នែកបកប្រែឯកសារនិងបកប្រែផ្ទាល់មាត់ ។ ហើយយើងក៏បានព្យាយាម ហើយនិងព្យាយាមផងដែរ ទៅតាមសមត្ថភាពរបស់យើងដែលយើងមាន ឬទាក់ទងទៅនឹងភាគីផ្សេងៗទៀត ដើម្បីព្យាយាមសម្រេចឲ្យបាននូវប្រសិទ្ធភាពជាអតិបរិមាទាក់ទងទៅនឹងសំណើបក

ប្រែឯកសារ ដើម្បីជាសេចក្តីសង្ឃឹមថា គឺថាយើងអាចកំណត់នូវកាលបរិច្ឆេទឲ្យកាន់តែឆាប់សម្រាប់សវនាការ ហើយនិងការបញ្ចប់ការបកប្រែឯកសារនៅពេលនុំងដែរ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ពេទីត ដែលបានធ្វើបទបង្ហាញចែកជូនអង្គប្រជុំអំពីស្ថានភាពនៃឯកសារនៅការិយាល័យសហព្រះរាជអាជ្ញា ។ ហើយដោយសារពេលវេលាច្រើនហើយ ហើយអ៊ីចឹង ពេលនេះម៉ោងដប់សាមសិបប្រាំនាទី អ៊ីចឹងខ្ញុំសូមអនុញ្ញាតអង្គពិធីប្រកាសសម្រាករយៈពេលដប់ប្រាំមីនុត គឺរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញអស់លោក លោកស្រី នាងកញ្ញាចូលមកក្នុងសាលប្រជុំវិញ ដើម្បីបន្តកិច្ចប្រជុំរបស់យើងតទៅទៀត ។ ហើយនិងសូមរំឭកផងដែរថា លោក ថារីក មន្ត្រីជាន់ខ្ពស់នៃ*ស៊ីអ៊ឹមអេស* សូមចាត់ចែងនូវរបៀបចាត់វិធានការការពារជូនអង្គប្រជុំបានឃើញនាពេលសម្រាកនេះ ។

*(កិច្ចប្រជុំសម្រាកពីម៉ោង១០:៤១ ដល់ម៉ោង ១០:៥៧ នាទី)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអស់លោក លោកស្រីចូលកាន់ទីកន្លែង ហើយយើងបន្តកិច្ចប្រជុំរបស់យើងតទៅទៀត។

សូមអធ្យាស្រ័យដែរ ដោយសារបច្ចេកទេសនិងឧបករណ៍ដែលត្រូវយកមកបង្ហាញនោះ មានធ្ងន់ ហើយនៅខាងក្រោមឯណោះ ។

ឥឡូវនេះ យើងចាប់ផ្តើមបន្តកិច្ចប្រជុំរបស់យើងតទៅទៀត ។ ហើយក៏សុំអធ្យាស្រ័យផងដែរ អម្បាញ់មិញនេះខ្ញុំបានបង្ហាញ ជម្រាបជូនទៅអង្គប្រជុំថា នឹងមានបទបង្ហាញមួយស្តីពី "របាំង ការប្រើប្រាស់របាំងដើម្បីការពារសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលវិធានការការពារ ។ ប៉ុន្តែបញ្ហានេះ គឺដោយសារហេតុផលនៃសម្ភារៈ ឬក៏បច្ចេកទេសដែលត្រូវចំណាយពេលវេលាយូរ អ៊ីចឹងគឺយើងមិនអាចធ្វើនាពេលនេះបានទេ ។ ប៉ុន្តែខាងគ្រប់គ្រងតុលាការ លោកមានផែនការ និងមានកាលបរិច្ឆេទដែលត្រូវនៅសប្តាហ៍ក្រោយនេះ ដើម្បីអញ្ជើញភាគីដែលពាក់ព័ន្ធ ដែលមានបំណងចង់ដឹង ចង់ឃើញនូវរបៀប ឬក៏នីតិវិធីនៃការចំណាត់ការ ចាត់វិធានការការពារចំពោះសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលការការពារនៅក្នុងសវនាការនោះ លោកនឹងត្រៀមរៀបចំ នៅក្នុងសប្តាហ៍ក្រោយ និងពេលវេលាជាបន្តបន្ទាប់ទៀត ទៅតាមស្ថានភាពជាក់ស្តែង ។

ហើយជាកិច្ចបន្តគឺ ដោយសារមានការពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់ខាងអ្នកបកប្រែភាសាផង ហើយពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់លោក ពើទីត សហព្រះរាជអាជ្ញាផង ។ វេទិកាបន្តនេះគឺសូមជូនវេទិកានេះទៅអង្គប្រជុំថាតើមានសំណួរ ឬក៏មានការកត់សម្គាល់អ្វីទេ ពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់លោក ពើទីត សហព្រះរាជ្ញា ដែលបានបង្ហាញអម្បាញ់មិញនេះ?

បើមានគឺនឹងអនុញ្ញាត ដើម្បីពាក់ព័ន្ធនឹងបទបង្ហាញរបស់លោក ពើទីត ។

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ តាមពិតលោក រ៉ូប៊ីត ពើទីត លោកបានលើកឡើងយ៉ាងច្បាស់លាស់អំពីបញ្ហា ឬក៏ទំហំនៃការបកប្រែ ។ លោកអាចជម្រាបយើងខ្ញុំបានទេ ថាតើឯកសារទាំងអស់នេះមានឯកសារប៉ុន្មានហើយដែលត្រូវបានបកប្រែ ហើយឬក៏មិនទាន់បានបកប្រែសោះទេ គឺឯកសារពីរពាន់ម្ភៃពីរឯកសារ ដែលបានបង្ហាញមិញនេះ?

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណ ។ ដូចខ្ញុំបានជម្រាបហើយឯកសារក្រុមបី បួន ប្រាំហ្នឹង សូមឲ្យបញ្ចាំង *ស្លាយ* ដដែលនេះឡើងវិញ គឺទាក់ទងចំណុចបី បួន ប្រាំ មិញនេះ បើសិនអាចធ្វើបាន ។ សូមអញ្ជើញ ។

នៅក្នុងនេះគឺយើងឃើញហើយមានសំណើគេស្នើបាន កាលពីថ្មីៗនេះ ហើយយើងមើលឃើញថ្ងៃប្រាំមួយ ខែមករា នេះគឺជាកាលបរិច្ឆេទដែលគេចុះក្នុងនេះ ។ ហើយខ្ញុំបានជម្រាបហើយ ឯកសារភាគច្រើននៃឯកសារទាំងអស់នេះ គឺមិនចាំបាច់ត្រូវការបកប្រែជាភាសាបារាំងទេ លើកលែងតែជនត្រូវចោទ ឬក៏ក្រុមមេធាវីគាត់ស្នើឲ្យបកតែប៉ុណ្ណឹង ។

នៅក្នុងនេះ ទំហំនៃឯកសារទាំងស្រុង-- នៅក្នុងនេះទាក់ទងជាមួយនឹងឯកសារទាំងមូលតែម្តងហ្នឹង គឺដូចលោកស្រីបានឃើញហើយ នៅក្នុងក្រុមមួយនិងក្រុមពីរហ្នឹង គឺគេបានស្នើឲ្យបកប្រែខែមិថុនានិងខែធ្នូឆ្នាំទៅ ។ ហើយខ្ញុំគិតថា ប្រហែលជាខាង *ស៊ីអ៊ីមអេស* បានបកប្រែយ៉ាងហោចណាស់ក៏ផ្នែកខ្លះនៃឯកសារទាំងអស់នោះ ឬក៏អាចបកហើយបាត់ទៅហើយ ។

ហើយគាត់ថា បើមិនទាន់បកអស់ទេ ក៏គេកំណត់ឲ្យបកហើយនៅខែកុម្ភៈ នៅថ្ងៃ២៨ កុម្ភៈ ។ ហើយឯកសារទាំងអស់នេះ គឺឯកសារពីរពាន់ម្ភៃពីរឯកសារនេះ ដែលខ្ញុំបានលើកឡើងរួចហើយនេះ គឺជាឯកសារពាក់ព័ន្ធជាមួយនឹងសាក្សី ហើយអ៊ីចឹងគឺមិនចាំបាច់ត្រូវបកប្រែទៅជាបីភាសានោះទេ ។

កាលពីឆ្នាំទៅ គឺយើងបានសួរថាតើឯកសារហ្នឹងបានធ្វើរួចហើយឬនៅ? ក៏ប៉ុន្តែ មើលទៅគឺឯកសារទាំងអស់ ដែលយើងគិតថាមិនចាំបាច់ឲ្យបកប្រែទាំងអស់នោះ គឺមានឯកសារដូចនៅគុក អេស *ធ្វេនធីវ័ន(S-21)* ។ ជាពិសេស ទាក់ទងជាមួយនឹងឯកសាររឿងជម្លោះប្រដាប់អាវុធអីហ្នឹង គឺខ្ញុំគិតថាមិនចាំបាច់បកប្រែឲ្យអស់ទេ ជាបីភាសាទេ ។

ហើយឯកសារម្ភៃពីរឯកសារទៀតហ្នឹងគឺ ទាក់ទងជាមួយនឹងឯកសារដែលចង់ឲ្យអង្គជំនុំជម្រះយកមកពិនិត្យទាក់ទងជាមួយនឹងបទឧក្រិដ្ឋ និយាយពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាង ហើយនិងបទឧក្រិដ្ឋដែលពាក់ព័ន្ធជាមួយនឹង ស-២១ ហ្នឹង ។

ហើយយើងបានមានសំណើទាំងអស់នោះហើយ ហើយខ្ញុំដឹងហើយពាក់ព័ន្ធជាមួយនឹងឯកសារដែល-- គ្រាន់តែចង់ឲ្យតុលាការមានការយកចិត្តទុកដាក់ទៅលើឯកសារនេះ ហើយភាគីក៏អាចមានការជំទាស់ ឬក៏យ៉ាងម៉េចទាក់ទងវិធានរឿងឯកសារដែលមានច្រើនពេក ឬក៏មិនពាក់ព័ន្ធទាំងស្រុងនោះអាចមិនយកមកប្រើ ។ ហើយខ្ញុំខ្លាចក្រែងលោមានបញ្ហារាំងស្ទះដល់ការបកប្រែនៅក្នុងពេលជំនុំជម្រះហ្នឹង គឺបានន័យថា ឯកសារត្រូវតែស្នើឲ្យហើយពីមុននឹងពេលសវនាការ ព្រោះយើងអត់ចង់ឲ្យរឿងហ្នឹងទៅកើតឡើងជជែកគ្នា ពេលដល់សវនាការហើយ បានលើកឡើងបញ្ហាបកប្រែហ្នឹងទេ នាំឲ្យមានការរាំងស្ទះ ។ អ៊ីចឹងបានថាយើងត្រូវតែពិនិត្យមើល និងវិភាគថាតើឯកសារណាខ្លះយើងត្រូវបកប្រែហើយអ៊ីចឹងយើងមើលដឹងមុនហើយ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ៖**

សូមអរគុណលោកពើទីត ។

**ប្រធានអង្គជំនុំ៖**

មិញគឺពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់ខាងអ្នកបកប្រែ ខាងអង្គភាពបកប្រែភាសា ។ នៅមេធាវីការពារជនជាប់ចោទមិនទាន់មានសំណួរ ឬក៏កត់សម្គាល់អ្វីទេ ពាក់ព័ន្ធនឹងបទបង្ហាញនេះ ។ ហើយទន្ទឹមនឹងនេះដែរ គឺមានទាំងបទបង្ហាញរបស់លោកពើទីត ផង ។ ប្រសិនបើមាន សូមអញ្ជើញមេធាវីការពារជនជាប់ចោទ ប្រសិនបើមាន ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានមតិយោបល់មួយចំនួន ហើយក៏មានសំណួរផងដែរ ។ តាមពិតយើងទាំងអស់គ្នាសុទ្ធតែបានដឹងគ្រប់ៗគ្នាហើយ អំពីការពិតថា បញ្ហាការបកប្រែផ្ទាល់មាត់ និងបក

ប្រែភាសាគឺជា--វាឯកសារគឺជាភាសា-- បញ្ហាធំណាស់ មិនមែនតែនៅស្រុកខ្មែរទេ គឺនៅសាលាក្ដីអន្តរជាតិផ្សេងៗទៀត ទាក់ទងជាមួយឧក្រិដ្ឋកម្មហ្នឹង គឺមានដូចគ្នា ។

ខ្ញុំអាចនិយាយថា ទាក់ទងជាមួយនឹងបញ្ហាទំនាក់ទំនងគ្នានេះគឺ យើងឃើញថា អ្វីដែលសំខាន់នៅទីនេះ គឺអ្វីដែលយើងត្រូវយល់អំពីអ្វីដែលយើងបានដឹង ។ ជាពិសេស គឺមិនមែនទាក់ទងចំនួនទំហំឯកសារទេ តែទាក់ទងជាមួយនឹងការដែលយើងអាចឲ្យជនណាម្នាក់បានយល់អំពីឯកសារហ្នឹងដែលមាន ដែលបានទៅដល់ដៃគាត់ ។

ហើយខ្ញុំទាក់ទងជាមួយនឹងក្រុមបកប្រែភាសា និងបកប្រែផ្ទាល់មាត់នេះគឺយើងដឹងហើយថានៅក្នុងកិច្ចដំណើរការនីតិវិធីរបស់យើងគឺ យើងដូចធ្លាប់ស្នើអ៊ីចឹង គឺយើងទទួលស្គាល់ថាយើងត្រូវតែនិយាយឲ្យយឺត ហើយខ្ញុំសូមគោរពនូវអ្នកបកប្រែភាសាទាំងអស់ហ្នឹង ។ ហើយយើងខ្ញុំក៏ត្រូវតែនិយាយឲ្យយឺតដើម្បីគោរពដល់អ្នកដែលស្ដាប់យើងផងដែរ ។

នៅពេលដែលខ្ញុំធ្វើការនៅសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិ យើងមានសិក្ខាសាលាមួយដែលគេរៀបចំជាមួយគ្នា ជាមួយនឹងផ្នែកខាងបកប្រែភាសា ។ ហើយជាទូទៅក្នុងកិច្ចប្រជុំនេះគឺ គេលើកឡើងអំពីបញ្ហាទាក់ទងជាមួយនឹងផ្នែកបកប្រែផ្ទាល់មាត់ ឬបកបណ្ដោញនេះ ។ ហើយធម្មតានៅក្នុងនេះ គឺដូចខ្ញុំជម្រាបហើយ គឺសូម្បីតែអ្នកបកប្រែជំនាញយ៉ាងម៉េចក៏ដោយ គឺសារដែលត្រូវបកហ្នឹង គឺបាត់ម្ភៃប្រាំភាគរយហើយ ហ្នឹងសូម្បីតែយើងបកប្រែផ្ទាល់ផង ។ អ៊ីចឹងលោកចៅក្រម ឬក៏អ្នកចូលរួមទាំងអស់ត្រូវចងចាំថា មិនចំពោះថាយើងពូកែប៉ុនណាទេ គឺបកបានត្រឹមតែចិតសិបប្រាំភាគរយពីខ្លឹមសារដើមទេ ។

អ៊ីចឹងនៅក្នុងន័យនេះ ខ្ញុំក៏សូមអរគុណផងដែរ ហើយខ្ញុំអរគុណអ្នកដែលផ្ដល់សេវាបកប្រែឯកសារហ្នឹងផ្ទាល់មាត់ ។ ខ្ញុំសូមជម្រាបថា តាំងតែពីដើមដំបូងមកម្ល៉េះ នៅក្នុងកិច្ចដំណើរការនីតិវិធីតាំងពីកិច្ចដំណើរការស៊ើបអង្កេត គឺយើងឃើញមានការទទួលបានផលជាដុំកំភួនច្រើនណាស់នៅក្នុងផ្នែកបកប្រែនេះ ។

ក៏ប៉ុន្តែយើងនៅមានរឿងច្រើនទៀត ដែលត្រូវបំពេញផងដែរ ដែលនៅមិនទាន់បានបំពេញនៅឡើយ ។ ហើយមែនទែនខ្ញុំ មិនមែនតែជនជាតិបារាំងម្នាក់នៅក្នុងតុលាការនេះទេ នៅក្នុងបន្ទប់នេះទេ គឺយើងមានអ្នកនិយាយភាសាបារាំង ដូចជានៅខាងដើមបណ្ដឹងរដ្ឋប្បវេណីក៏មានជនជាតិបារាំង ។ ហើយសូម្បីនៅលើវេទិកាលោកចៅក្រមក៏មានលោកចៅក្រមបារាំងដែរ ។ អ៊ីចឹងនៅក្នុងចំណុចនេះ ពេលដែល

ខ្ញុំបានធ្វើការជាមួយអង្គជំនុំជម្រះនេះជិត វាជាងពីរឆ្នាំទៅហើយ ក៏ប៉ុន្តែខ្ញុំមានការដូចជាសោកស្តាយដែរ ដែលមិនការបកប្រែដោយផ្ទាល់ពីបារាំងទៅខ្មែរតែម្តង ។

ហើយចំពោះខ្ញុំ ខ្ញុំចង់លើកបញ្ជាក់ម្តងទៀតថា ចំណុចនេះមិនអាចទទួលយកបានទេ ។ ហើយខ្ញុំ ហើយសូមទាមទារឲ្យធ្វើយ៉ាងណាដោះស្រាយបញ្ហានេះឲ្យបាន បើអាចធ្វើទៅបាន គឺយើងធ្វើឲ្យប្រញាប់ ព្រោះអីបើមិនអ៊ីចឹងយើងនឹងមានបញ្ហាហើយទាក់ទងជាមួយនឹងការដែលយើងចង់ឲ្យបានការជំនុំជម្រះ ឲ្យបានយុត្តិធម៌នោះ ។ ព្រោះនៅក្នុងនេះ ខ្ញុំចង់ជម្រាបផងដែរទៅខាងអ្នកគ្រប់គ្រងផ្នែកតុលាការ គឺបាន ន័យថា អ្នកឯងត្រូវរកឲ្យបានទាន់នូវអ្នកប្រែភាសាបារាំង-ខ្មែរ ខ្មែរ-បារាំង ដែលអាចបកប្រែផ្ទាល់ពី ក្នុងសវនាការឲ្យបានក្នុងដំណើរការខាងមុខនេះ ។

ហើយពាក់ព័ន្ធជាមួយនឹងបញ្ហានៃការបកប្រែឯកសារវិញ ហើយនិងទំហំនៃឯកសារបកប្រែនេះ ខ្ញុំមែនទែន ខ្ញុំដឹងច្បាស់ណាស់អំពីសម្ពាធ ដែលយើងមានកំពុងដាក់ទៅលើក្រុមអ្នកបកប្រែឯកសារនោះ។ ក៏ប៉ុន្តែនៅទីនេះក៏ខ្ញុំ***សុំ***សួរអ្នកខាងបកប្រែភាសាផងដែរ ថាតើអ្វីដែលយើងមាននៅពេលនេះ តើបញ្ហាអ្វី ខ្លះដែលយើងកំពុងធ្វើសព្វថ្ងៃនេះ?

ហើយនៅក្នុងចំណុចនេះគឺ យើងមែនទែន--មិនៗ គឺជាអង្គជំនុំជម្រះមួយ ឬក៏សាលាក្តីមួយ ដែលទទួលខុសត្រូវក្នុងការស្វែងរកយុត្តិធម៌ ។ ហើយការដែលខ្វះខាតសព្វបែបយ៉ាងនៅក្នុងទីនេះ គឺ យើងអាច ជាពិសេសគឺយើងឃើញហើយ គឺខ្វះខាតក្នុងផ្នែកបកប្រែឯកសារ ក៏ដូចបកប្រែផ្ទាល់មាត់ ។ ហើយនិយាយទៅ ព្យសនកម្ម ឬក៏ផលវិបាកនៃបញ្ហានេះគឺយើងមើលឃើញមានផលប៉ះពាល់ធំធេង ណាស់ទៅដល់ជនត្រូវចោទ ។

ហើយខ្ញុំសុំទោស ប្រសិនជាខ្ញុំលើកចំណុចនេះម្តងទៀត ក៏ប៉ុន្តែខ្ញុំគិតថា គឺជាភារៈរបស់ខ្ញុំ ក្នុង នាមជាមេធាវីការពារកូនក្តីខ្ញុំ ។ ខ្ញុំត្រូវតែទាមទារ ហើយនិងជម្រាបបញ្ជាក់ថានេះគឺជាសាលាជំនុំជម្រះ ក្តី ។

ឥឡូវខ្ញុំមានចំណាប់អារម្មណ៍យ៉ាងក្រៃលែងទាក់ទងជាមួយនឹងសហការីរបស់ខ្ញុំគឺ មីស្ទ័រ រ៉ូប៊ីត ពេទីត ដែលគាត់លើកឡើងអំពីឯកសារផ្សេងៗ បង្ហាញជូននៅក្នុងកិច្ចប្រជុំនេះ ។ ហើយខ្ញុំសូមស្នើកុំ ឲ្យនិយាយពីតែចំនួនឯកសារ បំណែកឯកសារ យើងនិយាយពីទំព័រឯកសារផង ដើម្បីឲ្យយើងដឹងច្បាស់ ព្រោះថាតើ តើយើងដឹងថាទំហំទំព័រនោះវាមានប៉ុន្មានរយពាន់សន្លឹក ដែលយើងដឹងទំហំ ។ ព្រោះអីនេះ គឺយើងដឹងហើយខាងមេធាវីការពារក្តី គឺកំពុងតែប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់ខ្លួន នៅក្នុងការ

ដែលជួយសម្រួលការងាររបស់យើង ។ ហើយនៅពេលដែលក្រុមមេធាវីការពារក្តីថាយើងមិនទាមទារឱ្យមានការបកប្រែឯកសារដែលពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធហ្នឹង គឺយើងបង្ហាញពីចេតនាល្អរបស់យើងថាដោយសារមិនចង់ឱ្យដាក់បន្ទុកខ្លាំងពេកទៅលើខាងអ្នកបកប្រែឯកសារ ។ ក៏ប៉ុន្តែ ក្នុងនេះក៏ខ្ញុំសុំសួរទៅខាងសហព្រះរាជអាជ្ញា លោកក៏គួរធ្វើដូចយើងផងដែរ សួរថាតើ សួរថាខាងសហព្រះរាជអាជ្ញាហ្នឹងចាំបាច់អីត្រូវការឱ្យបកប្រែឯកសារដល់ទៅ៤២៩ឯកសារ ដើម្បីគ្រាន់តែបញ្ជាក់អំពីជម្លោះប្រដាប់អាវុធដែលមាន ហើយខ្ញុំដឹងថាតើសហព្រះរាជអាជ្ញា-- ការិយាល័យរបស់គាត់ហ្នឹងគិតតែចង់ឱ្យចម្លើយសារភាពនៅមន្ទីរស-២១ទាំងអស់ហ្នឹងត្រូវតែបកឱ្យអស់ បានអាចនឹងរកឃើញអំពីការទទួលខុសត្រូវរបស់កូនក្តីខ្ញុំបាន ឬក៏យ៉ាងម៉េច? ឬក៏ជនជាប់ចោទបានឬក៏យ៉ាងម៉េច?

ហើយជាមួយគ្នានេះផងដែរ ខ្ញុំគិតថាដូចជាមិនចាំបាច់ត្រូវតែដាក់បន្ទុកឱ្យកាន់តែធ្ងន់ជាងហ្នឹងទៅទៀតទៅលើខាងផ្នែកបកប្រែឯកសារទេ ព្រោះខ្លួនគាត់សព្វថ្ងៃហ្នឹងកំពុងតែមានឯកសារសន្ធឹកសន្ធាប់ដែលត្រូវបកប្រែទៅហើយ ។ អ៊ីចឹង នៅពេលដែលមេធាវីការពារក្តីបានជួយបន្ថយបន្ទុកខាងអ្នកបកប្រែអ៊ីចឹងខាងសហព្រះរាជអាជ្ញាក៏គួរតែធ្វើដូចគ្នាផងដែរ ។

ហើយយើងមែនទែនបានជជែកគ្នាហើយថា មិនចង់ឱ្យបកប្រែ ឯកសារទៅជាភាសាបារាំងរឿងជម្លោះប្រដាប់អាវុធនោះទេ ។ ក៏ប៉ុន្តែ ឯកសារ៤២៩ឯកសារដែលនិយាយអំពីជម្លោះប្រដាប់អាវុធ ហើយដែលខាងសហព្រះរាជអាជ្ញាទាមទារឱ្យបកប្រែជាភាសាខ្មែរឱ្យខាងតែបានហ្នឹង ចំពោះខ្ញុំគិតថាដូចជាចំណាយពេលអត់ប្រយោជន៍ទេ ។ ហើយវាខាតពេល ហើយវាដាក់បន្ទុកខ្លាំង សូម្បីតែបកតែពាក់កណ្តាលក៏អាចថាបញ្ជាក់អំពីជម្លោះប្រដាប់អាវុធបានទៅហើយហ្នឹង ចាំបាច់អីបកដល់ទៅទាំងអស់? អានេះខ្ញុំសូមឱ្យលោកជួយយកចិត្តទុកដាក់ក្នុងចំណុចហ្នឹងផង ។

ហើយពាក់ព័ន្ធជាមួយនឹងក្រុមមេធាវីរបស់យើងវិញ ហើយអនុលោមទៅតាមសេចក្តីសម្រេចរបស់សហចៅក្រមស៊ើប នៅថ្ងៃទី១៨ ខែកក្កដា ២០០៨ គឺខ្ញុំបានដាក់សេចក្តីជូនដំណឹងទៅខាងអ្នកបកប្រែឯកសារអំពីបញ្ជីដែលយើងគិតថាជាឯកសារអាទិភាព ។ ក៏ប៉ុន្តែ ខ្ញុំនៅទីនេះក៏សុំពិនិត្យមើលឡើងវិញផងដែរ នៅក្នុងឯកសារទាំងអស់ ក្នុងចំណោមឯកសារទាំងនោះ គឺគេប្រាប់មកថា ទាល់តែខែ២ថ្ងៃ២៨ បានបកអស់ ។ ហើយខ្ញុំមិនដឹងថា ក្នុងផ្នែកដែលថាបកអស់ទាល់តែថ្ងៃ២៨ ខែ២ ឆ្នាំ២០០៩ហ្នឹងមានចូលឯកសារយើងខ្ញុំនៅក្នុងហ្នឹងដែរឬអត់ទេ? ព្រោះយើងដឹងហើយ ខាងសហព្រះរាជអាជ្ញាបានបញ្ជូនឯកសាររាប់ពាន់ទំព័រ ដល់ម៉ឺនទំព័រឯណោះទៅខាងផ្នែកបកប្រែ ដើម្បីបកប្រែ ហើយគេបានថា

ឯកសារទាំងអស់ហ្នឹងនឹងបកប្រែចប់នៅថ្ងៃ២៨ ខែ២ ឆ្នាំ២០០៩ ។

អ៊ីចឹងខ្ញុំចង់ដឹងមើលថាតើ ឯកសារដែលយើងខ្ញុំសុំផ្តល់ជាអាទិភាពហ្នឹងគិតថា ដល់ថ្ងៃ២៨ ខែ២ ហ្នឹង គិតថាបកអស់ដែរឬយ៉ាងម៉េច? មានបញ្ចូលក្នុងហ្នឹងដែរឬទេ? ព្រោះអីឯកសារដែលយើងខ្ញុំដាក់ទៅនេះគឺជាឯកសារសំខាន់ ជាពិសេសទាក់ទងជាមួយនឹងឯកសារសម្ភាសន៍ និងឯកសារពាក់ព័ន្ធជាមួយនឹងដីកាបង្គាប់ឱ្យស៊ើបសួរ ឬក៏ចាត់ឱ្យស៊ើបសួរជំនួស ។

ហើយនៅក្នុងនេះគឺទាក់ទងជាមួយនឹងបញ្ជីដែលសហព្រះរាជអាជ្ញាបានលើកឡើងមកនេះ គឺខ្ញុំមិនដឹងថាតើនៅក្នុងបញ្ជីហ្នឹង គឺអាចធ្វើចប់ដល់ថ្ងៃ២៨ ខែ២ ដូចលោកបានជម្រាបហ្នឹង ហើយខ្ញុំគ្រាន់តែចង់ដឹងថាតើរបស់យើងនេះដល់ថ្ងៃហ្នឹងថាតើបកចប់អស់ដូចគ្នាអ៊ីចឹងដែរឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ដែលបានធ្វើការកត់សម្គាល់នូវបញ្ហានានាដែលពាក់ព័ន្ធនឹងការបកប្រែនេះ ដែលនៅឯកសារមួយចំនួន ហើយជាពិសេសគឺឯកសារខាងមេធាវីការពារក្តី ។

ជាបន្តនេះ សូមអញ្ជើញខាង លោកស្រី មីសែល និង លោក គង់ សុភី តើមានអ្វីចង់កត់សម្គាល់ឬក៏តបទៅនឹងអ្វីដែលបានលើកឡើងដោយមេធាវីការពារក្តីទេ?

**លោក គង់ សុភី៖**

សូមគោរពលោកចៅក្រម ខ្ញុំសូមការអនុញ្ញាតឆ្លើយតបទៅនឹងសំណួរដែលខាងលោក ហ្រ្វង់ស្វ័រ ឱ្យខាងយើងខ្ញុំឆ្លើយបំភ្លឺចំពោះលិខិតដែលគាត់បានផ្ញើមក ថាតើឯកសារទាំងអស់នៅក្នុងលិខិតហ្នឹងតើយើងបានបកប្រែហើយឬនៅ? ជាការពិត លិខិតដែលគាត់បានផ្ញើមក គឺគាត់បានបញ្ជាក់ឈ្មោះឯកសារ និងលេខ *អ៊ីអ័រអ៊ិន* ឯកសារ ហើយខាងក្រុមការងារយើងខ្ញុំជាមួយខាងផ្នែកខាង *រ៉ិខតអាខាយ*ហ្នឹង គឺយើងបានពិនិត្យឯកសារហ្នឹង ហើយយើងបានពិនិត្យមើលថា តើឯកសារដែលគាត់ផ្ញើមកនោះ តើមានឯកសារណាខ្លះ ដែលបានស្នើសុំដោយភាគីផ្សេង ហើយបានបកប្រែហើយឬនៅ? ហើយជាសរុបមកវិញ គឺឯកសារទាំងអស់នោះ គឺយើងបានដាក់ចូលក្នុងប្រព័ន្ធបកប្រែ ហើយយើងបានចាត់ចែង បកប្រែទៅតាមសំណើរហ្នឹងទៅហើយ ។ ប៉ុន្តែ អ្វីដែលសំខាន់នោះ គឺថាឯកសារទាំងអស់ហ្នឹងមានឯកសារមួយចំនួននោះ យើងបានបកប្រែហើយ ហើយមានឯកសារមួយចំនួនទៀត ដែលយើងកំណត់*ដេតឡាញ* ចុងក្រោយបំផុតនោះគឺថ្ងៃ២៨ ខែកុម្ភៈ ខាងមុខនេះ ។ បាទនេះសូមឆ្លើយនឹងសំណួរចុងក្រោយនេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោក សុភី ។ តើមានលោក លោកស្រីណាមានបញ្ហាពាក់ព័ន្ធទៅនឹងបទបង្ហាញត្រង់របៀបវារៈនេះទៀតដែរទេ? សូមអញ្ជើញលោកស្រី ។

**លោកស្រី ម៉ាទីន ហ្សាកហ្វ៊ីន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមជម្រាបផងដែរទាក់ទងជាមួយនឹងផ្នែកនេះ គឺយើងយល់ស្របទាំងស្រុងនូវអ្វីដែលលោក ហ្វ្រង់ស្វ័រ រូ បានលើក ហើយខ្ញុំមានបញ្ហាសំខាន់ចំនួនពីរផងដែរ ជាក់លាក់ ។ នៅក្នុងនេះ ក្នុងនាមជាមេធាវីការពារក្តី ហើយជាជនជាបារាំង គឺយើងក៏ចង់ស្នើឲ្យមានការបកប្រែឯកសារជាក់លាក់មួយចំនួនដែរ ជាពិសេសគឺ-- ប៉ុន្តែយើងមិនមែនចង់ឲ្យបកប្រែទាំងអស់នោះទេ យើងគ្រាន់តែចង់បកប្រែទៅតាមលក្ខណៈជាក់ស្តែងដែលយើងគិតថាសំខាន់ ។ ក៏ប៉ុន្តែ ខ្ញុំគិតថានៅក្នុងនេះ គឺវាអាចវាមានបញ្ហាផងដែរ ជាពិសេសគឺនៅក្នុងសាលាក្តីយើងនេះ គឺយើងមាន ចៀសមិនផុតពីការរិះគន់ ព្រោះអីឯកសារដែលមាននៅក្នុងសំណុំរឿងហើយ ដែលជាឯកសារសំខាន់ទៅហើយនោះ នៅក្នុងរឿងក្តីហ្នឹងគឺមានតែជាភាសាអង់គ្លេស ហើយឯកសារភាគច្រើន គឺមិនមានជាភាសាបារាំង ហើយយើងដឹងហើយសមាជិកភាគច្រើននៅក្នុងសាលាក្តីនេះ គឺជាអ្នកចេះនិយាយភាសាអង់គ្លេសក៏ដោយ ក៏ប៉ុន្តែយើងមានអ្នកការពារក្តីនិងភាគីដែលត្រូវប្រើប្រាស់ភាសាបារាំងផងដែរ ។ អ៊ីចឹងនៅក្នុងនេះ យើងពិតជាចង់សហការជាមួយនឹងលោកចៅក្រម ក៏ប៉ុន្តែយើងមិនចង់ឲ្យមានការរិះគន់ពីពិភពលោកមកពីការមិនបានបកប្រែភាសាបារាំងហ្នឹងទេ ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីដែលបានធ្វើការកត់សម្គាល់លើចំណុចនេះ ។ សូមអញ្ជើញលោកមេធាវីការពារជនជាប់ចោទ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងខ្ញុំសូមអធ្យាស្រ័យដោយសារមានការភ្លាំងភ្លាត់បន្តិចមិនបានចុចប៊ូតុងបកប្រែ ហើយខ្ញុំសូមជម្រាបថា យើងខ្ញុំយល់ស្របអំពីមតិដែលខាង *ស៊ីវិលផាតី* លោកបានលើកឡើងមិញអ៊ីចឹងដែរ ។ (ឥឡូវលោកសូមអញ្ជើញតទៅទៀត យើងខ្ញុំត្រៀមខ្លួនរួចហើយអ្នកបកប្រែ) ។

យើងបានបង្ហាញអំពីកង្វល់របស់យើងញឹកញាប់ហើយ ជាពិសេសទាក់ទងជាមួយនឹងការបកប្រែភាសាជាឯកសារ ហើយនិងការដែលត្រូវយកឯកសារទៅបកប្រែនៅខាងក្រៅសាលាក្តីរបស់យើង

ឯកសារដើម

ហើយទាក់ទងជាមួយការដែលចុះកិច្ចសន្យាឲ្យខាង *ឌីស៊ីខេម* បកប្រែ ហើយយើងដឹង ហើយយើងយល់ស្របនូវអ្វីដែលមានកន្លងមក ហើយយើងមើលការងាររបស់ *ឌីស៊ីខេម* ក៏យើងដឹងអំពីកិច្ចការដែលគេធ្លាប់ធ្វើមកហ្នឹង គឺគេធ្វើបានការងារល្អ យូរឆ្នាំហើយទាក់ទងជាមួយនឹងវិស័យនេះ ។ ហើយនៅក្នុងហ្នឹងគឺក្នុងការងាររបស់ *ឌីស៊ីខេម* គេកំពុងមានជំហរជួយដើមបណ្ដឹងរដ្ឋប្បវេណីដែរ ក៏ប៉ុន្តែខ្ញុំចង់សួរថាតើយើងអាចទទួលយកបានដែរទេ ដែលថាមានអង្គការមួយដែលយើងដឹងហើយថា កំពុងតែជួយគាំទ្រខាងផ្នែកភាគីមួយ ហើយមកបកប្រែឯកសារទាក់ទងជាមួយនឹងក្រុមមេធាវីការពារក្ដីទៅវិញ ក្នុងពេលជាមួយគ្នាហ្នឹង? ហើយខ្ញុំក៏ចង់លើកពីបញ្ហាហ្នឹងផងដែរ គឺថាធ្វើអ៊ីចឹងមិនអាចទទួលយកបានទេ ព្រោះអីមិនអាចឲ្យដើមបណ្ដឹងរដ្ឋប្ប-- បើសិនជាគេបកប្រែឯកសារដើមបណ្ដឹងរដ្ឋប្បវេណី ហើយគេជួយដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមិនយល់ទាស់ទេ ក៏ប៉ុន្តែនេះគេបកប្រែឯកសារមកពីខាងមេធាវីការពារក្ដី ដែលខាងជនជាប់ចោទ ហើយគេមានទំនាស់ផលប្រយោជន៍ជាមួយភាគីម្ខាងទៅហើយ ខ្ញុំមិនអាចទទួលយកបានទេក្នុងចំណុចនេះ ។ សូមលោកចៅក្រមទាំងអស់មេត្តាជ្រាបផង ។

**ប្រធានអង្គជំនុំ៖**

...អ្វីដែលបានកត់សម្គាល់អំពីចំណុចបាន ។ ប្រហែលជាចុងក្រោយហើយ សូមអញ្ជើញលោកមេធាវី ។

**លោក គង់ ពិសី៖**

ខ្ញុំបាទសូមអរគុណលោកប្រធាន ។ បញ្ហាទាក់ទងក្នុងការបកប្រែនេះ គឺសូមជម្រាបជូនអង្គប្រជុំបន្តិច ទាក់ទងទៅនឹងមេធាវីអន្តរជាតិ បើសិនណាជាខ្ញុំចាំមិនភ្លេចទេ មេធាវីអន្តរជាតិគឺត្រូវចេះយ៉ាងតិចណាស់ក៏ពីរភាសា គឺជាភាសារបស់ខ្លួនគាត់ពីកំណើត ហើយនិងភាសាបរទេសមួយទៀត ។ អ៊ីចឹងបើសិនណាជា ខ្ញុំលើកឡើងទៅប្រហែលជាប៉ះពាល់ដល់មេធាវីខាងភាសាបារាំងអ៊ីចឹងដែរទៅអាចថាសូមអធ្យាស្រ័យ បើសិនណាជាគាត់ជាមេធាវីមួយដែលមកពី ឧទាហរណ៍ថា គាត់មកពី អង់គ្លេស គាត់ចេះភាសាអង់គ្លេស អ៊ីចឹងជាភាសាកំណើតរបស់គាត់ហើយ អ៊ីចឹងគាត់គួរតែចេះភាសាមួយទៀតដែលគេប្រើនៅក្នុងសាលាក្ដីនេះ គឺត្រូវតែចេះភាសាបារាំង ។ ហើយបើមេធាវីគាត់អញ្ជើញមកពីភាសាបារាំង មកពីប្រទេសបារាំង អ៊ីចឹងភាសាកំណើតរបស់គាត់ គឺបារាំង អ៊ីចឹងគាត់ត្រូវតែចេះអង់គ្លេសដែលគេយកប្រើនៅក្នុងសាលាក្ដីនេះ ។ អ៊ីចឹងឯកសារទាំងអស់បើសិនណាជាឯកសារនោះ មានតែជាភាសាខ្មែរ អត់មានភាសាអង់គ្លេស នឹងគួរតែបកជូនគាត់ អាហ្នឹងតាមអ្វីដែលខ្ញុំយល់ ។

ហើយចំណុចមួយទៀតទាក់ទៅហ្នឹង ខ្ញុំមិនមែននិយាយការពារខាងព្រះរាជអាជ្ញាទេ គឺថាជាបន្ទុកនៃការបង្ហាញភស្តុតាងរបស់គាត់ អ៊ីចឹងគឺគាត់ខំប្រឹងប្រែងស្វែងរក ធ្វើយ៉ាងម៉េចដើម្បីបង្ហាញភស្តុតាងនៅក្នុងតុលាឲ្យអស់ពីវិមតិសង្ស័យរបស់គាត់ អ៊ីចឹងគាត់ខំប្រឹងប្រែងរករបស់គាត់ ។ ហើយចំពោះខាងមេធាវីខាងការពារក៏អ៊ីចឹងដែរ គឺថាយើងធ្វើយ៉ាងណាធ្វើការការពារឲ្យបានត្រឹមត្រូវឲ្យអស់សមត្ថភាពរបស់ខ្លួន អ៊ីចឹងគឺខំប្រឹងប្រែងថា គិតធ្វើយ៉ាងណាឲ្យមានការបកប្រែហ្នឹងទៅ ឲ្យបានល្អទៅ ហើយនេះគឺជាបញ្ហារបស់ខ្ញុំ ។ ដូចជាខាងខ្ញុំមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានការលំបាកណាស់ លោកមេធាវី ហុង គឹមសួន ក៏បានលើកឡើងហើយ តាំងពីការធ្វើសារណាក្តី អីក្តី គឺថាត្រូវការអ្នកបកប្រែហ្នឹង ជួនកាលដល់ថ្ងៃមិនធ្វើការ ក៏ត្រូវមានបកប្រែដែរ ។ អ៊ីចឹងឧទាហរណ៍ ដូចជាថ្ងៃស្អែកនេះជាថ្ងៃសៅរ៍មិនធ្វើការទៀត ហើយយើងបានស្នើសុំទៅអង្គភាពផ្នែកខាងបកប្រែនេះ គឺថាឲ្យគេបញ្ជូនទៅ ។ អានេះជាការខំប្រឹងប្រែងរបស់ខ្លួនរៀងៗខ្លួន ដើម្បីធ្វើការជូនកូនក្តី ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណនូវកត់សម្គាល់ចំណាប់អារម្មណ៍ កត់សម្គាល់របស់លោកមេធាវី ។ យើងបានជជែកពិភាក្សាលើរបៀបវារៈនេះច្រើន អ៊ីចឹងជាកិច្ចបន្តខ្ញុំសូមចូលដល់របៀបវារៈមួយទៀត គឺអំពីម៉ោងធ្វើសវនាការ ថ្ងៃជំនុំជម្រះ ថ្ងៃឈប់សម្រាកផ្លូវការ និងការឈប់សម្រាកពេលជំនុំជម្រះ ។ ខ្ញុំសូមជម្រាបជូនថា នេះជាការកំណត់ជារួមនៃកម្មវិធីសវនាការប្រចាំថ្ងៃ ដែលអង្គជម្រះបានពិភាក្សាគ្នា និងសម្រេចដូចខាងក្រោមនេះ៖

១) ជាទូទៅសវនាការនឹងគ្រោង នឹងធ្វើមានរយៈពេល៤ថ្ងៃ ក្នុងមួយសប្តាហ៍នីមួយៗ ។

២) ក្នុងករណីសប្តាហ៍ណាដែលមានថ្ងៃឈប់សម្រាកច្រើន ការប្រកាសអំពីចំនួនថ្ងៃសវនាការនឹងត្រូវធ្វើឡើងជាមុន ។

ចំណុចទីពីរ អំពីចំនួនម៉ោងសវនាការសម្រាប់ថ្ងៃនីមួយៗ

១) នៅពេលព្រឹកយើងហ្នឹង ចាប់ផ្តើមអំពីម៉ោងប្រាំបួន ហើយបញ្ចប់នៅម៉ោងដប់មួយ និងហាសិបនាទី ហើយនៅចន្លោះពេលនេះ នឹងមានការឈប់សម្រាករយៈពេលដប់ប្រាំនាទី ។

២) នៅពេល-- សូមអធ្យាស្រ័យដែរ ខ្ញុំក៏ប្រឹងដែរ គឺព្រោះធម្មជាតិខ្ញុំនិយាយខ្មែរហ្នឹងញាប់ណាស់ហើយនេះជា ការប្រឹងមែនទែន ដើម្បីកាត់បន្ថយអ៊ីចឹងអាចភ្លេចភ្លាត់ ។

២) អំពីពេលវេលានឹងចាប់ផ្តើមនៅម៉ោងដប់មួយ ម្ភៃប្រាំនាទីនាពេលរសៀល និង

បញ្ចប់វិញនៅម៉ោងដប់ប្រាំមួយនិងដប់ប្រាំនាទី ហើយនៅចន្លោះពេលនេះ នឹងមានការឈប់សម្រាករយៈពេលដប់ប្រាំនាទី ។

របៀបវារៈបន្ត គឺការឈប់សម្រាកពេលវេលា ពេលជំនុំជម្រះ និងប៉ាន់ស្មានរយៈពេលសម្រាប់សវនាការ ខាងអង្គជំនុំជម្រះគិតថា វាហាក់បីដូចជាឆាប់ពេកក្នុងការបង្ហាញថា ពេលណាការឈប់សម្រាកនឹងត្រូវកំណត់ការប៉ាន់ស្មានរយៈសម្រាប់សវនាការនោះ ។

ចំណុចមួយទៀត អំពីរបៀបវារៈកាលបរិច្ឆេទដែលអាចកំណត់បានសម្រាប់ការចាប់ផ្តើមការជំនុំជម្រះ និងការបរិច្ឆេទកាលវិភាគសវនាការ ។ នៅពេលនេះអង្គជំនុំជម្រះសាលាដំបូងសូមលើកយកបញ្ហានៃការរៀបចំកាលវិភាគសម្រាប់ការជំនុំជម្រះ និងជាពិសេសគឺការរៀបចំសវនាការបឋម ។ ពាក់ព័ន្ធនឹងបញ្ហានេះអង្គជំនុំជម្រះសាលាដំបូង សូមសួរទៅភាគី ព្រមទាំងផ្នែកនានាឯទៀតរបស់តុលាការអំពីភាពត្រៀមខ្លួនរួចរាល់និងពេលវេលា ដែលខ្លួនអាចចូលរួមនៅក្នុងពេលចាប់ផ្តើមនៃកិច្ចជំនុំជម្រះ ។ ជាពិសេសជាងនេះទៅទៀត អង្គជំនុំជម្រះសូមអញ្ជើញភាគីទាំងអស់ ផ្តល់នូវការបញ្ជាក់ថា តើខ្លួនមានផែនការចាត់វិធានការផ្លូវច្បាប់ណាមួយដែលអាចប៉ះពាល់ដល់ការរៀបចំកាលវិភាគនៃការជំនុំជម្រះដែរឬយ៉ាងណា? ឧទាហរណ៍ ដូចជាប្រសិនបើភាគីចង់លើកអំពីបញ្ហាអញ្ញត្រកម្មណាមួយ ក្នុងសវនាការបឋមជាដើម ។ ព្រោះនេះជាបញ្ហាដែលពាក់ព័ន្ធទៅនឹងកាលវេលា ដំណើរការប្រព្រឹត្តទៅនៃពេលវេលាសវនាការប្រចាំសប្តាហ៍ ប្រចាំថ្ងៃ ហើយនឹងអំឡុងពេលនៃការត្រូវឈប់សម្រាក នៅក្នុងរយៈពេលនៃការប៉ាន់ស្មានរយៈពេលប្រចាំសវនាការមួយចប់ ពីដើមរហូតដល់ចប់ ឬក៏ការបរិច្ឆេទសម្រាប់ការចាប់ផ្តើមជំនុំជម្រះជាដើម គឺមានការសុំធ្វើបទបង្ហាញប៉ុណ្ណឹង ហើយនឹងជូនវេទិការនេះជូនទៅអស់លោកលោកស្រី អ្នកនាងកញ្ញាដែលចូលរួម ប្រសិនបើមានបញ្ហា ឬក៏សំណួរមានពាក់ព័ន្ធនឹងបញ្ហានេះ ដែលខ្ញុំបានលើកឡើងនេះ សូមអញ្ជើញ ។

**លោក រ៉ូបឺត ពេទីត៖**

ចំណុចដែលខ្ញុំនិយាយហ្នឹង គឺថាខ្ញុំអត់មានការបកប្រែឲ្យបានច្បាស់លាស់ជាភាសាអង់គ្លេសទេអំពីម៉ោងសវនាការ សូមលោកប្រធានមេត្តាប្រាប់ម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

សូមម្តងទៀតលោក ពេទីត ខ្ញុំអត់បានពាក់ *កាស* មិញ ។

**លោក រ៉ូប៊ឺត ពើទីត៖**

គឺថា ខ្ញុំមិនបានទទួលការបកប្រែទេ អំពីចំនួនម៉ោង និងពេលវេលាម៉ោងសម្រាប់ធ្វើសវនាការ សូមលោកប្រធានមានប្រសាសន៍ម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ ។ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀត អំពីពេលវេលាធ្វើសវនាការ ថ្ងៃជំនុំជម្រះ ថ្ងៃឈប់សម្រាកផ្លូវការ និងការឈប់សម្រាកពេលជំនុំជម្រះ ។ កម្មវិធីសវនាការប្រចាំសប្តាហ៍ ជាទូទៅសវនាការនឹងធ្វើមានរយៈពេល៤ថ្ងៃក្នុងមួយសប្តាហ៍ នេះគឺយើងធ្វើសម្រាប់សប្តាហ៍ណាដែលមិនមានថ្ងៃឈប់សម្រាក ។

ទី២. ក្នុងករណីសប្តាហ៍ណា ដែលមានថ្ងៃឈប់សម្រាកច្រើន ការប្រកាសអំពីចំនួនថ្ងៃសវនាការនឹងធ្វើឡើងជម្រាបជូនទៅភាគីជាមុន ។

ទី២. ចំនួនម៉ោងសវនាការ នៅពេលព្រឹក យើងនឹងចាប់ផ្តើមនៅម៉ោងប្រាំបួន និងបញ្ចប់នៅម៉ោងដប់មួយហាសិបនាទីព្រឹក ហើយនៅចន្លោះនេះយើងនឹងមានការឈប់សម្រាករយៈពេលដប់ប្រាំនាទី ។ នៅពេលរសៀលនឹងចាប់ផ្តើមនៅវេលាម៉ោងដប់បីនិងម្ភៃប្រាំនាទី និងបញ្ចប់នៅម៉ោងដប់ប្រាំមួយនិងដប់ប្រាំនាទី ហើយនៅចន្លោះពេលនេះ នឹងមានការឈប់សម្រាករយៈពេលដប់ប្រាំនាទី ។ ច្បាស់ទេ?

**លោក រ៉ូប៊ឺត ពើទីត៖**

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀតពាក់ព័ន្ធនឹងអ្វីដែលខ្ញុំបានលើកឡើងនេះ សូមភាគីមាន-- បាទៗសូមអញ្ជើញ មេធាវីការពារជនជាប់ចោទ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន ។ ដោយអនុលោមទៅតាមវិធាន៨៩ អនុវិធានមួយ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បាននិយាយពីអញ្ញត្រកម្មទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដោយយោងទៅលើបញ្ហានេះ នៅអង្គជំនុំជម្រះបឋមខ្ញុំបាទសូមដាក់អញ្ញត្រកម្មជូនទៅលោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបងម្តងទៀត ព្រោះមិញការបកប្រែអត់បាន មានបញ្ហាបច្ចេកទេស ។

**លោក ការ សាវុត្ថ៖**

សូមគោរពជាថ្មីម្តងទៀតលោកប្រធាន ។ ដោយអនុលោមទៅតាមវិធាន៨៩ អនុវិធានមួយ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបាននិយាយអំពីអញ្ញត្រកម្មទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ។ បញ្ហានេះ ខ្ញុំសូមអនុញ្ញាតនឹងដាក់អញ្ញត្រកម្មជូនសាលាដំបូងដើម្បីពិនិត្យ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវីការពារក្តី ដែលបានផ្តល់ព័ត៌មាននេះ ហើយដើម្បីយើងខ្ញុំនៅអង្គជំនុំជម្រះសាលាដំបូងនឹងត្រៀមលក្ខណៈសម្បត្តិ ដោយគណនាអំពីពេលវេលា ឬក៏អំពី-- ជាពិសេសគឺពេលវេលា ដើម្បីត្រៀមធ្វើចំណាត់ការ បើសិនជាមានដូច្នេះមែន ។ ហើយសូមអញ្ជើញលោកស្រីចៅក្រម សូមអញ្ជើញមានយោបល់ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៍៖**

សូមអរគុណសម្រាប់ការបង្ហាញ ដែលលោកព្យាយាមលើកឡើងនូវ-- ទាក់ទងនឹងយុត្តាធិការនៅក្នុងសវនាការបឋម តើលោកអាចមានការបញ្ជាក់អំពី អាចកំណត់បានទេអំពីពេលវេលា ឬក៏ការបង្ហាញអំពីហេតុផលនៃយុត្តាធិការដែលលោកនឹងលើកឡើងនោះ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកស្រីចៅក្រម អំពីពេលវេលាដែលខ្ញុំបាទបម្រុងនឹងលើកឡើងអំពីបញ្ហាអញ្ញត្រកម្មនៅក្នុងសវនាការបឋមនេះ ខ្ញុំគិតថាប្រហែលជាអាចដេញដោលគ្នាទៅអាចជាប់មួយថ្ងៃ រយៈពេលមួយថ្ងៃ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

បើអ៊ីចឹងមានន័យថា លោកនឹងផ្តល់ឲ្យមានទទឡ្ហីករណ៍ពីខាងភាគីដទៃ ពីភាគីដើមបណ្តឹងរដ្ឋប្បវេណី និងពីខាងសហព្រះរាជអាជ្ញាឬក៏យ៉ាងម៉េច ទាក់ទងទៅនឹងការធ្វើការដេញដោលគ្នានោះ ? សូមអរគុណ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកស្រីចៅក្រមជាថ្មីម្តងទៀត ថាបញ្ហាដែលយើងខ្ញុំដាក់អញ្ញត្រកម្មនេះ គឺយើងខ្ញុំបើកចំហភាគីណាចង់ជំទាស់យ៉ាងម៉េច គឺដេញដោលគ្នាដើម្បីរកយុត្តិធម៌ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាសូមអញ្ជើញ ។

**លោក រ៉ូប៊ើត ពើទីត៖**

សូមអរគុណ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើមិនមានសំណួរទាក់នឹងផ្នែកទីពីររបស់ខាងអង្គជំនុំជម្រះទេ? ដែលទាក់ទងទៅនឹងសវនាការ ។ តើលោកអាចបង្ហាញថា តើអ្វីទៅដែលជាប្រធានបទនៃអញ្ញត្រកម្មរបស់លោកនោះ? ដែលពេលនោះ គឺថាយើងអាចនឹងមានឱកាសនឹងអាចយល់ដឹង និងរៀបចំឲ្យបានជាមុន ។ ពីព្រោះនេះ គឺជាការបានដឹងលើកដំបូង ដែលខ្ញុំបានដឹងអំពីព្រឹត្តិការណ៍បែបនេះ ទាក់ទងទៅនឹងអញ្ញត្រកម្ម តើលោកអាចមានឱកាសដើម្បីបង្ហាញប្រាប់អំពីហេតុផល ឬក៏ប្រធានបទនៃការធ្វើអញ្ញត្រកម្មរបស់លោកដែរឬទេ? បើសិនមិនមាននៅពេលនេះទេ តើលោកហ្នឹងមាននៅពេលណា? សូមអរគុណ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! អំពីបញ្ហាអញ្ញត្រកម្មនេះ យើងខ្ញុំមានសព្វគ្រប់អស់ហើយ ក៏ប៉ុន្តែពេលនេះយើងខ្ញុំមិនបានលើកជូនទេ ទុកដល់ថ្ងៃសវនាការ យើងនឹងសួរដេញដោលគ្នា ប៉ុន្តែអ្វីដែលខ្ញុំនឹងដាក់ជូន គឺខ្ញុំដាក់ជូនមុនទៅលោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ដោយបញ្ហានេះក៏ជារឿងថ្មីសម្រាប់អង្គជំនុំជម្រះដែរ ហើយខ្ញុំក៏មិនទាន់បានជួបដែរ ហើយនេះគឺជា ទើបតែទទួលបានព័ត៌មានជាលើកដំបូង ហើយអ្វីៗទាំងអស់យើងនឹងគ្រោងឲ្យមានការដាក់ជាឯកសារ ជាកម្មវត្ថុនៃការទាមទារហ្នឹងឲ្យបានច្បាស់លាស់ ហើយនិងដាក់ឯកសារជាមុន ដើម្បីយើង

មានឱកាសក្នុងការសិក្សា ឬបញ្ជូនទៅភាគី ដើម្បីមានផ្ញើសារណាតបអីជាដើម មុននឹងចាប់ផ្ដើមជជែកពិភាក្សាគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីបឋមនោះ ។ ប៉ុន្ដែទោះជាយ៉ាងណា គឺខ្ញុំអរគុណដោយសារលោកមេធាវីបានផ្ដល់ព័ត៌មាននេះជាមុន យើងនឹងមានលក្ខណៈត្រៀមខ្លួន ដើម្បីទទួលយកបញ្ហាហ្នឹង ។ ហើយក៏ដូចជាខ្ញុំជម្រាបអ៊ីចឹង នឹងគណនាអំពីពេលវេលានៃដំណើរការប្រជុំ តើយើងចំណាយពេលវេលាយ៉ាងម៉េចដើម្បីសមស្រប ហើយឆ្លើយតបទៅនឹងបញ្ហានានាដែលយើងនឹងអាចលើកឡើងពិភាក្សា និងចេញសេចក្ដីសម្រេចនៅក្នុងអំឡុងពេលនៃដំណើរការសវនាការបឋមនោះ ។

តទៅទៀតទៅមានភាគីផ្សេងទៀតមានការពាក់ព័ន្ធនឹងបទបង្ហាញរបស់ខ្ញុំ ដែលខ្ញុំបានលើកឡើងទេ? បើមិនមានទេ គឺជារបៀបវារៈ--

បាទៗសូមអញ្ជើញៗលោកស្រីមេធាវី ។

**លោកស្រី ស៊ីលឃីស្ទួន ហ្សីនស្ដី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរ អាចមានទាក់ទងបញ្ហាបកប្រែជាភាសាអង់គ្លេស លោកនិយាយអំពីអំឡុងពេលសវនាការ តើមានបាននិយាយអំពីការរំពឹងទុកនៅអំឡុងពេលសវនាការដែរឬទេ? ដូចជាចំនួនម៉ោងធ្វើការអ៊ីចឹង គឺថាមិនបានបកប្រែជាមុនមកនោះ? តើលោកអាចផ្ដល់ព័ត៌មានអស់ទាំងហ្នឹងអំពីដូចថា ក្រុមដែលអាចមានសម្រាប់ការចូលរួមនៅក្នុងរៀបចំសវនាការនោះ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចំពោះបញ្ហាទាំងនេះ គឺអង្គជំនុំជម្រះបានលើកឡើងបង្ហាញហើយថា វាហាក់ដូចជាឆាប់ពេកក្នុងការបង្ហាញនៅបញ្ហាផ្សេងៗ ជាពិសេសគឺការប៉ាន់ស្មានរយៈពេលសវនាការជាដើមនោះ ។ ហើយប្រសិនបើភាគីដែលមានការពាក់ព័ន្ធទៅនឹងក្នុងរឿងក្ដី ហើយបើមានបំណងនៅក្នុងការដាក់នូវសំណើសុំផ្សេងៗអំពីអំឡុងពេលនៃដំណើរការនោះ គឺយើងនឹងទទួល ហើយនឹងពិភាក្សាផ្ទៃក្នុងនៅក្នុងអង្គជំនុំជម្រះ ហើយយើងនឹងរៀបចំជូនដំណឹងទៅអស់លោក លោកស្រីជាក្រោយ ។

សូមអញ្ជើញលោកមេធាវី ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន ។ ចំពោះថ្ងៃសវនាការក្នុងមួយសប្ដាហ៍ ខ្ញុំសូមធ្វើសំណូមពរលោកប្រធានថា ឲ្យធ្វើសវនាការមួយថ្ងៃឈប់មួយថ្ងៃ ។ ឧបមាថា ធ្វើថ្ងៃច័ន្ទ ឈប់អង្គារ ដូច្នេះក្នុងមួយ

អាទិត្យសូមធ្វើតែបីថ្ងៃទេ ដើម្បីទុកពេលវេលាឲ្យយើងខ្ញុំនឹងមើលឯកសារថែមទៀតផង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវអ្វីដែលជាសំណូមពររបស់លោកមេធាវី ។ ហើយដោយសារបញ្ហានេះ យើងបានពិភាក្សានៅក្នុងផ្ទៃក្នុងអង្គជំនុំជម្រះរួចហើយ ហើយមុននឹងប្រកាសនេះ ប្រសិនបើមានបំណងដូច្នេះមែន គឺយើងនឹងកត់សម្គាល់នូវសំណូមពររបស់លោក ហើយនឹងទៅពិភាក្សាទៅក្នុងផ្ទៃក្នុងនៃអង្គជំនុំជម្រះសាជាថ្មីម្តងទៀត ដើម្បីថ្លឹងថ្លែងអំពីសុខភាពរបស់ជនជាប់ចោទ អំពីថ្លឹងថ្លែងអំពីទំនាក់ទំនងនៃទំហំឯកសារដែលត្រូវបង្ហាញជាដើម ហើយថាតើយើងអាចរកវិធីណា ឬក៏ពេលវេលាណាបាន? ហើយយើងនឹងឆ្លើយតបនឹងសំណូមពររបស់លោកនៅពេលក្រោយ ។

ជាកិច្ចបន្តគឺសូមអញ្ជើញ ជាចំណុចដែលពាក់ព័ន្ធនឹងការផ្សាយ ។ សូមអញ្ជើញមេធាវីមានបញ្ហាអីទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានទាក់ទងទៅនឹងការកំណត់កាលបរិច្ឆេទសវនាការហ្នឹង ថាតើអង្គជំនុំជម្រះហ្នឹងអាចកំណត់បាននៅពេលនេះទៅ អំពីអំឡុងពេលវេលា សម្រាប់សវនាការបឋម ជាការប្រសើរណាស់បើសិនជាយើងបានកាលបរិច្ឆេទជាក់លាក់ណាមួយនោះ ប៉ុន្តែខាងអង្គជំនុំជម្រះមិនផ្តល់ឲ្យយើងនូវការបរិច្ឆេទជាក់លាក់ណាមួយនោះទេ ។ យ៉ាងណាក៏ដោយ គឺថាយើងមានភាពចាំបាច់ក្នុងការរៀបចំផែនការរបស់យើង ហើយខ្ញុំចង់ដឹង ថាតើយើងមានឱកាស ឬក៏ចន្លោះពេលណាខ្លះ ឬក៏ពេលណាដែលថាអង្គជំនុំជម្រះយល់ថាហ្នឹង ជាពេលដែលអាចកំណត់បានសម្រាប់ការធ្វើសវនាការបឋម ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចំពោះបញ្ហានេះគឺ អង្គជម្រះបាននឹងកត់ត្រាទុកនូវមតិយោបល់ ដែលភាគីសម្តែងឡើង ហើយចំពោះកាលវិភាគ កាលបរិច្ឆេទនៃដំណើរការសវនាការបឋមនោះ ហើយយើងក៏បានពិគ្រោះ ពិភាក្សាគ្នាជាច្រើនមកហើយ អំពីពេលវេលាណាដែលសមស្របនោះ ។ ហើយពេលវេលានៅចុងខែកុម្ភៈ ឬក៏ដើមខែមីនា ក៏សាលសវនាការនេះត្រូវជាប់ ដោយកក់ទុកជាមុននៅខាងអង្គបុរេ ហើយចំណែកដើមខែមីនានោះនឹងមានកិច្ចប្រជុំពេញអង្គនៃប្រជុំអង្គ ។ ដូច្នេះ គឺបញ្ហាដែលសមស្របនោះ គឺយើងខ្ញុំនឹងផ្តល់ជូននូវ

ព័ត៌មាននេះជាក្រោយ ព្រោះនៅក្នុងនេះគឺ ក៏បានកត់ត្រាទុកដែរថា ការកំណត់សវនាការមួយនឹងចេញទៅដោយប្រកាសអំពីកាលបរិច្ឆេទសម្រាប់ការរៀបចំសវនាការបឋម ប៉ុន្តែ ដោយសារតែខ្ញុំត្រូវការពិភាក្សាលម្អិតនៅក្នុងអង្គ ជំនុំជម្រះសាលាដំបូង ដើម្បីសម្រេចជាចុងក្រោយ អ៊ីចឹង គឺយើងនឹងធ្វើការពិភាក្សារួច យើងនឹងផ្តល់ប្រកាសជូនអង្គប្រជុំជាក្រោយ ។

សូមអញ្ជើញ ប្រធានអង្គភាពជនរងគ្រោះ ។ ចង់មានយោបល់អីទេ! ។

**លោកស្រី គាត បូផល ៖**

សូមគោរពលោកប្រធាន! ទាក់ទងទៅនឹងអ្វីដែលខ្ញុំលើកឡើងនេះ ទាក់ទងទៅការកំណត់កាលបរិច្ឆេទ រយៈពេលដប់ថ្ងៃសម្រាប់ជនរងគ្រោះ ដែលមានបំណងចង់ដាក់ពាក្យមកកាន់អង្គភាពជនរងគ្រោះ ។ ដូច្នេះ ដោយសារថា ការកំណត់ពេលសវនាការបឋម អាចនឹងមិនសម្រេចនៅក្នុងកិច្ចប្រជុំនេះទេ ខាងយើងខ្ញុំចង់លើកឡើងដើម្បីជូនដល់លោកប្រធាន ក៏ដូចជាលោកចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងហ្នឹង អាចពិចារណាថា តើខាងអង្គភាពជនរងគ្រោះអាចកំណត់យកថ្ងៃ ឧទាហរណ៍ដូចជាដើមសប្តាហ៍នៃខែកុម្ភៈ ដើម្បីជម្រាបជូនសាធារណជន ឬជាពិសេសជនរងគ្រោះ ដែលគាត់អាចមានបំណងដាក់ពាក្យមកកាន់អង្គជំនុំជម្រះ ហើយយើងអាចពន្យល់ទៅសាធារណជនឲ្យគាត់បានជម្រាបដែរថា នៅពេលណាដែលមានការកំណត់កាលបរិច្ឆេទច្បាស់លាស់អំពីសវនាការបឋមនោះ យើងនឹងជម្រាបជូននៅការកំណត់ច្បាស់លាស់នោះនៅតាមក្រោយ ធ្វើដូច្នេះ ដើម្បីងាយស្រួលដល់អង្គភាពជនរងគ្រោះក្នុងការផ្សព្វផ្សាយព័ត៌មានជូនសាធារណជន ហើយក៏ជាពិសេសអង្គការដែលធ្វើការជាមួយជនរងគ្រោះ ។ ដូចជាជនរងគ្រោះដែលមានបំណង ហើយគាត់ប្រហែលជាអាចនឹងពិចារណាក្នុងការដាក់បណ្តឹងនេះមកកាន់អង្គជំនុំជម្រះហ្នឹងឲ្យបានទាន់ពេលវេលា ។ ហើយក៏ដើម្បីជាការងារមួយសម្រាប់ជាមួយនឹងខាងផ្នែកកិច្ចការសាធារណៈដែលយើងធ្វើការផ្សព្វផ្សាយនេះឲ្យបានទូលំទូលាយថែមទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតរាយថ៍៖**

សូមអរគុណ ។ ដូចដែរខ្ញុំបានបង្ហាញជូនកាលពីម្សិលមិញអញ្ចឹង ។ បើសិនជាកាន់តែឆាប់នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សំណុំពាក្យរបស់ខ្លួនបាននោះ មានន័យថា ពួកគេមិនគួររង់ចាំរហូតដល់ពេលដប់ថ្ងៃ មុនកាលបរច្ឆេទកំណត់បិទនោះទេ ។ អ៊ីចឹងខាងអង្គភាពជនរងគ្រោះហ្នឹងឯង ក៏

គួរមានឱកាសដើម្បីធ្វើការទៅលើសំណុំពាក្យអស់ទាំងនោះ អ៊ីចឹងសារដែលគួរតែផ្តល់ទៅឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណីនោះហើយ គឺថាគួរតែពាក្យឲ្យបានមុនទៅតាមការដែលអាចធ្វើបាន ដូចជាការយកទៅបង្ហាញនៅថ្ងៃនេះអ៊ីចឹង ថាតើយើងអាចកំណត់គម្រោងពេលណាដើម្បីនឹងធ្វើសម្រាប់សវនាការបឋមនោះ? ហើយយើងនឹងជូនដំណឹងទៅដល់អ្នកស្រីអំពីនៅថ្ងៃខែពិតប្រាកដ សម្រាប់ការធ្វើសវនាការបឋមនោះ ប្រហែលជាយើងនឹងអាចជូនដំណឹងនេះបាននៅដើមសប្តាហ៍ក្រោយ ប៉ុន្តែចំណុចសំខាន់ហ្នឹង គឺថាឲ្យភាគីពាក់ព័ន្ធនឹងឯងដាក់សំណុំរឿងឲ្យបានកាន់តែឆាប់ កុំទុកឲ្យនៅដល់នាទីចុងក្រោយនោះ ពីព្រោះនឹងអាចខកខានក្នុងការដាក់ពាក្យរបស់ខ្លួន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកស្រីចៅក្រម ។ ហើយយើងខ្ញុំមើលទៅពេលវេលាដូចជាអស់ហើយ កាលកំណត់គឺម៉ោងដប់ពីរខ្វះដប់ប្រាំនាទីយើងត្រូវសម្រាក ឥឡូវនៅតែម៉ោងដប់ពីរខ្វះដប់នាទីប៉ុណ្ណោះ អ៊ីចឹងដល់ពេលវេលា ដែលអស់លោក លោកស្រី ត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ ។

អ៊ីចឹង ខ្ញុំសូមប្រកាសសម្រាក ដើម្បីត្រឹមនេះ ដើម្បីពិសាអាហារថ្ងៃត្រង់ ។ ហើយសូមអនុរក្សពន្ធនាគារ គឺនាំលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់ខាងក្រោមសាលសវនាការ ។

*(កិច្ចប្រជុំសម្រាកពីម៉ោង១១:៥៥នាទី ដល់ម៉ោង ១៣:៣២នាទី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ ។ ជំរាបសួរអស់លោក លោកស្រី! ឥឡូវនេះយើងចាប់ផ្តើមបន្តដំណើរការកិច្ចប្រជុំរបស់យើងតទៅទៀត តាមរបៀបវារៈដែលបានគ្រោងទុកសម្រាប់កិច្ចប្រជុំនៅថ្ងៃនេះ ។ ហើយតាមរបៀបវារៈប្រជុំហ្នឹងគឺនៅសល់តែមួយទេ គឺការផ្សាយសវនាការ និងការគ្រប់គ្រងព័ត៌មានដែលជាសំណើបន្ថែម របៀបវារៈនេះស្នើដោយសហព្រះរាជអាជ្ញា ។ ហើយបទបង្ហាញនេះ គឺនឹងធ្វើបទបង្ហាញសង្ខេបដោយប្រធានផ្នែកកិច្ចការសាធារណៈ ។ ហើយពាក់ព័ន្ធនឹងរបៀបវារៈនេះ គឺអង្គជំនុំជម្រះសូមអញ្ជើញផ្នែកកិច្ចការសាធារណៈឡើងធ្វើបង្ហាញសង្ខេបអំពីបច្ចុប្បន្នភាពនិងការរៀបចំ ដែលមានសម្រាប់ការផ្សាយនូវដំណើរការនីតិវិធីសាធារណៈ ។ រយៈពេលកំណត់បង្ហាញនេះគឺមានរយៈពេលខ្លីទេ អាចគ្រោងក្នុងកម្រិតដប់នាទី ហើយវាអាចជាលើសពីនេះតិចតួចតាមមើល ។ សូមអញ្ជើញលោកស្រី ។

**លោកស្រី ហេឡែន ចាវីស៖**

សូមជម្រាបសួរអ្នកទាំងអស់គ្នា ហើយនិងភាគីដែលចូលរួមក្នុងប្រជុំថ្ងៃនេះ! ខ្ញុំធ្វើការបែងចែកនូវឯកសារមួយចំនួនតូចទាក់ទងទៅនឹងព័ត៌មាននឹងអត្ថបទដែលខ្ញុំនឹងត្រូវនិយាយនៅក្នុងពេលនេះ។

លោកចៅក្រមជាទីគោរព! យើងខ្ញុំសប្បាយចិត្តណាស់ដែលយើងខ្ញុំមានឱកាសដើម្បីនិយាយពីបញ្ហាមួយចំនួនទាក់ទងទៅនឹងការផ្សព្វផ្សាយព័ត៌មានពីសវនាការ ។ ហើយយើងខ្ញុំពេញចិត្តនឹងលើកឡើងបង្ហាញអំពីប្រភេទផ្សេងៗគ្នានៃបញ្ហាដែលនឹងលើកយកមកពិចារណា ហើយនិងទទួលស្តាប់ការណែនាំអំពីខាងអង្គចៅក្រម ។

ចំណុចទីមួយដែលជាចំណុចសំខាន់គឺ ការផ្សព្វផ្សាយព័ត៌មាន ។ ដូចដែលខ្ញុំដឹងថា លោកចៅក្រមបានដឹងច្បាស់ហើយថា មានគោលបំណងមួយដែលថាមានទាក់ទងទៅនឹងចំណាប់អារម្មណ៍របស់សាធារណៈជនទៅលើ អ.វ.ត.ក របស់យើងនេះ ។ ហើយមកទល់នឹងពេលនេះគឺថាយើងមាននូវព្រឹត្តិបត្តិកម្មដ៏វិជ្ជមាននូវការពេញចិត្តសម្រាប់លទ្ធភាពក្នុងការផ្សព្វផ្សាយ គឺការផ្សព្វផ្សាយផ្ទាល់នៃសវនាការពីអង្គបុរេជំនុំជម្រះ ។ យើងមានការទទួលស្គាល់ថាដែរ នៅក្នុងអង្គជំនុំជម្រះនៃសវនាការហ្នឹង ការផ្សព្វផ្សាយផ្ទាល់នៅក្នុងករណីមួយចំនួនធំ ឬក៏នៅក្នុងករណីភាគច្រើនហ្នឹងមិនអាចធ្វើបាន ។ ប៉ុន្តែ គឺថាយើងខ្ញុំសូមស្នើដល់លោកចៅក្រមឲ្យធ្វើការពិនិត្យ ថាតើនឹងអាចមានផ្នែកណាមួយនៃសវនាការដែលអាចនឹងធ្វើការផ្សព្វផ្សាយផ្ទាល់ ជាពិសេសនៅក្នុងដំណាក់កាលបើក ឬក៏សេចក្តីថ្លែងការណ៍បើកសវនាការជាដើម ។ យើងខ្ញុំដឹងដែលថា ចំណុចនេះនឹងជាចំណុចពិសេសបំផុតដែលសាធារណជនចង់បាន ។ យើងដឹងហើយថា យើងមិនមានសមត្ថភាពដូចដែលខ្ញុំបាននិយាយកាលពីព្រឹកមិញអ៊ីចឹង ដូចជាខាងផ្នែកគ្រប់គ្រងតុលាការបាននិយាយពីព្រឹកមិញ គឺថាយើងអត់មានលទ្ធភាពក្នុងការធ្វើការពន្យារពេលរយៈពេលកន្លះម៉ោង ឬក៏រយៈពេលយូរក្នុងអ្វីដែលយើងនឹងធ្វើការផ្សព្វផ្សាយនោះ ។

ប្រសិនបើយើងត្រូវធ្វើការរង់ចាំរយៈពេលនៅថ្ងៃបន្ទាប់ ដើម្បីធ្វើការផ្សព្វផ្សាយនោះ មានន័យថាអាចជាការបាត់បង់មួយ គឺថាបាត់បង់នូវចំណាប់អារម្មណ៍ គឺថាមានការចាប់អារម្មណ៍ជាខ្លាំងចំពោះថ្ងៃដែលសវនាការនឹងធ្វើឡើង ។ ហើយជាការពិតណាស់ គឺថាយើងនឹងមិនធ្វើការផ្សព្វផ្សាយអ្វីដែលជាសវនាការអសាធារណៈនោះទេ ។ ខ្ញុំក៏សូមជម្រាបទៅដល់លោកចៅក្រមផងដែរថានៅទូរទស្សន៍ *ស៊ីធីអិន* គឺថាមាន *វ៉ែន* សម្រាប់ផ្សព្វផ្សាយមួយនៅលើទីតាំងនេះសម្រាប់ការផ្សព្វផ្សាយផ្ទាល់ ហើយនិងប៉ុស្តិ៍ទូរទស្សន៍អប្សរាក៏បានធ្វើការផ្សព្វផ្សាយផងដែរនៅរយៈពេលយប់ ដោយផ្តោតអារម្មណ៍ទៅលើសហ-

00286108



គមន៍កម្ពុជាដែលមាននៅ *អេសប៉េរ៉ា* នៅក្នុងកម្មវិធីពេលយប់ ហើយនឹងទូរទស្សន៍កម្ពុជាក៏បានធ្វើការផ្សព្វផ្សាយផងដែរ ហើយបានធ្វើការផ្សព្វផ្សាយជាបន្តបន្ទាប់ទៀត ។ មានន័យថាមានប៉ុស្តិ៍ទូរទស្សន៍ជាច្រើនដែលបានធ្វើការផ្សព្វផ្សាយនោះ ហើយមានផ្នែកតូចខ្លះមួយចំនួននៅក្នុងទូរទស្សន៍ *ស៊ីអិនអិន* ទូរទស្សន៍អូស្ត្រាលី ហើយនិងរបស់ទូរទស្សន៍អង់គ្លេស និងរបស់បារាំងផងដែរ ។

ចំណុចទីពីរទាក់ទងទៅនឹងការផ្សព្វផ្សាយហ្នឹងឯង គឺថាយើងមានការផ្សាយផ្ទាល់ពីបន្ទប់នេះបញ្ជូលមកលើអេក្រង់តាមទូរទស្សន៍ បើតាមអេក្រង់នៅក្នុងសាលសាធារណៈនៅខាងក្រៅនេះ ហើយយើងក៏សុំស្នើថាការអនុវត្តបែបនេះនឹងបន្តទៅមុខទៀតប្រសិនបើយើងមានលទ្ធភាព ហើយមានន័យថាខាងបណ្តាញសារព័ត៌មាននឹងមានការពេញចិត្ត នៅពេលដែលពួកគេត្រូវចំណាយពេលវេលាអង្គុយនៅទីនេះជាច្រើន ហើយដែលថាពួកគេអាចដើរចុះដើរឡើង ឬក៏អាចមើលបាននូវអ្វីដែលផ្សាយនៅតាមអេក្រង់នោះ ។ អ៊ីចឹងបើសិន ខាងផ្នែកគ្រប់គ្រងតុលាការអាចធ្វើការផ្សព្វផ្សាយបែបនេះបាននោះ គឺមានន័យថាអាចធ្វើការភ្ជាប់បានចំនួន៣០កន្លែងនោះ ដែលការកត់ត្រាចម្លងនឹងអាចធ្វើបាននោះនឹងជាចំណុចមួយល្អប្រសើរបំផុត ។ បើសិនជាការអនុវត្តប្រភេទនេះអាចបន្តទៅមុខទៀតបាន ដើម្បីឲ្យពួកគេធ្វើការកត់ត្រាទុកនូវចំណុចសំខាន់ៗ ។ ដូចខ្ញុំបាននិយាយដែរថា ការថតចម្លងហ្នឹងនឹងមិនអនុញ្ញាតទេ លើកលែងតែក្នុងករណីដែលសវនាការដែលត្រូវទទួលឲ្យអនុញ្ញាតធ្វើការផ្សព្វផ្សាយនោះ ។ កាលពីនៅក្នុងអតីតកាលកន្លងមកទាក់ទងទៅនឹងផ្នែក *អាយស៊ីធី* និង *ស៊ីអ៊ីមអេស* ហ្នឹងគឺថាពួកគេមានលទ្ធភាពផ្តល់នូវការផ្សាយវីដេអូផ្ទាល់ បើទៅតាមការិយាល័យនានានៅលើអេក្រង់ កុំព្យូទ័ររបស់បុគ្គលិកនៅក្នុង អ.វ.ត.ក ។ ហើយប្រសិនបើសិនជាយើងអាចធ្វើដូច្នេះបានទៀតហ្នឹង គិតថាវាមានលទ្ធភាពល្អប្រសើរណាស់ ហើយនិងអាចជួយសម្ពាធទៅលើកន្លែងអង្គុយនៅក្នុងសាលសាធារណៈផងដែរ ។ ហើយយើងខ្ញុំក៏មានបំណងចង់ជម្រាបទៅលោកចៅក្រមផងដែរថា ការផ្សព្វផ្សាយការធ្វើសវនាការក៏អាចបញ្ជូលទៅក្នុង *វេបខាស់ស្ទីង* បានដែរនៅក្នុងសកលវិទ្យាល័យមួយ ។ ហើយអ្នកអស់ទាំងហ្នឹងគឺថា ពួកគាត់បានរៀបចំនិងបន្តប្រើឧបករណ៍ផ្សេងៗសម្រាប់ឲ្យខាងសាធារណជនអាចចូលមើលបាន ហើយគេក៏អាចរៀបចំជាប៉ាលិក្រុម ផងដែរនៅលើ *វេបខាស់* នោះ ។

ផ្នែកទីពីរ ដែលខ្ញុំអាចនឹងនិយាយបន្តទៀតនោះ គឺទាក់ទងទៅនឹងការផ្តល់ផ្នែកនៃសវនាការសម្រាប់សាធារណៈដែលអាចដាក់ចម្លងទៅលើ *វីស៊ីឌី* សម្រាប់ឲ្យទៅខាងផ្នែកសារព័ត៌មាន និងផ្នែកទាំងឡាយណាដែលពាក់ព័ន្ធ ។ បើអ៊ីចឹងក្នុងអំឡុងពេលបច្ចុប្បន្នកន្លងនេះ សម្រាប់សវនាការសាធារណៈ

ដែលមិនមានការលុបចម្លងនេះ  គឺថាផ្នែកខាងគ្រប់គ្រងតុលាការបានផ្ដល់មកឲ្យខាងយើងធ្វើការបែងចែក បន្ទាប់ពីប៉ុន្មានម៉ោងក្រោយពីមានសវនាការទាំងនោះ ហើយក្នុងកំឡុងពេលសម្រាប់សវនាការដែលត្រូវការការលុបនោះឯងគឺថានឹងអាចធ្វើការផ្សព្វផ្សាយបន្ទាប់ពីមានការលុបរួច ។ មកដល់ពេលនេះ នៅក្នុងសវនាការរបស់ ឌុច នៅក្នុងអង្គបុរេជំនុំជម្រះហ្នឹងឯងគឺថាមាន៣៦ នៃវគ្គសវនាការដែលត្រូវបានគេស្នើឡើង ហើយយើងសង្ឃឹមថានឹងមានសំណើ ឬក៏ការចាប់អារម្មណ៍បន្ថែមទៀតដែរទាក់ទងទៅនឹងការទទួលយក *វីស៊ីឌី* នេះ ។

ចំណុចទីបី គឺថាទាក់ទងការថតរូប ។ កាលពីមុនៗនោះឯង ឬក៏កាលពីអតីតកាលគឺថាយើងបានផ្ដល់ ហើយហ្នឹងក៏បានស្នើដល់ខាងជំនុំជម្រះអនុញ្ញាតឲ្យពួកយើងថតរយៈពេលខ្លីមួយនៅពេលដែលចាប់ផ្ដើមសវនាការ ។ យើងធ្លាប់បានមានការបញ្ចេញមតិពីអ្នកថតរូបថតដែលចង់ថតរូប ដែលពួកគេយល់ថា គុណភាពដែលពួកគេថតហ្នឹងអាចវាគុណភាពខ្ពស់ ហើយអាចជ្រើសរើសទីតាំងដើម្បីថតខ្លួនឯងបាន ដូចប្រសើរជាងការថត ឬក៏ចម្លងចេញពីវីដេអូ ។ ប៉ុន្តែនេះ គឺអាស្រ័យទៅលើការពិចារណារបស់លោកចៅក្រមបើសិនជាលោកចៅក្រមអនុញ្ញាតឲ្យអ្នកថតរូបប្រហែលជាប្រាំអ្នកអាចចូលថតក្នុងរយៈពេលខ្លីមួយ  នៅពេលដែលជនជាប់ចោទហ្នឹងបានអង្គុយហើយនោះ  ហើយបន្ទាប់ពីចៅក្រមបានចូលអង្គុយក្នុងអសនៈហើយ  បើពួកគេថតហើយនឹងចេញពីសាលសវនាការភ្លាម ។ ខ្ញុំក៏សុំនិយាយដែរថា អ្នកដែលជាអ្នកថតរូបអស់ហ្នឹង គឺសុទ្ធតែអ្នកមានបានទទួលនូវនិតិសម្បទានដើម្បីចូលមកធ្វើកិច្ចការនេះបាន។

ចំណុចបន្តមកទៀតគឺថាទាក់ទងទៅនឹងកន្លែងសាលសវនាការសាធារណៈហ្នឹងឯង  គឺថាយើងមានកៅអីចំនួន៤៩៤  ហើយនៅក្នុងសាលសវនាការសាធារណៈ  ហើយយើងបានធ្វើការបែងចែកទៅតាមប្រភេទក្នុងលក្ខណៈទូទៅ ហើយបានធ្វើការផ្សព្វផ្សាយដល់សាធារណៈ និងមានផ្ដល់ជាព័ត៌មានដល់ពួកគេដែលអំពីការបែងចែកកន្លែងអង្គុយហ្នឹងឯង ។ ជាទូទៅគឺថាយើងមានកៅអី៣០ សម្រាប់មន្ត្រីការទូត  ៦០កៅអីសម្រាប់បុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាល  និង៣៦កៅអី  សម្រាប់អ្នកសារព័ត៌មាន ៣០សម្រាប់សារព័ត៌មាន ១៤០កៅអីសម្រាប់អ្នកនៅក្នុងក្រុមជាធម្មតាដែលបានកក់ទុកជាមុន និង១៤០សម្រាប់អ្នកដែលមកជាក្រុម ។ នេះគឺជាចំណុចនៃការចាប់ផ្ដើមបែងចែកកៅអី ហើយយើងនឹងធ្វើការកែសម្រួលទៅតាម  ថាតើមានគេកក់មុនឬក៏អត់? ហើយពីមុនមកនុំងហ្នឹង  គឺយើងធ្លាប់មានលទ្ធភាពដែលអាចមានទទួលសាធារណជននៅក្នុងសាលសវនាការនោះមានច្រើន ដូច្នេះ យើងសង្ឃឹមថាពួកគេ

នឹងបន្តទៀត ។ លោកប្រធានកាលពីព្រឹកមិញបានអាននូវវិធាន ហើយយើងខ្ញុំក៏មានការពេញចិត្តដែរ ហើយយើងខ្ញុំនឹងធ្វើការផ្សព្វផ្សាយនូវវិធាន ឬក៏បទប្បញ្ញត្តិនៅក្នុងសវនាការនោះផងដែរ ។ ខ្ញុំមិនបាន ស្តាប់ឲ្យបានព័ត៌មានលម្អិតទាំងអស់ទាក់ទងទៅនឹងវិធាន ឬក៏បទប្បញ្ញត្តិនៅក្នុងសាលសវនាការនោះទេ ប៉ុន្តែខ្ញុំមិនដឹងថា តើមានចំណុចមួយដែលបាននិយាយឬទេ? ដែលខ្ញុំនឹងលើកឡើងនៅពេលនេះ គឺការ ស្លៀកសម្លៀកបំពាក់ចូលរួមនៅក្នុងសវនាការ ដែលថាមានផ្លាកសញ្ញាផ្សេងៗនោះ ។ អ៊ីចឹងប្រហែលជា ដូចថាអ្នកដែលពាក់អាវមានផ្លាកសញ្ញាផ្សេងៗប្រហែលជាមិនស័ក្តិសមទេក្នុងការចូលរួមក្នុងសវនាការ។

ហើយចំណុចមួយទៀត ដែលខ្ញុំចង់លើកផងដែរនោះ គឺទាក់ទងនឹងសន្និសីទសារព័ត៌មាន នៅក្នុងប្រទេសខ្មែរយើងនេះ គឺមានការចាំបាច់យ៉ាងខ្លាំងក្នុងការធ្វើមតិយោបល់ពីភាគីផ្សេងៗបន្ទាប់ពី សវនាការបានបញ្ចប់ ។ ហើយពីអតីតកាលនោះ គឺថាយើងបានផ្តល់ឱកាសដើម្បីសារព័ត៌មានបានជួប ជាមួយនឹង បានជួបហ្នឹង ដើម្បីទទួលយកមតិយោបល់ពីភាគីពាក់ព័ន្ធនៅក្នុងសាលសវនាការសាធារណៈ ហើយយើងក៏បានធ្វើការស្នើដល់ខាងផ្នែកគ្រប់គ្រងតុលាការដែរក្នុងការថតនៅពេលធ្វើសន្និសីទសារ-ព័ត៌មាននោះ អ៊ីចឹងប្រហែលជាអ្វីដែលបានរៀបនេះអាចជាការពេញចិត្តបាន ។ ហើយប្រហែលជាអាច ត្រូវការរៀបចំបន្ថែមទៀតក្នុងការរៀបចំការធ្វើសន្និសីទសារព័ត៌មានចុងក្រោយ ដែលកាលពេលនោះ ឯង មានការប្រទាញប្រទុងគ្នារវាងខាងក្រុមមេធាវីការពារក្តី ហើយនិងខាងដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយខ្ញុំគិតថា យើងនឹងធ្វើការប្រយ័ត្នប្រយែងបំផុតដើម្បីផ្តល់ផ្នែកសន្តិសុខក្នុងការរៀបចំ ផ្នែកភាគី ផ្សេងៗគ្នានេះឯងឲ្យធ្វើម្តងម្នាក់ មិនឲ្យធ្វើក្នុងពេលដំណាលគ្នានោះទេ ។ ហើយខ្ញុំមិនបារម្ភថាយើងមិន អាចរៀបចំកិច្ចការងារនេះបាននោះទេ ។

ចំណុចបញ្ចប់ដែលខ្ញុំចង់លើកឡើងទាក់ទងទៅនឹងការផ្សព្វផ្សាយជាសាធារណៈ ការប្រកាសជា សាធារណៈដល់សាធារណជនទាក់ទងទៅនឹងកម្មវិធី និងរបៀបវារៈរបស់តុលាការ និងការប្រកាស ផ្សេងៗទៀតដែលលោកចៅក្រមចង់ធ្វើនោះ ។ កាលពីមុន គឺថាយើងដាក់នៅកាលបរិច្ឆេទរបស់តុលាការ នៅលើ *វេបសាយ* នៅគេហទំព័រ ប៉ុន្តែក្រោយមកបានធ្វើការប្រែសម្រួលបច្ចុប្បន្នភាពទៅតាមវគ្គដែល យើងបានធ្វើរួមបញ្ចូលទាំងវគ្គថ្ងៃនេះផងដែរ ដែលវគ្គនេះគឺជាសវនាការអសាធារណៈ ។ ហើយយើង ស្នើឲ្យមានបន្តទៀតឲ្យមាននូវកិច្ចបែបនេះ ហើយនឹងបានផ្តល់ព័ត៌មានបែបនេះដែរទៅដល់ខាងភាគី ពាក់ព័ន្ធ ឬក៏អង្គការពាក់ព័ន្ធនានាទាក់ទងទៅនឹងសវនាការនេះ ។ ហើយជាទូទៅគឺការធ្វើសវនាការនេះ ត្រូវបានគេរាយការណ៍មានលក្ខណៈទូលំទូលាយបាននៅច្រើនទីកន្លែង ដូចលោកស្រីចៅក្រម ខាតរាយថ៍

បាននិយាយអ៊ីចឹងគឺថា យើងមានត្រូវការ បើទាក់ទងទៅឲ្យខាងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងឯង បានដាក់ពាក្យឲ្យបានមុន ហើយយើងនឹងធ្វើការទាក់ទងជាមួយផ្នែកអង្គភាពជនរងគ្រោះដើម្បីទាក់ទងនៅក្នុងការរៀបចំធ្វើការប្រាស្រ័យទាក់ទងជាមួយខាងដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ ហើយយើងខ្ញុំក៏សូមស្នើផងដែរថា នឹងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅក្នុងកាសែត នៅតាមវិទ្យុ និងតាមរយៈអង្គស្ថានទូតនានា និងតាមសហគមន៍នានានៅបរទេស ។ ហើយយើងសង្ឃឹមថានឹងអាចធ្វើការងារបាននៅក្នុងអនាគតដ៏ខ្លីខាងមុខនេះ ។ ប្រសិនបើខ្ញុំអាចបញ្ចប់បាននោះ ខ្ញុំមានចំណុចមួយដែលខ្ញុំចង់និយាយអំពីទាក់ទងការ ប្រកាសផ្សាយជាសាធារណៈទាក់ទងទៅនឹងការចាប់អារម្មណ៍កាន់តែកើនមានឡើងទៅលើកាលបរិច្ឆេទនៃកាលសវនាការបឋមថាតើនឹងអាចធ្វើនៅពេលណា ? ហើយហ្នឹងថាតើសវនាការពិតប្រាកដនឹងចាប់ផ្តើមនៅពេលណា ? អ៊ីចឹងយើងគិតថា ខាងផ្នែកសារព័ត៌មានចង់ដឹងអំពីចំណុចកាលបរិច្ឆេទនេះណាស់ប្រហែលជានៅដើមសប្តាហ៍ក្រោយហ្នឹង នឹងអាចជាការប្រសើរបំផុតប្រសិនបើពួកគេអាចទទួលបាននូវព័ត៌មានជាក់លាក់ណាមួយ ប្រហែលជាដូចកាលបរិច្ឆេទជាក់លាក់ ឬក៏កាលបរិច្ឆេទជាក់លាក់ណាមួយដែលថានឹងត្រូវកំណត់ឡើង ដូចជាលោកប្រធានបាននិយាយអ៊ីចឹង ។ ដោយសារខាងអង្គបុរេហ្នឹងឯង គាត់នឹងប្រើសាលសវនាការនៅចុងខែកុម្ភៈ អ៊ីចឹងប្រហែលជាមិនអាចធ្វើបានទេ ។ អ៊ីចឹងបើសិនជាលោកចៅក្រមអាចបង្ហាញពីកាលបរិច្ឆេទណាមួយដែលយើងអាចធ្វើបាននោះ ជាការចាប់អារម្មណ៍បំផុត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកស្រីប្រធានដែលបានធ្វើបទបង្ហាញយ៉ាងក្បោះក្បាយអំពីរបៀបវារៈការផ្សាយសាធារណៈ និងការគ្រប់គ្រងព័ត៌មាននៅសវនាការនេះ ។ ហើយពាក់ព័ន្ធនឹងបទបង្ហាញនេះ ជាបន្តទៀតយើងខ្ញុំសូមជូនវេទិកានេះទៅភាគីពាក់ព័ន្ធដែលអាចមានការសួរ ឬក៏កត់សម្គាល់ផ្សេងៗពាក់ព័ន្ធទៅនឹងរបៀបវារៈដែលបង្ហាញអម្បាញ់មិញនេះ ។ ជាដំបូងគឺសូមអនុញ្ញាត និងអញ្ជើញទៅមេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើមានបំណងចង់សួរ ឬក៏មានការកត់សម្គាល់អ្វីពាក់ព័ន្ធជាមួយនឹងបទបង្ហាញនេះ សូមអញ្ជើញ ។ សូមអញ្ជើញ លោកស្រីមេធាវី ។

**លោកស្រី ម៉ាក់ទីន ហ្សាកឃ្សីន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមទាញសេចក្តីចាប់អារម្មណ៍ពីខាងការិយាល័យសាធារណៈបន្តិចថាដោយសារយើងមានកៅអីកំណត់នៅក្នុងបន្ទប់សវនាការនេះសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

ហើយឥឡូវនេះយើងមិនទាន់ដឹង ថាតើនឹងមានកូនក្តីដែលជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុន្មាន? នឹងចូលរួមពេញនោះទេ ហើយគាត់ប្រហែលជាត្រូវអង្គុយនៅក្នុងបន្ទប់ខាងក្រៅក្នុងកន្លែងសាលធំនោះ ។ ហើយពីម្សិលមិញយើងបានជជែកហើយថា យើងប្រហែលជាត្រូវការកន្លែងយ៉ាងហោចណាស់ក៏ ៨០កៅអីដែរ ។ ហើយអ៊ីចឹង ដើម្បីឲ្យពួកគាត់អាចមកអង្គុយបានកុំឲ្យមានបញ្ហា ជាពិសេសខ្ញុំចង់ឲ្យខាងការិយាល័យសាធារណៈហ្នឹង កិច្ចការសាធារណៈពិនិត្យរឿងនេះផងដើម្បីជៀសវាងបញ្ហា ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ។ មានសំណួរអីទៀតទេ មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី? បើពុំមានទេសូមអញ្ជើញខាងសហព្រះរាជអាជ្ញា តើមានអ្វីចង់កត់សម្គាល់ ឬក៏ចង់សួរពាក់ព័ន្ធនឹងរបៀបវារៈដែលពាក់ព័ន្ធនឹងរបៀបវារៈដែលបានបង្ហាញដោយលោកស្រីផ្នែកការិយាល័យកិច្ចការសាធារណៈនេះទេ?

សូមអញ្ជើញលោក ពេទីត ។

**លោក រ៉ូបឺត ពេទីត៖**

សូមអរគុណលោកប្រធាន ។ បើសិនជា ខ្ញុំយល់មិនច្រឡំទេគឺដូចជាមិនទាន់មានការយល់ស្របគ្នានៅឡើយទេ រវាងខាងផ្នែកខាងប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសក្នុងការផ្សព្វផ្សាយអំពីសវនាការប្រចាំថ្ងៃនីមួយៗហ្នឹង ហើយបើតាមខ្ញុំដឹង ហើយយល់ផងដែរទាក់ទងនឹងការផ្សព្វផ្សាយតាម អ៊ីនធឺណេតហ្នឹងគឺយើងមានធ្វើហើយកិច្ចព្រមព្រៀង ក៏ប៉ុន្តែ បើខ្ញុំដឹងគេមានការផ្សាយបន្តផ្ទាល់ទៅកន្លែងប្រព័ន្ធអ៊ីនធឺណេតហ្នឹង ។ ខ្ញុំថាបើសិនជាអ៊ីចឹងមែន ហើយបើសិនជាខ្ញុំយល់មិនច្រឡំទេគឺបញ្ហានេះ គឺបានន័យថាខាងប្រព័ន្ធផ្សព្វផ្សាយអាចនឹងមកនៅទីនេះថតផ្ទាល់ ឬក៏អាចថាថតផ្សាយផ្ទាល់ពីបន្ទប់ខាងក្រោមនៅក្នុងការថតផ្សាយពីសវនាការទាំងស្រុងផ្ទាល់ ខាងអង្គជំនុំជម្រះក៏គួរពិចារណាផងដែរ ។ ហើយខ្ញុំគិតថានៅក្នុងនេះគឺមិនមានពេលវេលាអីត្រូវពន្យារពេលក្នុងការផ្សាយផ្ទាល់ទេ បានន័យថា ព្រោះអីយើងអត់មានឧបករណ៍ដើម្បីពន្យារការផ្សាយហ្នឹងទេ គឺថាសវនាការដំណើរការទៅគឺផ្សាយចេញផ្ទាល់អត់មានកាត់ទេ ។ ហើយអ៊ីចឹងបើសិនជា យើងធ្វើដូច្នេះមែន ការដែលធ្វើដូច្នេះនឹងអាចប៉ះពាល់ដល់ខាងវិធានការការពារដល់សាក្សី ព្រោះយើងអត់មានអីក្នុងការគ្រប់គ្រងនូវព័ត៌មាន ឬក៏រូបភាព វីដេអូ ដែលផ្សាយចេញទៅផ្ទាល់ៗបែបនេះ ដែលមិនមានម៉ាស៊ីនសម្រាប់កាត់តមុននឹងអាចចេញផ្សាយផ្ទាល់បាននេះ ។ ហើយខ្ញុំទាក់ទងជាមួយនឹងសវនាការមែនទែននោះ ខ្ញុំជឿថាដើមបណ្តឹង ឬក៏ភាគីទាំងអស់គ្នាហ្នឹងគួរ

តែបានជ្រាបពីបញ្ហានេះឱ្យបាន ទូលំទូលាយសិនមុននឹងយើងអាចដំណើរការបាន ។ សូមអរគុណលោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

សូមជូនវេទិកានេះទៅជូនមេធាវីការពារជនជាប់ចោទ តើលោកមេធាវីមានអ្វីចង់សួរ ឬចង់កត់សម្គាល់អំពីការផ្សាយសវនាការ និងការគ្រប់គ្រងព័ត៌មាន ដែលបង្ហាញឡើងដោយលោកស្រីប្រធានការិយាល័យកិច្ចការសាធារណៈអម្បាញ់មិញនេះទេ? សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកចៅក្រមប្រធាន ។ ខ្ញុំសូមលើកឡើងអំពីយោបល់ដែលបាន ដែលខ្ញុំបានឮពីកន្លងមក ។ មែនទែនទៅ គឺគេជាទូទៅគេច្រើនបន្ទោសយើងទាក់ទងជាមួយនឹងផ្នែកខាងព័ត៌មាននេះព្រោះជាទូទៅសាធារណជន ហើយនឹងពិភពលោកគឺគេចង់បានឱ្យសវនាការរបស់យើងធ្វើជាព្រឹត្តិការណ៍មួយដ៏មហាឱឡារិកសម្រាប់អ្នកទាំងអស់គ្នានោះ ។ អ៊ីចឹងខ្ញុំចង់ទាញការយកចិត្តទុកដាក់ពីលោកចៅក្រម និងអ្នកទាំងអស់ផងដែរ និយាយអំពីសារសំខាន់បំផុតនៅក្នុងការធានាឱ្យមានការផ្តល់ជូនព័ត៌មានទៅដល់សាធារណជន ជាពិសេសទាក់ទងជាមួយនឹងមិនចំពោះថាមានអ្វីមួយដែលកើតឡើងនៅទីនេះទេ ។ មានមនុស្សមួយចំនួនគឺគេបានស្នើថា វាអាចនឹងថា រាល់ពេលល្ងាចគឺគេចង់ឱ្យមានការសង្ខេបឡើងវិញនូវកិច្ចដំណើរការនីតិវិធីប្រចាំមួយថ្ងៃហ្នឹង គេមិនចង់ឱ្យយើងថតផ្សាយបន្តផ្ទាល់តាំងពីព្រឹកទល់ល្ងាចទេ ។ ជាទូទៅ ព្រោះអីយើងមិនដឹងថាមានអ្នកណាមានពេលទៅអង្គុយមើលតាំងពីដើមរហូតដល់ចប់ទេ ក៏ប៉ុន្តែខ្ញុំ នេះជាការយល់ឃើញរបស់ខ្ញុំ ហើយខ្ញុំគិតថាយើងគួរតែយកចិត្តទុកដាក់ផងដែរនៅលើចំណុចនេះព្រោះយើងថាចង់ ការដែលផ្សាយនេះគឺផ្សាយនូវអ្វីដែលយើងកំពុងតែធ្វើនៅទីនេះ ។ ហើយខ្ញុំមែនទែនទៅ មិនចង់ឱ្យការផ្សព្វផ្សាយនេះគឺគ្រាន់តែនិយាយពីរឿងតុលាការទេ ក៏ប៉ុន្តែ ធ្វើជាឧបករណ៍សម្រាប់អប់រំផង ។ អ៊ីចឹងទេបានយើងត្រូវតែ តាមគោលការណ៍បច្ចេកទេសហ្នឹង ជាគោលការណ៍ហ្នឹងគឺយើងត្រូវតែផ្សព្វផ្សាយជាសាធារណៈកុំឱ្យលាក់ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

...លោកមេធាវីដែលមានចំណាប់អារម្មណ៍ ហើយកត់សម្គាល់ពីបញ្ហានេះ ។ ជាបន្តទៀត សូមអញ្ជើញលោកស្រីប្រធានផ្នែកកិច្ចការសាធារណៈឆ្លើយតបទៅនឹងសំណួរ ឬការកត់សម្គាល់របស់អ្នកដែលមានការពាក់ព័ន្ធនឹងប្រធានបទអម្បាញ់មិញ សូមអញ្ជើញ លោក។

**លោកស្រី ហេឡែន ចាវីស៖**

អរគុណលោកប្រធានដែលបានផ្តល់ឱកាសឲ្យខ្ញុំម្តងទៀតក្នុងការឆ្លើយតប ។ ដូចខាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងហើយ គឺខ្ញុំក៏បានជម្រាបដែរគឺនិយាយពីការរៀបចំកៅអីដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានអង្គុយ ហើយខ្ញុំនឹងជជែកជាមួយអង្គភាពជនរងគ្រោះដើម្បីរៀបចំកិច្ចការនេះឲ្យបានល្អមុននឹងយើងធ្វើសវនាការ ។ ហើយខ្ញុំសូមយក ចំណុចមួយដែលលោកខាងសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងពីរឿងការផ្សាយបន្តផ្ទាល់ហើយខ្ញុំគិតថា នេះគឺជាអ្វីដែលយើងត្រូវមើលយកចិត្តទុកដាក់ឲ្យមែនទែនផងដែរ ព្រោះអីបើសិនជាយើងមានឧបករណ៍បញ្ចាំងរូបភាពវីដេអូទៅនៅក្នុងបន្ទប់ធំ នេះគឺបានន័យថា បើសិនជាយើងបញ្ចេញរូបផ្ទាល់ទៅក្នុងបន្ទប់ខាងក្រោមឲ្យអ្នកប្រព័ន្ធផ្សព្វផ្សាយមើលខ្ញុំថាមិនអីទេ ដោយសារយើងមានមន្ត្រីសន្តិសុខរបស់យើងនៅចាំឃ្លាំមើលក្រែងលោមាននរណាយកវីដេអូកាម៉េរ៉ា ឬក៏ថតរូបនៅការផ្សព្វផ្សាយនេះហើយខ្ញុំជឿថាប្រហែលជាមិនជាបញ្ហាទេ ។ ហើយនៅក្នុងនេះក៏នៅបន្ទប់ខាងក្រោមនេះក៏យើងអនុញ្ញាតឲ្យមាន ឌុយ សម្រាប់ដោតយករូបផ្ទាល់តែម្តងពីសវនាការ ។ ហើយអ៊ីចឹងនៅក្នុងនេះគឺវាអាស្រ័យទៅលើការគ្រប់គ្រង អ៊ីចឹងគ្រាន់តែថាយើងត្រូវការការពិនិត្យ និងពិចារណា និងពិភាក្សាបន្តទៀត ជាពិសេសជាមួយនឹងផ្នែកគ្រប់គ្រងតុលាការស្តីអំពីបច្ចេកទេសក្នុងការគ្រប់គ្រងរូបភាពវីដេអូនេះ ។ ហើយខ្ញុំក៏ត្រូវការការឲ្យយោបល់ពីអង្គជំនុំជម្រះផងដែរទាក់ទងជាមួយចំណុចនេះ ។ ហើយទាក់ទងជាមួយនឹងការដែលលោក ហ្វ្រង់ស្វ័រ រូ លើកឡើងពី ថាតើល្ងាចៗហ្នឹងនៅក្នុងតាមកញ្ចក់ទូរទស្សន៍គួរតែសង្ខេបព្រឹត្តិការណ៍ដែលមានប្រចាំថ្ងៃនៅក្នុងសវនាការ គឺជាអ្វីដែលយើងចង់បានដែរ ព្រោះអីខ្ញុំបានជម្រាបហើយថាបើយើងផ្សាយព័ត៌មានអីរួចចាំស្អែកបានផ្សាយព្រឹត្តិការណ៍ថ្ងៃ នេះវាហួសទៅហើយ អ៊ីចឹងវាសឹងថាយឺតពេល ។ អ៊ីចឹងខ្ញុំក៏គាំទ្រនូវគំនិតហ្នឹង បានន័យថាយកល្អ គឺបានន័យថាក្នុងពេលល្ងាចហ្នឹង គឺនៅតាមកញ្ចក់ទូរទស្សន៍គួរតែយើងផ្សាយព័ត៌មានសង្ខេបហ្នឹង ។ ហើយខ្ញុំគិតថា ខ្ញុំសង្ឃឹមថាមានអង្គការមួយចំនួនដែលគាត់ចង់ទាញយកប្រយោជន៍ពីសវនាការនេះដើម្បីបុព្វហេតុនៃការធ្វើការអប់រំ ឬក៏គាត់ចង់ធ្វើជាឯកសារសង្ខេបផ្សព្វផ្សាយប្រចាំពីរសប្តាហ៍ម្តង ឬក៏យ៉ាងម៉េចនោះ ព្រោះអីខ្ញុំដឹងហើយថាមិនមានទស្សនិកជន ឬក៏ប្រជាពលរដ្ឋយើងបានមើលសវនាការហ្នឹងបានមួយថ្ងៃវាស់ល្ងាចទេ ហើយអ្នកខ្លះនៅស្រុកជនបទ នៅចម្កាត់មាត់ញក មិនមានទូរទស្សន៍មើលផង ។ អ៊ីចឹងបានជាយើងធ្វើជាផលិតជា*ឌីវីឌី* ឬ*វីស៊ីឌី* ដើម្បីចែកជូនទៅដើម្បីឲ្យបានជ្រាបគ្រប់ៗគ្នា ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីដែលបានឆ្លើយតបនឹងនៅសំណួរ និងការកត់សម្គាល់ផ្សេងៗរបស់ភាគី។ ខ្ញុំកត់សម្គាល់ឃើញថា មានបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងការសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងលើការផ្សាយនេះជាសាធារណៈ ឬអសាធារណៈ ។ ដោយបញ្ហានេះជាបញ្ហាស្មុគស្មាញដែរ ហើយខ្ញុំសូមកត់ត្រាទុកនូវអ្វីដែលបានកត់សម្គាល់នេះ ហើយនិងយើងខ្ញុំនឹងលើកយកទៅប្រជុំពិភាក្សាជាបន្តបន្ទាប់មុននឹងកិច្ចដំណើរការដើម្បីខ្ញុំមានវិធានការជាក់លាក់ ដើម្បីឲ្យការផ្សព្វផ្សាយទៅគឺមានលក្ខណៈច្បាស់លាស់ កុំឲ្យវាចៀសវាងមានកំហុស ។

បើជាសិនមិនមានបញ្ហាសំណួរអីពាក់ព័ន្ធទៀតទេ គឺខ្ញុំគិតថា កិច្ចប្រជុំរបស់យើងហ្នឹងគឺតាមរបៀបវារៈដែលបានគ្រោងទុក បានចប់សព្វគ្រប់ហើយ ។ ហើយដោយសារមានសំណូមពរទទូចជាច្រើន ដែលចង់ដឹងចង់ឮអំពីការកំណត់កាលបរិច្ឆេទសវនាការបឋមនោះ ថ្ងៃនេះក្រោយពីនៅពេលបាយនេះ យើងបានប្រជុំពិភាក្សាគ្នាជាចុងក្រោយនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ។ យើងបានឯកភាពគ្នាថាការកំណត់កាលបរិច្ឆេទសវនាការបឋម លទ្ធភាពដែលអាចធ្វើទៅបាននោះ គឺនៅថ្ងៃទី១៦និងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ។

នេះគឺជាការគិត ប្រហែលជាយើងគ្រោងលទ្ធភាពនៅពេលនេះ ។ ពីព្រោះបើពេលក្រោយនេះគឺមានបញ្ហាជាប់សវនាការរបស់អង្គបុរេនៅទីនេះ ហើយសប្តាហ៍បន្ទាប់ទីបី-- សប្តាហ៍ទីមួយនៃខែបីនោះ គឺយើងធ្វើ *ផ្លេនណារី* ប្រជុំពេញអង្គ ។ ហើយបើយើងទុកតទៅទៀតនោះ គឺពេលវេលាវែងណាស់ យើងមិនអាចទទួលបានទេ ។ អ៊ីចឹងលទ្ធភាពនោះគឺយើងប៉ុណ្ណឹង ។ កំណត់ដូចខ្ញុំបានជម្រាបអ៊ីចឹងគឺជាការប៉ាន់ស្មាន ឬក៏លទ្ធភាពដែលយើងអាចធ្វើបាន ។

អ៊ីចឹងគឺពាក់ព័ន្ធជាមួយនឹងបញ្ហានេះ ខ្ញុំសូមសួរទៅភាគីទាំងអស់ថា បើលទ្ធភាពយើងនឹងគ្រោងធ្វើដូច្នេះមែនហ្នឹង តើវាមានបញ្ហាអ្វីទេអំពីលទ្ធភាពក្នុងការចូលរួមនៅក្នុងកិច្ចប្រជុំសវនាការបឋមនេះ? មានបញ្ហាអីទេ?

**លោក អាប់ឌុលឡាក់ ចារីក៖**

ខ្ញុំគិតថា រឿងហ្នឹងរឿងផ្សេងទេលោកចៅក្រម មិនអីទេ ខ្ញុំមិនមែនពាក់ព័ន្ធរឿងហ្នឹងទេ សូមអធ្យាស្រ័យ ។

**ប្រធានអង្គជំនុំ៖**

មានទេ? សូមអញ្ជើញលោកមេធាវីការពារក្ដី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសូមឆ្លើយតបទៅនឹងសំណើរបស់លោក កាលវិភាគដែលលោកលើកមកនេះ គឺខាងមេធាវីការពារក្ដី ខ្ញុំមានពេលអាចចូលរួមបាន គឺ១៦-១៧ ខែកុម្ភៈ ហ្នឹង មិនមានបញ្ហាអីទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណ មេធាវីដែលបានផ្ដល់ព័ត៌មាននេះ ។ អ៊ីចឹងទេបើសិនមិនមានបញ្ហាអីទេ ករណីនេះ អង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្ដីសម្រេចកំណត់អំពីកាលបរិច្ឆេទសវនាការបឋមហ្នឹងនៅក្នុងសប្ដាហ៍ក្រោយ គឺសប្ដាហ៍ក្រោយនេះ ។ នៅថ្ងៃច័ន្ទ សប្ដាហ៍បន្ទាប់ពីនេះទៅ យើងនឹងចេញនូវដីកាសម្រេចកំណត់កាលបរិច្ឆេទសវនាការបឋមជាផ្លូវការ ។

ចំណុចបន្ថែមទៀតគឺអង្គជំនុំជម្រះសាលាដំបូងសូមជម្រាបផងដែរ ដល់មេធាវីការពារជនជាប់ចោទអំពីបំណងដែលលោកចង់ដាក់នូវអញ្ញត្រកម្ម គប្បីដាក់ឲ្យបានមុនកាលបរិច្ឆេទកំណត់មុនសវនាការបឋម ។ ហើយដូចគ្នានេះដែរ គឺមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានបំណងចង់សុំឲ្យមានវិធានការការពារចំពោះដើមបណ្ដឹងរដ្ឋប្បវេណីអាណាមួយ ឬច្រើន គប្បីដាក់ពាក្យសុំឲ្យបានមុនកាលបរិច្ឆេទកំណត់មុនការសវនាការបឋម ។

កាលបរិច្ឆេទកំណត់ដាក់នូវអញ្ញត្រកម្ម ឬក៏ដាក់ពាក្យសុំវិធានការការពារ អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់ក្នុងដីកាសម្រេចកំណត់កាលបរិច្ឆេទសវនាការបឋម ។ នេះគឺជាការជូនជាព័ត៌មាន ។ សូមអញ្ជើញលោកស្រីប្រធានការិយាល័យកិច្ចការសាធារណៈ ។

**លោកស្រី ហេឡែន ចាវីស៖**

លោកប្រធានខ្ញុំសូមអធ្យាស្រ័យ ខ្ញុំសូមការឲ្យយោបល់ពីលោកប្រធាន និងអង្គជំនុំជម្រះបានទេ ថាតើយើងអាចធ្វើសេចក្ដីប្រកាសទៅឲ្យប្រព័ន្ធផ្សព្វផ្សាយដឹងអំពីថ្ងៃ១៦-១៧ ខែកុម្ភៈ អំពីរឿងសវនាការបឋមហ្នឹងបានឥឡូវ ឬក៏យ៉ាងម៉េចដែរលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ខ្ញុំបានជម្រាបមិញ អានេះគ្រាន់តែជាការរំពឹងទុកទេថា យើងនឹង-- លទ្ធភាពដែលយើងជម្រើសដែលយើងពិចារណាទៅ គឺលទ្ធភាពពេលហ្នឹង ។ ហើយចំណែកឯថាសម្រេចជាក់លាក់យ៉ាងណានោះ

គឺថាអាស្រ័យលើចេញដីកាសម្រេច ។ ហើយប្រហែលជាមិនយូរទេ យើងនឹងប្រឹងប្រែងនៅក្នុងសប្តាហ៍ក្រោយ ចាប់ពីថ្ងៃច័ន្ទទៅយើងពិនិត្យអាទិភាពនៅក្នុងបញ្ហានេះ ។ ហើយយើងធ្វើក្នុងរយៈពេលខ្លះទេ ដោយសារយើងមានបទពិសោធន៍ក្នុងការកំណត់កាលបរិច្ឆេទប្រជុំនេះហើយ ។ អ៊ីចឹងយើងមានទម្រង់បែបផែនរួចហើយ ហើយអ្វីដែលយើងបានគ្រោងៗជាច្រើនខែហើយ ។ អ៊ីចឹងយើងគ្រាន់តែរៀបចំដើម្បីឲ្យទៅជាភាសាមួយហ្នឹងច្បាស់លាស់ ហើយឯកភាពគ្នាសម្រេចគ្នាដោយ *ធីស៊ី* យើងនឹងបកប្រែជាភាសាទាំងបីភាសា ហើយយើងចេញតែម្តង ប្រហែលជាមិនយឺតយ៉ាវទេ សូមរង់ចាំ ។

ជាចុងក្រោយនេះសូមអញ្ជើញលោក ថារីក ដែលលោកមានការប៉ុនប៉ងជម្រាបដល់ភាគីទាំងអស់ដែលមានការចង់ដឹងអំពីទម្រង់ ឬក៏បែបបទ បែបផែននៃការការពារ វិធានការការពារសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសាលសវនាការ ។ សូមអញ្ជើញលោក ថារីក ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមជម្រាបអ្នកទាំងអស់ទាក់ទងជាមួយការធ្វើការបំភ្លឺនេះ គឺខ្ញុំសូមអញ្ជើញមកចូលរួមនៅថ្ងៃទី២០ គឺថ្ងៃអង្គារ ខែមករា យើងហ្នឹងនៅម៉ោងដប់មួយនៅក្នុងបន្ទប់សវនាការ គឺយើងនឹងធ្វើការបង្ហាញ អំពីថាតើការពារសាក្សីហ្នឹង គឺយើងរៀបចំយ៉ាងដូចម្តេច?

អ៊ីចឹងខ្ញុំសូមលើកទឹកចិត្តឲ្យលោកទាំងអស់គ្នា អ្នកដែលពាក់ព័ន្ធហ្នឹង អញ្ជើញមកចូលរួមហើយចំពោះលោកមេធាវីការពារក្តី បើសិនជាលោកមកមិនបានថ្ងៃហ្នឹង យើងរៀបចំជូនសម្រាប់លោកក៏ប៉ុន្តែខ្ញុំសូមឲ្យភាគីផ្សេងៗទៀតអញ្ជើញមកតាមកាលកំណត់នេះ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោក ថារីក ដែលបានផ្តល់ព័ត៌មាននេះដល់អង្គប្រជុំរបស់យើង ។ ហើយខ្ញុំក៏ ខ្លួនខ្ញុំផ្ទាល់ ឬក៏អង្គជំនុំជម្រះ ចៅក្រមអង្គជំនុំជម្រះក៏បានចង់ដឹងអំពីវិធានការ ឬក៏ចំណាត់ការការពារសាក្សី នៅពេលដែលសុំមានវិធានការការពារនៅក្នុងសាលសវនាការដែរ ។ ដល់ពេលយើងដឹងជាមុនយើងបានត្រៀមខ្លួនជាមុនទៅ ដល់ពេលចំណាត់ការ ជាពិសេសបង្គាប់បញ្ជាអីផ្សេងៗ ដើម្បីចាត់វិធានការឲ្យបានត្រឹមត្រូវចៀសវាងមានកំហុសខុសឆ្គង ព្រោះយើងនឹងផ្សាយជាសាធារណៈផង ។

សូមអរគុណ ព័ត៌មាននេះ ហើយខ្ញុំនឹងជម្រាបជូនដល់ទៅ-- នឹងចូលរួម រីករាយនឹងការចូលរួមបើចង់ដឹងនឹងបញ្ហានេះណាស់ ។

កិច្ចប្រជុំរបស់យើងក៏ដល់ទីបញ្ចប់ហើយ ដោយរបៀបវារៈដែលយើងបានគ្រោងទុក គឺបាន

ពិភាក្សាគ្នាសព្វគ្រប់ហើយ អ៊ីចេះគឺចុងក្រោយនេះ ខ្ញុំសូមធ្វើបូកសរុបនូវលទ្ធផលនៃកិច្ចប្រជុំរបស់យើងដូចតទៅនេះ៖

អស់លោក លោកស្រីដែលជាសមាជិកសមាជិកានៃអង្គប្រជុំ ព្រមទាំងអ្នកចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការទាំងអស់ជាទីគោរពរាប់អាន ក្នុងនាមខ្ញុំផ្ទាល់ និងក្នុងនាមជំនួសមុខឲ្យអង្គជម្រះសាលាដំបូង ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលបានសម្រេចតាមរយៈកិច្ចប្រជុំរយៈពេលពីរថ្ងៃ ថ្ងៃទី១៥ និងថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ នេះ ។

អង្គជំនុំជម្រះសង្កេតឃើញថា កិច្ចប្រជុំនេះមានការចូលរួមនិងពិភាក្សាយ៉ាងផុសផុលពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា មេធាវីជនជាប់ចោទ និងអង្គភាពចំណុះឲ្យការិយាល័យរដ្ឋបាល ដែលមានតួនាទីភារៈកិច្ចពាក់ព័ន្ធផ្ទាល់ដល់កិច្ចដំណើរការនីតិវិធី ។ កិច្ចប្រជុំរៀបចំសវនាការពិតជាបានជួយសម្រួលដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការរៀបចំសវនាការបឋមក៏ដូចជាត្រៀមខ្លួនសវនាការអង្គសេចក្តីនាពេលខាងមុខដែរ ។

ឆ្លងតាមកិច្ចប្រជុំនេះ យើងបានកំណត់នូវបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ ។ បានពិភាក្សាលើបញ្ហាមួយចំនួនដែលចង្អុលបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង ។ បានបំភ្លឺនូវបញ្ហាមួយចំនួនដែលបានស្នើឡើងដោយភាគី ។ បានដឹងនូវបញ្ហាថ្មីៗបន្ថែមទៀតពាក់ព័ន្ធនឹងការរៀបចំក្រុមមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី និងបច្ចុប្បន្នភាពនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ថែមពីលើនេះទៀត យើងបានស្តាប់នូវបទបង្ហាញពីអង្គភាពនានាដែលចំណុះការិយាល័យរដ្ឋបាល ដែលបានត្រៀមខ្លួនជួយជ្រោមជ្រែង សម្រាប់បើកសវនាការបឋម ក៏ដូចជាសវនាការអង្គសេចក្តីដែរ ។

ក្រោយពីបញ្ចប់នូវកិច្ចប្រជុំនេះ អង្គជំនុំជម្រះសាលាដំបូងនឹងយកព័ត៌មានដែលទទួលបានពីកិច្ចប្រជុំនេះ ទៅធ្វើការពិភាក្សាលម្អិត ដើម្បីកំណត់នូវកាលបរិច្ឆេទសម្រាប់សវនាការបឋម ដែលអង្គជំនុំជម្រះសាលាដំបូងនឹងជម្រាបជូនព័ត៌មាននៅសប្តាហ៍ក្រោយនេះ ។

ជាចុងបញ្ចប់ ជំនួសមុខអង្គជំនុំជម្រះសាលាដំបូងនិងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់សហព្រះរាជអាជ្ញា ដល់មេធាវីការពារជនជាប់ចោទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមន្ត្រីនៃអង្គភាពចំណុះឲ្យការិយាល័យរដ្ឋបាល កងសន្តិសុខ អនុរក្សពន្ធនាគារ មន្ត្រីអង្គជំនុំជម្រះសាលាដំបូងទាំងអស់ និងអ្នកបកប្រែផងដែរ ដែលបានចូលរួម និងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងក្នុងការជួយសម្រួលដល់កិច្ចដំណើរការប្រជុំថ្ងៃនេះ សម្រេចបានជោគជ័យ ។

ឆ្លៀតឱកាសនេះដែរ ជាការចាប់ផ្តើមឆ្នាំ២០០៩នេះផង ខ្ញុំសូមគោរពជូនពរដល់អស់លោក លោកស្រី នាងកញ្ញាទាំងអស់ឲ្យជូននូវពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមអស់លោក លោកស្រី នាងកញ្ញាទទួលបានជោគជ័យនៅក្នុងការបំពេញភារកិច្ច ។

ខ្ញុំសូមប្រកាសបិទកិច្ចប្រជុំរៀបចំសវនាការចាប់ពីពេលនេះតទៅ ។

អនុរក្សមន្ទីរឃុំឃាំងសូមលោកនាំខ្លួនលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រឡប់ទៅមន្ទីរឃុំឃាំងវិញចុះ ៕

*(កិច្ចប្រជុំបញ្ចប់នៅម៉ោង១៤:១២នាទី)*